# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដី នៅក្នុងឃុំកំពង់គោ
# ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ
# ឆ្នាំ២០១៧ ដល់ ២០៣២





រៀបចំដោយ : ក្រុមហ៊ុនផ្ដល់សេវាកម្មSBK R&D

សម្របសម្រួលដោយ : ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីស្រុកកំពង់ស្វាយ

គាំទ្របច្ចេកទេសដោយ : អង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ(NIO-MLMUPC) និងថ្នាក់ខេត្ត(PIO)

ឧបត្ថម្ភថវិកាដោយ : រាជរដ្ឋាភិបាលកម្ពុជា (RGC) , ADB_Loan , GAFSP_Grant និងSCF_ADB

# មាតិកា


**អារម្ភកថា** ..... VII

**សេចក្តីផ្តើម** ..... 1

**ជំពូក១៖ ព័ត៌មានស្តីពីស្ថានភាពឃុំកំពង់គោ** ..... 3

**១.១.ស្ថានភាពឃុំ** ..... 3

១.១.១.ទីតាំងរដ្ឋបាលឃុំ ..... 3

១.១.២.ប្រជាសាស្ត្រ ..... 6

ក.ចំនួនប្រជាជន ..... 6

ខ.អត្រាកំណើន ដង់ស៊ីតេ និងរបាយប្រជាជន ..... 7

គ.ជនជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់ ..... 8

ឃ.របររកទទួលទាន ..... 8

ង.ចំណូលស្រុក និងចំណាកស្រុក ..... 10

១.១.៣.ស្ថានភាពសេដ្ឋកិច្ច ..... 11

ក.ប្រភពចំណូលចម្បង និងបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋ ..... 11

ខ.កម្រិតជីវភាពរស់នៅ ចំណូល ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ ..... 11

គ.ស្ថានភាពបំណុលសរុប និងអត្រាការប្រាក់ ..... 13

ឃ.ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់ ឬក្រោមរូបភាពផ្សេងៗ ..... 13

ង.ចំណូលពីប្រភពផ្សេងៗ ..... 13

១.១.៤.ស្ថានភាពអប់រំ និងសិក្សាធិការ ..... 14

ក.ស្ថានភាពអប់រំ ..... 14

ខ.ស្ថានភាពអក្ខរកម្ម ..... 15

គ.ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត ..... 16

១.១.៥.ស្ថានភាពសុខាភិបាល ..... 16

១.១.៦.ស្ថានភាពយេនឌ័រ ..... 19

**១.២.ស្ថានភាពភូមិសាស្ត្រ** ..... 20

១.២.១.ទីតាំងភូមិសាស្ត្រ ..... 20

១.២.២.អាកាសធាតុ (ពិពណ៌នាតាមរដូវកាល) ..... 25

១.២.៣.ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន ..... 26

១.២.៤.បរិក្ខាសាធារណៈ ..... 28

ក.ស្ថានភាពប្រើប្រាស់អគ្គិសនី......28
ខ.ប្រព័ន្ធទឹកស្អាត......29
**១.៣. ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន**......30
១.៣.១.ស្ថានភាពការកាន់កាប់ និងគ្រប់គ្រង......30
ក.ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ......32
ខ.ដីកសិកម្ម......33
គ.ដីព្រៃ/គម្របព្រៃឈើ......34
គ.១.ព្រៃតាមដងស្ទឹង......34
គ.២.ព្រៃលិចទឹក......35
ឃ.ផ្ទៃទឹក និងខ្សែទឹក......35
ឃ.១.បឹង......35
ឃ.២.ស្ទឹងមានទឹកតាមរដូវ......36
ឃ.៣.អាងស្តុកទឹក......36
ឃ.៤.ស្រះ......37
១.៣.២.ផលិតកម្មកសិកម្ម......38
ក.ផលិតកម្មដំណាំស្បៀង......38
ខ.ផលិតកម្មដំណាំរួមផ្សំ......39
គ.ផលិតកម្មឧស្សាហកម្ម......39
១.៣.៣.ធនធានធម្មជាតិ......39
ក.ធនធានព្រៃឈើ......39
ខ.ធនធានជលផល......40
គ.ធនធានរ៉ែ......41
**១.៤.ទីផ្សារ និងខ្សែសង្វាក់ផលិតផល**......41
១.៤.១.ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ......41
១.៤.២.ខ្សែសង្វាក់ និងចរាចរផលិតផល......41
១.៤.៣.ឧបសគ្គ និងឱកាស......43
**ជំពូក២៖ ការវិភាគ តម្រូវការ សក្តានុពល និងឧបសគ្គសម្រាប់អនាគត**......44
**២.១.តម្រូវការសម្រាប់អនាគត**......44
២.១.១.ផែនការអភិវឌ្ឍ ឃុំ......44

ក.ផែនការអភិវឌ្ឍសង្កាត់៥ឆ្នាំ(២០១៨-២០២២)......44
ខ.គម្រោងអភិវឌ្ឍផ្សេងៗទៀតដែលបានអនុម័តរួច......47
២.១.២.ចំណោលប្រជាសាស្ត្រគិតទៅដល់ឆ្នាំ២០៣២......48
២.១.៣.តម្រូវការដីជាមូលដ្ឋាន......49
ក.តម្រូវការដីលំនៅឋាន......49
ខ.ដីកសិកម្ម......50
គ.ដីព្រៃឈើ......51
ឃ.ធនធានទឹក......52
ង.ហេដ្ឋារចនាសម្ព័ន្ធសង្គម និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត......52
ង.១.វិស័យអប់រំ......52
ង.២.សម្រាប់វិស័យសុខាភិបាល......54
ង.៣.អគ្គិសនី......54
ង.៤.ទីលានចាក់សំរាម......54
ង.៥.ដីកប់ខ្មោច......55
ង.៦.ស្រះ និងអណ្តូងទឹក......55
**២.២.តំបន់សេដ្ឋកិច្ច**......55
**២.៣.ការប្រឈម**......57
២.៣.១.ការប្រឈមដោយធម្មជាតិ......57
ក.កំណើនប្រជាជន......57
ខ.គ្រោះធម្មជាតិការបេះបែរនៃធម្មជាតិ......57
២.៣.២.ការប្រឈមដោយ ការអភិវឌ្ឍដែលពុំមាននិរន្តរភាព......57
**២.៤.ឱកាស**......58
២.៤.១.ដោយអំណោយផលពីធម្មជាតិ......58
២.៤.២.ដោយបច្ចេកវិទ្យាថ្មីៗ......58
២.៤.៣.ដោយគម្រោងវិនិយោគ......59
**២.៥.បញ្ហា មូលហេតុ និងដំណោះស្រាយ**......59
**ជំពូក៣ ៖ ផែនការប្រើប្រាស់ដីអនាគតឆ្នាំ ២០១៧-២០៣២**......62
**៣.១.តម្រូវការ ស្ថានភាព និងសក្តានុពលដីជាក់ស្តែង**......62
៣.១.១.តម្រូវការដីទៅតាមប្រភេទ......62

៣.១.២.ស្ថានភាពនៃដីធ្លី និងសក្ដានុពល......62
**៣.២.ការបែងចែកដីទៅតាមតម្រូវការប្រើប្រាស់**......64
៣.២.១.ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ......64
៣.២.២.ផែនទីប្រើប្រាស់ដីអនាគត......66
៣.២.៣.សេចក្ដីអត្ថាធិប្បាយអំពីការប្រើប្រាស់ដីនាពេលអនាគត......68
ក.ដីលំនៅឋាន ភូមិ......68
ខ.ដីស្រែប្រាំង......68
គ.ព្រៃដាំឡើងវិញ......69
ឃ.ព្រៃតាមដងស្ទឹង......70
ង.ព្រៃលិចទឹក......70
ច.បឹង......70
ឆ.ស្ទឹង......71
ជ.អាងស្តុកទឹក......71
ឈ.ស្រះក្នុងតំបន់២ជុំវិញបឹងទន្លេសាប......71
**៣.៣.ដំណោះស្រាយផ្សេងៗ ក្នុងករណីខ្វះខាតដីធ្លី**......72
**៣.៤.កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព**......72
៣.៤.១.កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព......72
ក.ការគ្រប់គ្រងប្រព័ន្ធកសិកម្ម......72
ខ.ការគ្រប់គ្រងព្រៃឈើ ផលអនុផល និង ធនធានសំខាន់ៗផ្សេងៗទៀត......74
៣.៤.២.គម្រោងគាំទ្រចាំបាច់ សម្រាប់គាំទ្រនិរន្តរភាព......75
**៣.៥.សេចក្ដីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់២០៣២)**......75

## បញ្ជីតារាង

តារាង 1៖ ស្ថានភាពទូទៅនៃឃុំ......3
តារាង 2៖ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្ដាភូមិ......6
តារាង 3៖ ស្ថិតិប្រជាជន ឆ្នាំ២០១៧ តាមក្រុមអាយុ......7
តារាង 4៖ ស្ថិតិប្រជាជនតាមបណ្ដាឆ្នាំ និងការគណនាអត្រាកំណើនមធ្យម......8
តារាង 5៖ តារាងមុខរបរ......8
តារាង 6៖ តារាងមុខរបរបន្ទាប់បន្សំ......10
តារាង 7៖ ស្ថិតិប្រជាជនផ្លាស់ប្ដូរទីលំនៅក្នុងឆ្នាំ២០១៦-២០១៧......10
តារាង 8៖ ស្ថិតិប្រជាជនចំណាកស្រុក......11
តារាង 9៖ តារាងកម្រិតជីវភាពរបស់ប្រជាជន......12

តារាង 10៖ ស្ថិតិសាលារៀន ស្ថានភាពអប់រំ និងសិក្សាធិការក្នុងឃុំឆ្នាំ២០១៧ 15
តារាង 11៖ ស្ថិតិអ្នកមិនចេះអក្សរ 15
តារាង 12៖ ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត 16
តារាង 13៖ សុខភាពមាតានិងទារក 17
តារាង 14៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព 18
តារាង 15៖ ការវិភាគលើតួនាទីយេនឌ័រ ឃុំកំពង់គោ 19
តារាង 16៖ ក្រាមពំនុះកាត់ទទឹង ឃុំកំពង់គោ ស្រុកកំពង់ស្វាយ 22
តារាង 17៖ ប្រព័ន្ធធារាសាស្ត្រ 24
តារាង 18៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ 26
តារាង 19៖ ប្រព័ន្ធផ្លូវដឹកជញ្ជូន 27
តារាង 20៖ ស្ថិតិអ្នកប្រើប្រាស់អគ្គិសនី 28
តារាង 21៖ ស្ថិតិអ្នកប្រើប្រាស់ការប្រើប្រាស់ទឹក 29
តារាង 22៖ តារាងវាយលម្អិតតាមប្រភេទនៃការប្រើប្រាស់ដីបច្ចុប្បន្ន 32
តារាង 23៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស 38
តារាង 24៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស 39
តារាង 25៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស 40
តារាង 26៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស 40
តារាង 27៖ស្ថិតិផលិតផលស្រូវ និងតម្លៃ 41
តារាង 28៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស 43
តារាង 29៖ ក្របខ័ណ្ឌនៃការអភិវឌ្ឍ និងជម្រើសនៃការប្រាស់ដីធ្លីអនាគត 44
តារាង 30៖ ចំណោលប្រជាសាស្ត្រនៃចំនួនគ្រួសារ និងប្រជាជនសរុប (០៥ឆ្នាំ) 49
តារាង 31៖ ចំណោលប្រជាសាស្ត្រតាមក្រុមអាយុ (០៥ឆ្នាំ) 49
តារាង 32៖ តម្រូវការដីសម្រាប់លំនៅឋានក្នុងឆ្នាំ២០៣២ 50
តារាង 33៖ តម្រូវការដីសម្រាប់កសិកម្មក្នុងឆ្នាំ២០៣២ 51
តារាង 34៖ កំណើនកុមារ  តម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១៨ ដល់ឆ្នាំ ២០៣២ 53
តារាង 35៖ បញ្ហាប្រឈម (ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ) 59
តារាង 36៖ តារាងប្រើប្រាស់ដីនាពេលអនាគត 64
តារាង 37៖ តារាងផែនការផ្នែកហេដ្ឋារចនាសម្ព័ន្ធនាពេលអនាគត 65
តារាង 38៖ តារាងផែនការផ្នែកសេវាកម្មនាពេលអនាគត 65

## បញ្ជីដ្យាក្រាម

ដ្យាក្រាម 1៖ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្តាភូមិ 6
ដ្យាក្រាម 2៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព 18
ដ្យាក្រាម 3៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ 26

## បញ្ជីផែនទី

ផែនទី 1៖ ទីតាំងឃុំកំពង់គោ ស្រុកកំពង់ស្វាយ ..... 4
ផែនទី 2៖ ព្រំប្រទល់រដ្ឋបាលឃុំកំពង់គោ ..... 4
ផែនទី 3៖ ផែនទីរយៈកម្ពស់ឃុំកំពង់គោ ..... 21
ផែនទី 4៖ តំបន់វិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំកំពង់គោ ..... 22
ផែនទី 5៖ ប្រព័ន្ធធារាសាស្ត្រឃុំកំពង់គោ ..... 25
ផែនទី 6៖ ហេដ្ឋារចនាសម្ព័ន្ធឃុំកំពង់គោ ..... 28
ផែនទី 7៖ ផែនទីប្រើប្រាស់ដីសាមញ្ញ ..... 30
ផែនទី 8៖ ផែនទីប្រើប្រាស់ដីលម្អិត ..... 31
ផែនទី 9៖ ផែនទីគម្រោងវិនិយោគជាអាទិ៍ភាពឃុំកំពង់គោ ..... 48
ផែនទី 10៖ តំបន់រសើបឃុំកំពង់គោ ..... 56
ផែនទី 11៖ បញ្ហា មូលហេតុ និងដំណោះស្រាយ ..... 61
ផែនទី 12៖ ផែនទីប្រើប្រាស់ដីអនាគត ឃុំកំពង់គោ ..... 67

## បញ្ជីរូបភាព

រូបភាព 1៖ សាលារៀន ..... 14
រូបភាព 2 ៖ មណ្ឌលសុខភាពកំពង់គោ ..... 18
រូបភាព 3៖ ប្រព័ន្ធធារាសាស្ត្រ ..... 25
រូបភាព 4៖ ប្រព័ន្ធគមនាគមន៍ ..... 27
រូបភាព 5៖ លំនៅឋានភូមិក្នុងតំបន់២ជុំវិញបឹងទន្លេសាប ..... 33
រូបភាព 6៖ ស្រូវប្រាំង ..... 34
រូបភាព 7៖ ព្រៃតាមដងស្ទឹង ..... 35
រូបភាព 8៖ ព្រៃលិចទឹក ..... 35
រូបភាព 9 ៖ បឹងធម្មជាតិ ..... 36
រូបភាព 10៖ ទិដ្ឋភាពស្ទឹងសែន ..... 36
រូបភាព 11៖ អាងស្តុកទឹក ..... 37
រូបភាព 12៖ ស្រះទឹក ..... 37
រូបភាព 13៖ ទិដ្ឋភាពលក់ផលិតផលស្រូវនៅក្នុងឃុំ ..... 42

# អារម្ភកថា

ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ គឺ ជាឧបករណ៍មួយដ៏សំខាន់ក្នុងការជួយទៅដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ផ្ទាល់ ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការរួមចំណែកដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងសមធម៌ ជាពិសេសការគ្រប់គ្រងនិងប្រើប្រាស់ដី ដែលជាកត្តាស្នូលនៃការអភិវឌ្ឍសេដ្ឋកិច្ច និងលើកស្ទួយដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ដូច្នេះក្រោយពេលមានផែនការប្រើប្រាស់ដីនេះអាជ្ញាធរគ្រប់ផ្នែកនៅថ្នាក់ក្រោមជាតិ ជាពិសេសអាជ្ញាធរដែនដី នឹងមានមូលដ្ឋានកាន់តែគ្រប់ជ្រុងជ្រោយ ក្នុងការរៀបចំបញ្ចូលផែនការប្រើប្រាស់នៅក្នុងឃុំ/សង្កាត់នេះ ទៅក្នុងផែនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចនៅថ្នាក់មូលដ្ឋាន ដោយធ្វើសមាហរណកម្មផែនការនៅថ្នាក់ស្រុក និងការអនុម័តនៅថ្នាក់រាជធានី/ខេត្តទៅតាមនីតិវិធី ដូចដែលធ្លាប់អនុវត្តក្នុងការកសាងផែនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចកន្លងមក ដោយមានគ្រប់ភាគីពាក់ព័ន្ធទាំងអស់ចូលរួមធ្វើការសម្រេច។ នៅក្នុងទឹកចិត្តសោមនស្សរីករាយជាអនេក ខ្ញុំមានកិត្តិយសសូមធ្វើការបង្ហាញនូវរបាយការណ៍បច្ចេកទេសស្តីពីផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់គោ មានចក្ខុវិស័យរហូតដល់ឆ្នាំ ២០៣២ ដែលក្រុមការងារបានប្រឹងប្រែងសិក្សាស្រាវជ្រាវ និងរៀបចំឡើងអស់រយៈពេលជាងពីរឆ្នាំកន្លងមកនេះ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ធនាគារអភិវឌ្ឍអាស៊ី (ADB) និងកម្មវិធីកសិកម្ម និងសន្តិសុខស្បៀងពិភពលោក (GAFSP) ដែលបានគាំទ្រឧបត្ថម្ភថវិកា ក្រុមហ៊ុនផ្តល់សេវាកម្មមកជួយសិក្សារៀបចំផែនការនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលទទួលគ្រប់គ្រងគម្រោង និងគាំទ្របច្ចេកទេស រដ្ឋបាលខេត្តកំពង់ធំ និងរដ្ឋបាលស្រុកកំពង់ស្វាយ ដែលបានជួយសម្របសម្រួលដល់កិច្ចដំណើរការរបស់គម្រោង និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមនៅក្នុងដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់គោនេះ។ ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់គោនេះ នឹងបានចូលរួមចំណែកទៅដល់ការអភិវឌ្ឍឃុំប្រកបដោយចីរភាព ថែមទាំងត្រូវបានប្រើប្រាស់ដោយមានការចូលរួម និងគាំទ្រយ៉ាងពេញទំហឹងពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់។៚

ថ្ងៃ ពុធ ៥កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

កំពង់គោ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០២០

**ប្រធានក្រុមប្រឹក្សាឃុំ និងជា**

**មេឃុំកំពង់គោ**

ស្រី ណារាល់

# សេចក្តីផ្តើម

ស្ថិតនៅក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ដោយឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញ និងច្បាប់ រាជរដ្ឋាភិបាល ដែលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាល បានបន្តធ្វើការជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ នៅក្នុងគោលដៅបង្កើន និងកែលម្អការផ្តល់គុណភាពសេវាសាធារណៈប្រកបទៅដោយគុណភាព ប្រសិទ្ធិភាព និងស័ក្តិសិទ្ធិភាព។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលកម្ពុជា នៅក្រោមការដឹកនាំប្រកបទៅដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដាក់ចេញនូវគោលនយោបាយជាតិ ស្តីពីការរៀបចំដែនដី នៃព្រះរាជាណាចក្រកម្ពុជាសំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍតាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាន ឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។

ឃុំកំពង់គោ ជាឃុំមួយនៅក្នុងចំណោមឃុំទាំង ១១ ដែលស្ថិតនៅក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ មានតំបន់លំនៅឋាន និងតំបន់កសិកម្ម ដែលមានផ្ទៃដីសរុបចំនួន ២៨ ១៩២,៤៨ ហិកតា មានព្រំប្រទល់ខាងជើងជាប់នឹងឃុំត្បែង ឃុំសាន់គ ស្រុកកំពង់ស្វាយ និងឃុំចំណាក្រោម ស្រុកស្ទោង ខាងត្បូងជាប់នឹងឃុំផ្លូវទូក និងឃុំច្រណូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ខាងកើតជាប់សង្កាត់អូរកន្ធរ សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន និងឃុំត្រពាំងឫស្សី ឃុំក្ដីដូង ស្រុកកំពង់ស្វាយ និងខាងលិចជាប់នឹងឃុំផាត់សណ្តាយ ស្រុកស្ទោង មានប្រជាជនសរុបចំនួន ៧ ៦៥៦ នាក់ នៅក្នុងនោះមានស្ត្រីចំនួន ៣ ៩២១ នាក់ ហើយមានប្រជាពលរដ្ឋ ៩៨% ជាកសិករ។ ឃុំកំពង់គោ មានទំហំផ្ទៃដីស្រែសរុបចំនួន ១៥ ២៨០,០៤ ហិកតា គឺជាផ្ទៃដីដែលមានទំហំធំទូលាយមានវិសាលភាពស្រូបអស់ ៥៤,២០ % នៃផ្ទៃដីសរុបរបស់ឃុំ ដែលជាបង្អែកដ៏មានសក្តានុពលតែមួយគត់ សម្រាប់ការអភិវឌ្ឍន៍ឃុំកំពង់គោ ប្រកបដោយចីរភាព។

ក្នុងគោលដៅធានាការគ្រប់គ្រងនិងអភិវឌ្ឍឃុំកំពង់គោ ប្រកបទៅដោយចីរភាពនេះគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ និងស្រុកកំពង់ស្វាយ ព្រមទាំងក្រុមប្រឹក្សាឃុំកំពង់គោ នៅក្រោមការទទួលសិទ្ធិផ្តល់សេវាកម្មរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់គោ ដោយក្រុមហ៊ុន SBK Co.LTd និងមានការគ្រប់គ្រងគាំទ្របច្ចេកទេសដោយអង្គភាពអនុវត្តគម្រោងថ្នាក់ខេត្ត(PIO) និងអង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ(NIO) នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងគាំទ្រ និងឧបត្ថម្ភថវិកាពីរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍអាស៊ី បានរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់គោ ដែលមានចក្ខុវិស័យដល់ឆ្នាំ ២០៣២ សម្រាប់តម្រង់ទិសនៃការអភិវឌ្ឍឃុំពាក់ព័ន្ធនឹងការប្រើប្រាស់ដីនៅក្នុងឃុំកំពង់គោ ឆ្លើយតបនឹងកំណើនប្រជាសាស្ត្រ ដើម្បីជាមូលដ្ឋានជួយទៅដល់ក្រុមប្រឹក្សាឃុំកំពង់គោផ្ទាល់ ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការរួមចំណែកដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងសមធម៌ នៅក្នុងនោះមានការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដែលជាកត្តាស្នូលនៃការអភិវឌ្ឍឃុំ ធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានភាពប្រសើរឡើងរួចផុតពីភាពក្រីក្រ ជាពិសេស គឺការប្រើប្រាស់ដីកសិកម្មនៅក្នុងឃុំកំពង់គោឱ្យអស់ពីសក្តានុពលដែលមានក្នុងការផលិតស្រូវ ដើម្បីបង្កើនការនាំចេញអង្ករឱ្យបានច្រើន នាពេលខាងមុខ ឆ្លើយតបបានទៅនឹងគោលនយោបាយ ស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្កររបស់រាជរដ្ឋាភិបាល ដែលនៅសល់ពីការហូបចុក តាមរយៈការប្រើប្រាស់ផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់គោនេះ ធ្វើជាមូលដ្ឋានបង្អែកសម្រាប់រៀបចំផែនការអភិវឌ្ឍសង្កាត់នៅតាមអណត្តិនីមួយៗរបស់ខ្លួន។

ផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់គោត្រូវបានធ្វើការរៀបចំឡើងដោយមានការសិក្សាស្រាវជ្រាវច្បាស់លាស់ទៅលើកត្តាភូមិសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថាន ព្រមទាំងគោលនយោបាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានជាអាទិ៍ ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី នគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ និងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។ ចំពោះនីតិវិធីនៃការរៀបចំផែនការនេះវិញ ត្រូវបានរៀបចំឡើងដោយផ្អែកទៅលើអនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ ព្រមទាំងប្រកាសរួមស្តីពីនីតិវិធីលម្អិត សម្រាប់ការរៀបចំ និងអនុវត្តផែនការប្រើប្រាស់ដីក្នុងឃុំ/សង្កាត់ និងឯកសារណែនាំអនុវត្តស្តីពី ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ ដែលមានដំណើរការរៀបចំផែនការដូចមានសង្ខេបក្នុងដ្យាក្រាមខាងក្រោម។

ដ្យាក្រាម៖ ដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់




សម្គាល់៖ ប្រអប់បង្ហាញទំហំការងារដែលត្រូវអនុវត្តតាមឯកសារណែនាំ

# ជំពូក១៖ ព័ត៌មានស្តីពីស្ថានភាពឃុំកំពង់គោ

## ១.១.ស្ថានភាពឃុំ

ឃុំកំពង់គោ កាលដើមឡើយ ជាតំបន់ព្រៃរនាមបឹងទន្លេសាប លិចទឹកនៅរដូវវស្សា ម្យ៉ាងទៀតតំបន់នេះ មានស្ទឹងសែនហូរកាត់ចេញពីភាគខាងត្បូងឆៀងខាលិចឆ្ពោះទៅភាគខាងជើងឆៀងខាងកើត។ នៅក្នុងតំបន់នេះ មានសត្វព្រៃជាច្រើនឆ្លងកាត់នៅក្នុងរដូវប្រាំង ដោយសត្វទាំងអស់នោះបានចុះហែលឆ្លងកាត់ស្ទឹងសែន ពីត្រើយម្ខាងទៅត្រើយម្ខាងទៀត ដើម្បីស្វែងរកអាហារ ។ នៅក្នុងចំណោមសត្វទាំងអស់នោះ ភាគច្រើនជាគោព្រៃ ដែលពួកវារស់នៅជាហ្វូងៗតែម្តង។ ដោយសារតែប្រជាពលរដ្ឋឃើញហ្វូងគោទាំងអស់នោះមានចំនួនច្រើនជាងគេនិងបានឆ្លងកាត់ស្ទឹងសែននៅត្រង់ចំណុចនោះ ពួកគាត់ក៏បានហៅតំបន់នោះថាកំពង់គោៗរហូតមក និងដាក់ឈ្មោះតំបន់នោះថាឃុំកំពង់គោរហូតរៀងមក។

### ១.១.១.ទីតាំងរដ្ឋបាលឃុំ

ឃុំកំពង់គោ គឺជាឃុំមួយនៅក្នុងចំណោមឃុំទាំង ១១ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលស្រុកកំពង់ស្វាយ មានទីតាំងស្ថិតនៅភាគខាងត្បូង និងមានចម្ងាយពីស្រុកកំពង់ស្វាយប្រមាណ ២៩ គីឡូម៉ែត្រ។ ឃុំនេះមានភូមិចំនួន៥ ដូចជា៖ ភូមិកំពង់គោលើ កំពង់គោក្រោម ខ្សាច់ជីរស់ បូពឹង និងភូមិកោះគ្របបាយ ហើយផ្ទៃដីឃុំសរុបមានចំនួន ២៨ ១៩២,៤៨ ហិកតា និងមានព្រំប្រទល់ជាប់នឹង៖

- ខាងជើង ជាប់នឹង ឃុំត្បែង ឃុំសាន់គ ស្រុកកំពង់ស្វាយ និងឃុំចំណាក្រោម ស្រុកស្ទោង
- ខាងត្បូង ជាប់នឹងឃុំផ្លូវទូក និងឃុំច្រណូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង
- ខាងកើត ជាប់នឹងសង្កាត់អូរកន្ធរ សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន និងឃុំត្រពាំងឫស្សី ឃុំក្តីដូង ស្រុកកំពង់ស្វាយ
- ខាងលិច ជាប់នឹងឃុំផាត់សណ្តាយ ស្រុកស្ទោង។

តារាង 1៖ ស្ថានភាពទូទៅនៃឃុំ

| ខេត្ត | កំពង់ធំ | លេខកូដខេត្តៈ៦ |
|---|---|---|
| ស្រុក | កំពង់ស្វាយ | លេខកូដស្រុកៈ ៦០២ |
| ឃុំ | កំពង់គោ | លេខកូដឃុំៈ ៦០២០៣ |
| ចំនួនភូមិ៥ | ១. កំពង់គោលើ | លេខកូដភូមិៈ ៦០២០៣០១ |
| | ២. កំពង់គោក្រោម | លេខកូដភូមិៈ ៦០២០៣០២ |
| | ៣. ខ្សាច់ជីរស់ | លេខកូដភូមិៈ ៦០២០៣០៣ |
| | ៤. បូពឹង | លេខកូដភូមិៈ ៦០២០៣០៤ |
| | ៥. កោះគ្របបាយ | លេខកូដភូមិៈ ៦០២០៣០៥ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់គោ ខែមេសា ឆ្នាំ២០១៨*

ផែនទី 1៖ ទីតាំងឃុំកំពង់គោ ស្រុកកំពង់ស្វាយ




ផែនទី 2៖ ព្រំប្រទល់រដ្ឋបាលឃុំកំពង់គោ



### ១.១.២.ប្រជាសាស្ត្រ

#### ក.ចំនួនប្រជាជន

នៅក្នុងរដ្ឋបាលឃុំកំពង់គោ ត្រូវបានចែកចេញជា ០៥ភូមិ ដែលមានគ្រួសារសរុបចំនួន ១ ៥៤៣ គ្រួសារ និងមានប្រជាជនសរុប ៧ ៦៥៦ នាក់ មានស្ត្រី ៣ ៩២១ នាក់ ដែលនៅក្នុងនោះដែរប្រជាជន ដែលមានអាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅ មានចំនួន ៤ ៤៤៧ នាក់ ស្រីចំនួន ២ ២៩៤ នាក់ ។ នៅក្នុងឃុំកំពង់គោ ភូមិដែលមានប្រជាពលរដ្ឋតិចជាងគេ គឺភូមិបូពឹង មានប្រជាពលរដ្ឋ ១៩២ គ្រួសារ ស្មើនឹង ១២,៤៤ ភាគរយ និងប្រជាជនសរុប ៩១៧ នាក់ មានស្រី ៤៦៨ នាក់ នៅក្នុងនោះប្រជាពលរដ្ឋមានអាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅ មានចំនួន ៤៧១នាក់ ក្នុងនោះស្ត្រីមានចំនួន ២៤០ នាក់ ចំណែកភូមិដែលមានប្រជាជនច្រើនជាងគេ គឺភូមិខ្សាច់ជីរស់ មានប្រជាពលរដ្ឋ ៥០៥ គ្រួសារ ស្មើនឹង ៣២,៧៣ ភាគរយ និងប្រជាជនសរុបចំនួន ២ ២៦២ នាក់ មានស្រីចំនួន ១ ១៧៨ នាក់ ក្នុងនោះមានមនុស្ស អាយុចាប់ពី១៨ឆ្នាំឡើងទៅចំនួន ១ ៥៥៥ នាក់ មានស្រីចំនួន ៧៩២នាក់។ ទន្ទឹមនឹងនេះ ក៏សង្កេតឃើញប្រជាជននៅក្នុងឃុំ ស្ត្រីមានចំនួនច្រើនជាងបុរស ដូចមានក្នុងតារាងដែលក្រុមការងារបានរៀបចំសង្ខេបខាងក្រោម។

តារាង 2៖ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្ដាភូមិ

| ឈ្មោះភូមិ | គ្រួសារ | គិតជា% | មនុស្ស | | | ១៨ឆ្នាំឡើង | | |
|---|---|---|---|---|---|---|---|---|
| | | | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| កំពង់គោលើ | ២៩៣ | ១៨៩៩ | ១៦៧៩ | ៨០១ | ៨៧៨ | ៩៣២ | ៤២៩ | ៥០៣ |
| កំពង់គោក្រោម | ២៥៥ | ១៦៥៣ | ១៣២២ | ៦១២ | ៧១០ | ៦១៥ | ២៧០ | ៣៤៥ |
| ខ្សាច់ជីរស់ | ៥០៥ | ៣២៧៣ | ២២៦២ | ១០៨៤ | ១១៧៨ | ១៥៥៥ | ៧៦៣ | ៧៩២ |
| បូពឹង | ១៩២ | ១២៤៤ | ៩១៧ | ៤៤៩ | ៤៦៨ | ៤៧១ | ២៣១ | ២៤០ |
| កោះគ្របបាយ | ២៩៨ | ១៩៣១ | ១៤៧៦ | ៧៨៩ | ៦៨៧ | ៨៧៤ | ៤៦០ | ៤១៤ |
| **សរុប** | **១៥៤៣** | **១០០** | **៧៦៥៦** | **៣៧៣៥** | **៣៩២១** | **៤៤៤៧** | **២១៥៣** | **២២៩៤** |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់គោ ខែមេសា ឆ្នាំ២០១៨*

ដ្យាក្រាម 1៖ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្ដាភូមិ




*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់គោ ខែមេសា ឆ្នាំ២០១៨*

បើយោងទៅតាមតារាងស្ថិតិប្រជាជនតាមក្រុមអាយុនៅឆ្នាំ ២០១៧ នៅក្នុងឃុំកំពង់គោ បានបង្ហាញឱ្យឃើញថាប្រជាជនពេញកម្លាំងពលកម្ម ដែលមានអាយុចាប់ពី ២៥ ឆ្នាំ ទៅដល់ ៦០ ឆ្នាំ មានចំនួន ២ ៩១៧ នាក់ ស្មើប្រហាក់ប្រហែល ៣៨ ភាគរយ នៃប្រជាជនសរុប គឺលើស ១/៣ បន្តិច ក្រៅពីនេះមានអាយុចាប់ពីកើតដល់ ២៤ ឆ្នាំ មានចំនួន ៤ ០៦១ នាក់ ស្មើប្រហាក់ប្រហែលនឹង ៥៣ ភាគរយ នៃប្រជាជនសរុប និងប្រជាជនមានអាយុចាប់ពី ៦១ ឆ្នាំ ឡើងទៅ ដែលជាអ្នកបានចូលនិវត្តន៍បាត់បង់សមត្ថភាពការងារមានចំនួន ៦៧៨ នាក់ ស្មើប្រហាក់ប្រហែល ៩ភាគរយ នៃប្រជាជនសរុប ។ ដូច្នេះសន្និដ្ឋានបានថា នៅក្នុងឃុំកំពង់គោ មនុស្សពេញកម្លាំងពលកម្មមួយនាក់រកចំណូលបានគិតជាមធ្យមត្រូវចិញ្ចឹមមនុស្សជិតពីរនាក់បន្ថែម ។

តារាង 3៖ ស្ថិតិប្រជាជន ឆ្នាំ២០១៧ តាមក្រុមអាយុ

| ប្រជាជនតាមក្រុមអាយុ | ២០១៧ | | | ផ្សេងៗ |
|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | |
| អាយុពី០-២ឆ្នាំ | ៣៤៩ | ១៨៦ | ១៦៣ | កុមារ |
| អាយុពី៣-៤ | ៣៥២ | ១៦២ | ១៩០ | អាយុចូលរៀនសាលាមត្តេយ្យ |
| អាយុពី៥ឆ្នាំ | ៣៦២ | ១៧៨ | ១៨៤ | អាយុចូលរៀនសាលាមត្តេយ្យ |
| អាយុពី៦ឆ្នាំ | ៣៤២ | ១៥៨ | ១៨៤ | អាយុចូលរៀនសាលាបឋម |
| អាយុពី៧-១១ឆ្នាំ | ៥៩៦ | ២៧៣ | ៣២៣ | អាយុចូលរៀនសាលាបឋម |
| អាយុពី១២-១៤ឆ្នាំ | ៦៩៥ | ៣៦៦ | ៣២៩ | អាយុចូលរៀនអនុវិទ្យាល័យ |
| អាយុពី១៥-១៧ឆ្នាំ | ៥១៣ | ២៥៩ | ២៥៤ | អាយុចូលរៀនវិទ្យាល័យ |
| អាយុពី១៨-២៤ឆ្នាំ | ៨៥២ | ៤០២ | ៤៥០ | អាយុចូលរៀនមហាវិទ្យាល័យ |
| អាយុពី២៥-៣៥ឆ្នាំ | ១១១៧ | ៤៧២ | ៦៤៥ | អាយុពេញពលកម្ម |
| អាយុពី៣៦-៤៥ឆ្នាំ | ៩៤៤ | ៤៩៣ | ៤៥១ | អាយុពេញពលកម្ម |
| អាយុពី៤៦-៦០ឆ្នាំ | ៨៥៦ | ៣៩៩ | ៤៥៧ | អាយុពេញពលកម្ម |
| អាយុពី៦១ឆ្នាំឡើង | ៦៧៨ | ៣៨៧ | ២៩១ | អាយុចូលនិវត្តន៍ |
| **សរុប** | **៧៦៥៦** | **៣៧៣៥** | **៣៩២១** | |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់គោ ខែមេសា ឆ្នាំ២០១៨*

### ខ.អត្រាកំណើន ដង់ស៊ីតេ និងរបាយប្រជាជន

ដោយយោងតាម CDB ឆ្នាំ២០១៧ បានឱ្យដឹងថា អត្រាកំណើនប្រជាជនជាមធ្យមក្នុងអំឡុងពេលចន្លោះពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៧ មានចំនួន ១,២១ ភាគរយ ដោយសង្កេតឃើញថា មានការធ្លាក់ចុះខ្លាំងនៅឆ្នាំ ២០១៥ គឺមានអត្រាកំណើនប្រជាជនចំនួន -១១,៥៩ ភាគរយ ការធ្លាក់ចុះនេះ ដោយសារតែមានការផ្លាស់ប្តូរលំនៅឋានចេញ ចំណាកស្រុក ការពន្យាកំណើត មរណភាពកុមារ និងដោយសារកត្តាគ្រោះថ្នាក់ចរាចរណ៍ ជម្ងឺ។ល។ ប៉ុន្តែអត្រាកំណើននៅឆ្នាំ ២០១៤ មានការកើនឡើងខ្លាំងជាងគេ គឺមានចំនួន ១២ ភាគរយ ដោយសារតែមានការផ្លាស់ប្តូរទីលំនៅចូលតាមរយៈ អាពាហ៍ពិពាហ៍ និងកើតថ្មី។ តែបើពិនិត្យទៅលើជំរឿនទូទៅប្រជាជនឆ្នាំ ២០១៩ បានឱ្យដឹងថា អត្រាកំណើនជាមធ្យមក្នុងអំឡុង ១០ឆ្នាំ (២០០៨-២០១៨) នៅខេត្តកំពង់ធំមាន ០,៦ ភាគរយ ប្រហាក់ប្រហែលអត្រាកំណើនខាងលើដែរ។ ដូច្នេះ យើងបានកំណត់យកអត្រាកំណើនប្រជាជនជាមធ្យមប្រចាំឆ្នាំ នៅក្នុងឃុំកំពង់គោ ១,២១ ភាគរយ ជាបានការដើម្បីប្រើប្រាស់ក្នុងការព្យាករណ៍កំណើនប្រជាជនក្នុងឃុំ ។

នៅក្នុងឃុំកំពង់គោ នៅក្នុងឆ្នាំ ២០១៧ មានដង់ស៊ីតេប្រជាជនរស់នៅ ២៦,៦ នាក់/គម² ដោយការរស់នៅរបស់ប្រជាពលរដ្ឋភាគច្រើនតាំងលំនៅឋានជាលក្ខណៈរាយប៉ាយតាមភូមិ នៅតាមដងផ្លូវសំខាន់ៗនៅក្នុងឃុំ។

តារាង 4៖ ស្ថិតិប្រជាជនតាមបណ្តាឆ្នាំ និងការគណនាអត្រាកំណើនមធ្យម

| ចំនួន | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | កំណើនមធ្យម% |
|---|---|---|---|---|---|---|---|
| ចំនួនប្រជាជនសរុប | ៧៣១១ | ៧៤៣១ | ៨៣៣៤ | ៧៣៦៨ | ៧៥០៨ | ៧៦៥៦ | |
| កំណើនមធ្យម(%) | | ១,៦៤ | ១២,១៥ | -១១,៥៩ | ១,៩០ | ១,៩៧ | ១,២១ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់គោ ខែមេសា ឆ្នាំ២០១៨*

**<u>ចំណាំ</u>**

- អត្រាកំណើនសម្រាប់ចន្លោះឆ្នាំនីមួយៗ៖ (ឆ្នាំចុងក្រោយ-ឆ្នាំដំបូង)x១០០/ឆ្នាំដំបូង
- អត្រាកំណើនមធ្យមប្រចាំឆ្នាំ៖ (បូកសរុបអត្រាកំណើនតាមឆ្នាំនីមួយ/ចំនួនឆ្នាំ)

### គ.ជនជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់

នៅក្នុងឃុំកំពង់គោមានជនជាតិខ្មែរ និងខ្មែរកាត់ចិន ហើយភាគច្រើនកាន់សាសនាព្រះពុទ្ធ និងចំនួនតិចតួចកាន់សាសនាគ្រិស្ត ហើយប្រជាជនភាគច្រើននៅក្នុងឃុំគោរពប្រពៃណី និងទំនៀមទម្លាប់បែបខ្មែរ ដូចជាពិធីរៀបមង្គល ការប្រារព្ធពីធីបុណ្យទាននៅតាមវត្តអារាម និងតាមផ្ទះ និមន្តព្រះសង្ឃសូត្រមន្តតាមផ្ទះ ពិធីបូជាសព និងមួយចំនួនតិចមានទំនៀមទម្លាប់បែបចិន ដូចជា ពិធីសែនព្រេនដូនតា និងពីធីបញ្ចុះសព ព្រមទាំងភាគតិចបំផុតមានទំនៀមទម្លាប់បែបសាសនាគ្រិស្ត ដូចជា ការប្រារព្ធពិធីចូលព្រះវិហារគ្រិស្តនៅរៀងរាល់ថ្ងៃអាទិត្យជាដើម។ និយាយរួមប្រជាជននៅក្នុងឃុំកំពង់គោ តែងតែប្រារព្ធពិធីបុណ្យទានទៅតាមប្រពៃណីទំនៀមទំលាប់ពីបុរាណរៀងមក តាមជំនឿបែបខ្មែរ បែបចិន និងបែបគ្រិស្តសាសនា។

### ឃ.របររកទទួលទាន

យោងទៅតាមទិន្នន័យពីមន្ទីរផែនការនៅឆ្នាំ ២០១៧ នៅក្នុងតារាងខាងក្រោម បានបង្ហាញឱ្យឃើញថា នៅក្នុងឃុំកំពង់គោ អ្នកមានមុខរបរចម្បងចំនួន ៣ ៣៣១នាក់ ស្មើនឹង ៨៨,៤ ភាគរយ នៅក្នុងនោះប្រជាពលរដ្ឋភាគច្រើនប្រកបមុខរបរកសិកម្ម ជាចម្បងដែលមានចំនួន ២ ៨៨៥ នាក់ ស្មើនឹង ៨៦,៦ ភាគរយ អ្នកប្រកបមុខរបរសិប្បកម្មមិនមាននៅក្នុងឃុំនោះទេ និងអ្នកប្រកបមុខរបរសេវាកម្មមាន ៤៤៦ នាក់ ស្មើនឹង ១៣,៤ ភាគរយ មុខរបរទាំងអស់នោះមានដូចជា៖ នេសាទត្រី ធ្វើស្រែ ចិញ្ចឹមសត្វ ដាំដំណាំបន្លែ កម្មករសំណង់ ស៊ីឈ្នួលដកស្ទូងតិចតួច ហាលស្រូវ លើកស្រូវ លីស្រូវ លក់ដូរ ជាងជួសជុលកង់ម៉ូតូ ជាងកាត់សក់ ជាមន្ត្រីរាជការ អាជីវករលក់ដូរធ្វើការជាមួយវិស័យឯកជន និងអង្គការនានា ហើយភាគច្រើនធ្វើការមានជំនាញច្បាស់លាស់។

តារាង 5៖ តារាងមុខរបរ

| បរិយាយ | ២០១៧ |
|---|---|
| សរុបអ្នកមានមុខរបរចម្បង | ៣៣៣១ នាក់ |
| %សរុបអ្នកមានមុខរបរចម្បង | ៨៨,៤ |
| %ស្រីមានមុខរបរចម្បង(គិតក្នុងស្រី១៨-៦០ឆ្នាំ) | ៦៩,៤ |
| %ប្រុសមានមុខរបរចម្បង(គិតក្នុងប្រុស១៨-៦០ឆ្នាំ) | ៨០,៨ |
| **សរុបអ្នកមានមុខរបរចម្បងក្នុងផ្នែកកសិកម្ម** | **២៨៨៥ នាក់** |

| បរិយាយ | | ២០១៧ |
|---|---|---|
| **%អ្នកមានមុខរបរចម្បងផ្នែកកសិកម្ម( គិតក្នុងមុខរបរចម្បង )** | | **៨៦,៦ %** |
| **%ស្រីមានមុខរបរចម្បងផ្នែកកសិកម្ម( គិតក្នុងមុខរបរចម្បង )** | | **៤០,៣ %** |
| ក្នុងនោះ | %អ្នកមានមុខរបរធ្វើស្រែ | ៧០,៥ % |
| | %អ្នកមានមុខរបរដាំដំណាំចម្ការរយៈពេលវែង | ០ |
| | %អ្នកមានមុខរបរដាំដំណាំចម្ការរយៈពេលខ្លី | ០,៨ % |
| | %អ្នកមានមុខរបរដាំដំណាំបន្លែ | ១,៤ % |
| | %អ្នកមានមុខរបរនេសាទ | ១១,៧ % |
| | %អ្នកមានមុខរបរចិញ្ចឹមសត្វ | ២,៣ % |
| | %អ្នកមានមុខរបរពីអនុផលព្រៃឈើ | ០,០ |
| **សរុបអ្នកបម្រើការងារ( មុខរបរចម្បង ) ក្នុងផ្នែកសិប្បកម្ម** | | **០,០** |
| **%អ្នកបម្រើការងារក្នុងផ្នែកសិប្បកម្ម** | | **០,០** |
| **%ស្រីបម្រើការងារក្នុងផ្នែកសិប្បកម្ម** | | **០,០** |
| ក្នុងនោះ | %អ្នកបម្រើការងារសិប្បកម្មត្បាញរវៃ | ០,០ |
| | %អ្នកបម្រើការងារសិប្បកម្មផលិតពីផ្តៅ វល្លិ ល្ពាក់... | ០,០ |
| | %អ្នកបម្រើការងារសិប្បកម្មផលិតគ្រឿងសង្ហារឹម | ០,០ |
| | %អ្នកបម្រើការងារសិប្បកម្មចម្លាក់ធ្វើពីឈើ ថ្ម ស្ពាន់... | ០,០ |
| | %អ្នកបម្រើការងារសិប្បកម្មផលិតពីដែក អាលុយមីញ៉ូម | ០,០ |
| | %អ្នកបម្រើការងារសិប្បកម្មផលិតពីជ័រ ផ្លាស្ទិក ... | ០,០ |
| | %អ្នកបម្រើការងារសិប្បកម្មកែច្នៃឬវេចខ្ចប់គ្រាប់ធញ្ញជាតិ | ០,០ |
| | %អ្នកបម្រើការងារសិប្បកម្មផលិតផ្សេងៗ | ០,០ |
| **សរុបអ្នកបម្រើការងារ( មុខរបរចម្បង ) ក្នុងផ្នែកសេវាកម្ម** | | ៤៤៦ នាក់ |
| **%អ្នកបម្រើការងារ( មុខរបរចម្បង ) ក្នុងផ្នែកសេវាកម្ម** | | ១៣,៤ % |
| **%ស្រីបម្រើការងារ( មុខរបរចម្បង ) ក្នុងផ្នែកសេវាកម្ម** | | ៧,៥ % |
| ក្នុងនោះ | %អ្នកបម្រើការងារលក់ដូរ និងជំនួញ | ១,៤ % |
| | %អ្នកបម្រើការងារជាជាងជួសជុល | ១,៧ % |
| | %អ្នកបម្រើការងារក្នុងផ្នែកដឹកជញ្ជូន | ២,២ % |
| | %អ្នកបម្រើការងារស៊ីឈ្នួលក្នុងវិស័យកសិកម្ម កម្មករសំណង់ | ២,៥ % |
| | %អ្នកបម្រើការងារក្នុងវិស័យឯកជន( កម្មកររោងចក្រ បុគ្គលិក អង្គការ ) | ៤,២ % |
| | %អ្នកបម្រើការងារជាមន្ត្រីរាជការ | ១,៥ % |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់គោ ខែមេសា ឆ្នាំ២០១៨*

ប្រជាពលរដ្ឋនៅក្នុងឃុំកំពង់គោ ពួកគាត់បានបង្កើតមុខរបរបន្ទាប់បន្សំបន្ថែមទៀត ក្រៅពីមុខរបរចម្បងដើម្បីទ្រទ្រង់ជីវភាពក្នុងគ្រួសារឱ្យកាន់តែប្រសើរឡើង។ យោងទៅតាមទិន្នន័យពីមន្ទីរផែនការឆ្នាំ ២០១៧ បានបង្ហាញឱ្យឃើញថា ប្រជាជនដែលមានមុខរបរបន្ទាប់បន្សំផ្នែកកសិកម្មចំនួន ២០៣១ នាក់ ស្មើនឹង ៧៦,៦ ភាគរយ

ក្នុងនោះមានស្ត្រីចំនួន ៨៦៨ នាក់ ស្មើនឹង ៣២,៧ ភាគរយ និងអ្នកដែលមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម មានចំនួន៤៧៥ នាក់ ស្មើនឹង ២៣,៤ ភាគរយ មានស្រី ២៧៩ នាក់ ស្មើនឹង ១០,៥ ភាគរយ ហើយចំណែកអ្នកប្រកបមុខរបរសិប្បកម្មមិនមាននៅក្នុងឃុំនេះនោះទេ។

ដូច្នេះតាមព័ត៌មានខាងលើបានបង្ហាញឱ្យឃើញថា ប្រជាពលរដ្ឋក្នុងឃុំកំពង់គោក្រៅពីប្រកបរបរធ្វើស្រែជាចម្បង មានមួយចំនួនប្រមាណជិតពាក់កណ្តាលបានខិតខំប្រកបរបរទទួលទានបន្ទាប់បន្សំថែមទៀត ដូចជាលក់ដូរនិងជំនួញ ផ្នែកដឹកជញ្ជូន និងកម្មករសំណង់ ។ល។ ចំណែកអ្នកដែលមានរបរផ្នែកសេវាកម្មជាចម្បងមានស្ទើរតែទាំងអស់បានខិតខំប្រកបរបរកសិកម្មដែលជាមុខរបរបន្ទាប់បន្សំបន្ថែមទៀតផងដែរ ដូចមានរៀបរាប់ក្នុងតារាងខាងក្រោមនេះ៖

តារាង 6៖ តារាងមុខរបរបន្ទាប់បន្សំ

| បរិយាយ | ២០១៧ | ២០១៧ចំនួន(នាក់) |
|---|---|---|
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកកសិកម្ម | ៧៦,៦ % | ២០៣១ នាក់ |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកកសិកម្ម | ៣២,៧ % | ៨៦៨ នាក់ |
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសិប្បកម្ម | 0 | 0 |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកសិប្បកម្ម | 0 | 0 |
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម | ២៣,៤ % | ៤៧៥ នាក់ |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម | ១០,៥ % | ២៧៩ នាក់ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់គោ ខែមេសា ឆ្នាំ២០១៨*

### ង.ចំណូលស្រុក និងចំណាកស្រុក

កត្តាដែលធ្វើឱ្យមានការផ្លាស់ប្តូរលំនៅឋាន គឺដោយសារនៅភូមិចាស់ដែលគាត់បានរស់នៅពិបាកក្នុងការរកស៊ី និងគ្មានការងារធ្វើនៅក្នុងភូមិ ព្រមទាំងមូលហេតុមួយចំនួនទៀត ដូចជា៖ ស្ថានភាពដី នៅក្នុងតំបន់មូលដ្ឋានមួយចំនួនមានការប្រែប្រួលដោយសារដីខូច ងាប់សារធាតុបម្រុង ហើយឡើងខ្សោះ ឬហឹរជាដើម ខ្វះប្រភពទឹក ធ្វើឱ្យទទួលបានទិន្នផលទាប តម្លៃផលិតផលកសិកម្មមិនទៀងទាត់ និងគ្មានទីផ្សារផលិតផល ចំណែកសមាជិកក្នុងគ្រួសារកើនឡើង និងមួយចំនួនជាប់បំណុលធនាគារ និងមីក្រូហិរញ្ញវត្ថុជាដើម ។ ការផ្លាស់ប្តូរលំនៅឋានរបស់ប្រជាជនមួយចំនួនទៅរស់នៅទីប្រជុំជនឃុំ/សង្កាត់ ស្រុក/ក្រុង ខេត្ត/រាជធានី និងទៅធ្វើការងារនៅប្រទេសផ្សេងៗ។ មូលហេតុចម្បងនៃការធ្វើចំណាកស្រុកគ្រប់ប្រភេទ គឺនៅក្នុងគោលបំណងលើកស្ទួយជីវភាពគ្រួសារ។ បើយោងតាមទិន្នន័យក្រុមប្រឹក្សាឃុំឆ្នាំ ២០១៨ ចំនួនគ្រួសារផ្លាស់លំនៅឋានចូលមាន ១២ គ្រួសារ មានមនុស្សសរុប ៤៦ នាក់ ហើយនៅក្នុងនោះមានស្រីចំនួន ២៣ នាក់ និងគ្រួសារផ្លាស់លំនៅឋានចេញមានចំនួន ០៥ គ្រួសារ មនុស្សសរុប ២០ នាក់ ក្នុងស្រី ១៣នាក់។

តារាង 7៖ ស្ថិតិប្រជាជនផ្លាស់ប្តូរទីលំនៅក្នុងឆ្នាំ២០១៦-២០១៧

| ល.រ | បរិយាយ | ចំនួនគ្រួសារ | ចំនួនប្រជាជនសរុប ២០១៧ | |
|---|---|---|---|---|
| | | | សរុប | ស្រី |
| ១ | ចំនួនគ្រួសារផ្លាស់លំនៅឋានចូល | ១២ | ៤៦ | ២៣ |
| ២ | ចំនួនគ្រួសារផ្លាស់លំនៅឋានចេញ | ០៥ | ២០ | ១៣ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់គោ ខែមេសា ឆ្នាំ២០១៨*

ដោយយោងទៅតាមទិន្នន័យពីមន្ទីរផែនការនៅឆ្នាំ២០១៧ បានបង្ហាញថា ប្រជាជនធ្វើការចំណាកស្រុកទូទាំងឃុំមានចំនួន ៧៨០ នាក់ និងមានស្រីចំនួន ៣៩៨ នាក់ នៅក្នុងនោះដែរ អ្នកធ្វើចំណាកស្រុកក្នុងប្រទេសមានចំនួន ៦១២ នាក់ ស្រីចំនួន ៣៣៥ នាក់ ដោយពួកគាត់ទៅធ្វើការនៅ ស្រុក ខេត្តផ្សេង ឬរាជធានីភ្នំពេញតែមួយរយៈប៉ុណ្ណោះ ក្រោយមកពួកគាត់តែងតែវិលត្រលប់មកស្រុកជារឿយៗដែលជាចំណាកស្រុកមិនអចិន្ត្រៃយ៍។ ចំណែកអ្នកចំណាកស្រុកក្រៅប្រទេសមានចំនួន ១៦៨ នាក់ មានស្រី ៦៣ នាក់ ពួកគាត់ទៅប្រទេសថៃ ម៉ាឡេស៊ី ជប៉ុន និងប្រទេសកូរ៉េជាដើម ដោយពួកគាត់ទៅធ្វើការនៅទីនោះ តែមួយរយៈប៉ុណ្ណោះនិងត្រលប់មកស្រុកកំណើតវិញ បន្ទាប់ពីចប់កុងត្រាការងារ។ ប្រជាពលរដ្ឋដែលធ្វើចំណាកស្រុកទៅរកស៊ីនៅស្រុក ខេត្ត និងទៅប្រទេសជិតខាង ដោយសារកត្តាមួយចំនួដូចខាងក្រោមៈ

- ដីបង្កបង្កើនផលសម្រាប់វិស័យកសិកម្មតិចតួច ធ្វើស្រែបានផលតិច
- ការធ្វើស្រែចម្ការបានតែមួយរដូវ និងគ្មានទីផ្សារគ្រប់គ្រាន់សម្រាប់លក់ផលិតផល
- មិនមានការងារគ្រប់គ្រាន់នៅក្នុងស្រុក
- ជំពាក់បំណុលធនាគារ ឬឯកជនមិនមានលទ្ធភាពសង
- គ្មានមុខរបរច្បាស់លាស់ និងមានប្រាក់ចំណូលប្រចាំថ្ងៃទាប។
- កំណើនសមាជិកគ្រួសារមានមានការកើនឡើង។
- ដោយធ្វើស្រែប្រើឧបករណ៍ពាក់កណ្តាលស្វ័យប្រវត្តិធ្វើឱ្យកម្លាំងពលកម្មថយចុះ។
- គ្រួសារមានដីតិចតួច មិនគ្រប់គ្រាន់ក្នុងការចិញ្ចឹមគ្រួសារ បន្ទាប់មកលក់ចេញទៅស្រុកផ្សេង។

តារាង ៩៖ ស្ថិតិប្រជាជនចំណាកស្រុក

| ប្រជាជនចំណាកស្រុក | ២០១៦ | | | ២០១៧ | | |
|---|---|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| ចំនួនអ្នកធ្វើចំណាកស្រុកក្នុងប្រទេស | ៦៤០ | ២៨៦ | ៣៥៤ | ៦១២ | ២៧៧ | ៣៣៥ |
| ចំនួនអ្នកធ្វើចំណាកស្រុកក្រៅប្រទេស | ១៨៤ | ១១៤ | ៧០ | ១៦៨ | ១០៥ | ៦៣ |
| **សរុប** | **៨២៤** | **៤០០** | **៤២៤** | **៧៨០** | **៣៨២** | **៣៩៨** |

*ប្រភពៈ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់គោ ខែមេសា ឆ្នាំ២០១៨*

### ១.១.៣.ស្ថានភាពសេដ្ឋកិច្ច

#### ក.ប្រភពចំណូលចម្បង និងបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋ

បើយោងតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន នៅត្រង់ចំណុចនៃការវិភាគចំណាត់ថ្នាក់ទ្រព្យធនបានឱ្យដឹងថា គ្រួសារដែលមានជីវភាពគ្រាន់បើ មានប្រភពចំណូលទី១ លក់ស្រូវ ប្រភពចំណូលទី២ លក់ចាប់ហួយ និងប្រភពចំណូលទី៣ ជួលគ្រឿងចក្រ។ គ្រួសារមានជីវភាពមធ្យម មានប្រភពចំណូល ទី១ លក់ស្រូវ ប្រភពចំណូលទី២ ការនេសាទ។ គ្រួសារមានជីវភាពក្រ និងក្រណាស់មានប្រភពចំណូល ទី១ លក់កម្លាំងពលកម្ម និងប្រភពចំណូលទី២ ការនេសាទ ។

#### ខ.កម្រិតជីវភាពរស់នៅ ចំណូល ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ

បើយោងតាមតារាងចំណាត់ថ្នាក់ទ្រព្យធនក្នុងឆ្នាំ២០១៧ ដែលទទួលបានពីរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានខាងលើ បានបង្ហាញឱ្យឃើញថា ក្នុងឆ្នាំ ២០១៧ ប្រជាពលរដ្ឋក្នុងឃុំកំពង់គោ មានកម្រិត

ជីវភាពរស់នៅចែកចេញជាបួនកម្រិត គឺ ១)គ្រួសារបង្គួរ/គ្រាន់បើ ដែលជាគ្រួសារមានកម្រិតជីវភាពធូរធាជាងគេ មានដីលំនៅឋានកាន់កាប់ ០,២ ហិកតា និងដីស្រែ ៥០ ហិកតា ។ ២)គ្រួសារមធ្យម ជាចំនួនច្រើនជាងគេ មាន ដីលំនៅឋាន ០,២ ហិកតា និងដីស្រែចំនួន ២០ ហិកតា ៣)គ្រួសារក្រមានដីលំនៅឋានកាន់កាប់០,០២ ហិកតា និងមិនមានដីស្រែនោះទេ ៤)គ្រួសារក្រណាស់ដែលជាគ្រួសារក្រីក្របំផុត និងមានចំនួនតិចជាងគេ មានដីកាន់កាប់ពី ០,០០៦ ហិកតា ចុះក្រោមរហូតដល់អ្នកគ្មានដី។

បើយោងទៅតាមការសាកសួរក្រុមប្រឹក្សាឃុំកំពង់គោ បានបង្ហាញថា ចំណូលប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋជាមធ្យមចាប់ពី ២០ ០០០-២៥ ០០០រៀល/គ្រួសារ និងចំណូលប្រចាំឆ្នាំចាប់ពី ៧ ៣០០ ០០០-៩ ១២៥ ០០០ រៀល/គ្រួសារ ចំណែកការចំណាយប្រចាំឆ្នាំ ដែលមានដូចជា ស្បៀងអាហារ សម្លៀកបំពាក់ ឧបករណ៍ប្រើប្រាស់ សម្ភារៈសិក្សា និងថ្នាំសង្កូវ ព្រមទាំងចំណាយផ្សេងៗចាប់ពី ៥៤៧៥០០០-៧៣០០០០០រៀល/គ្រួសារ។

តារាង ១៖ តារាងកម្រិតជីវភាពរបស់ប្រជាជន

| ចំណាត់ថ្នាក់ធនធាន | បង្គួរ/គ្រាន់បើ | មធ្យម | ក្រ | ក្រណាស់/គ្មានដី | សរុប |
|---|---|---|---|---|---|
| ប្រៀបធៀបជា(%) តំបន់ទី I | ៣៥% | ៣០% | ១៥% | ២០% | ១០០% |
| តំបន់ទីII | ៦០% | ៤០% | ០% | ០% | ១០០% |
| តំបន់ទីIII | ៩០% | ១០% | ០% | ០% | ១០០% |
| ទូទាំងឃុំ | - | - | - | - | - |
| ទំហំគ្រួសារ | ៤ | ៥ | ៧ | ៩ | - |
| កម្លាំងពលកម្ម | ៣ | ៣ | ៣ | ៤ | - |
| ទំហំដីកាន់កាប់សរុប(ហ.ត) | - | - | - | - | - |
| ចំនួន និងប្រភេទក្បាលដី | - | - | - | - | - |
| ដីលំនៅឋាន(ហ.ត) | ០,២ | ០,២ | ០,០២ | ០,០០៦ | - |
| ដីស្រែ(ហ.ត) | ៥០ ហ.ត | ២០ ហ.ត | ០ | ០ | - |
| ដីផ្សេងៗទី១(ហ.ត) | - | - | - | - | - |
| ដីផ្សេងៗទី២(ហ.ត) | - | - | - | - | - |
| ប្រភេទពូជស្រូវដាំដុះ | ៥៤៥១<br>-សែនក្រអូប | ៥៤៥១<br>-សែនក្រអូប | ៥៤៥១<br>-សែនក្រអូប | ៥៤៥១<br>-សែនក្រអូប | - |
| ដំណាំទី១៖ ស្រូវ (ហ.ត) | - | - | - | - | - |
| ដំណាំទី២៖ ឱឡឹក (ហ.ត) | - | - | - | - | - |
| ដំណាំទី៣៖.........(ហ.ត) | - | - | - | - | - |
| ការចិញ្ចឹមត្រី | ០ | ស្រះតាមផ្ទះ | ០ | ០ | - |
| ចំនួនគោ | - | ១២ | ២ | ០ | - |
| ចំនួនក្របី | ០ | ៣ | ១ | ០ | - |
| ចំនួនជ្រូក | ០ | ២ | ០ | ០ | - |
| ការប្រើប្រាស់ឧបករណ៍នេសាទ | អួន លប | អួន លប | សន្ទូច មង សំណាញ់ | សន្ទូច | - |
| ប្រភពចំណូលទី១៖ | លក់ស្រូវ | លក់ស្រូវ | លក់កម្លាំង | លក់កម្លាំង | - |

| | | | | | |
|---|---|---|---|---|---|
| | | | ពលកម្ម | ពលកម្ម | |
| ប្រភពចំណូលទី២៖ | ចាប់ហួយ | នេសាទ | នេសាទ | នេសាទ | - |
| ប្រភពចំណូលទី៣៖ | ជួលគ្រឿងចក្រ | - | - | - | - |
| ការងារក្រៅពីកសិកម្ម (ប្រភេទពលកម្ម) | ជំនួញៈ ត្រី ស្រូវ ឡានដឹកដី ក្តាម | ជំនួយត្រី | រកខ្យង | -រកខ្យង<br>-រើសកក្កូរ | - |
| ការប្រើប្រាស់ឥណទាន | ចងការ ធនាគារ ហិរញ្ញវត្ថុ | ចងការធនាគារ ហិរញ្ញវត្ថុ | មីក្រូហិរញ្ញវត្ថុ | ចងការក្នុង ភូមិ | - |

ប្រភព៖ *របាយការណ៍វិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំកំពង់គោ ឆ្នាំ ២០១៨*

### គ.ស្ថានភាពបំណុលសរុប និងអត្រាការប្រាក់

ប្រជាពលរដ្ឋនៅក្នុងឃុំកំពង់គោមានចំនួន ៧៣៤គ្រួសារ ស្មើប្រមាណ ៤៨ភាគរយ ដែលមានបំណុលពីមីក្រូហិរញ្ញវត្ថុ និងធនាគារ ដូចមានរាយខាងក្រោម៖

- អ្នកមានជីវភាពបង្គួរ៖ មានលទ្ធភាពអាចខ្ចីប្រាក់ពីធនាគារ យកមកចងការបន្ត និងពង្រីកមុខរបរ ដូចជា កសិកម្ម សិប្បកម្ម និងលក់ដូរ។ល។
- អ្នកមានជីវភាពមធ្យម៖ មានលទ្ធភាពខ្ចីប្រាក់ពីធនាគារ យកមកចងការបន្ត និងពង្រីកមុខរបរ ដូចជា កសិកម្ម សិប្បកម្ម និងលក់ដូរ។ល។
- អ្នកមានជីវភាពខ្សត់ខ្សោយក្រ៖ ពុំអាចមានលទ្ធភាពខ្ចីប្រាក់ពីធនាគារឬមីក្រូហិរញ្ញវត្ថុឯកជនទេ ដោយសារគ្មានទ្រព្យបញ្ចាំ តែត្រូវខ្ចីប្រាក់បន្តពីអ្នកមានជីវភាពបង្គួរ និងមធ្យម។
- ចំណែកអ្នកក្របំផុត៖ ប្រកបរបរដោយលក់កម្លាំងពលកម្ម និងធ្វើចំណាកស្រុក។

នៅក្នុងឃុំកំពង់គោ មិនមានទីតាំងធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ នៅក្នុងឃុំនោះទេ តែមានសេវាប្រាក់កម្ចីពីធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុជាច្រើនក្នុងមូលដ្ឋាន។ ហើយចំពោះអត្រាការប្រាក់វិញគិតទៅតាមចំនួននៃប្រាក់កម្ចី បើសិនកម្ចីនោះកាន់តែច្រើនអត្រាការប្រាក់កាន់តែទាបរហូតដល់ 0,៩ ភាគរយ តែបើកម្ចីនោះកាន់តែតិច អត្រាការប្រាក់កាន់តែខ្ពស់រហូតដល់ ១,៨ ភាគរយ។ ទាំងធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងអស់មានអត្រាការប្រាក់ប្រហាក់ប្រហែលគ្នា នៅក្នុងនោះប្រជាពលរដ្ឋក្នុងឃុំ បានទទួលសេវាកម្ចីពីធនាគារអេស៊ីលីដា ប្រៃសណីយ៍ ស្ថាបនា ហត្ថាកសិករ ប្រសាក់ LOLC អេអឹមខេ មហានគរ បណ្តាញសេដ្ឋកិច្ច។ ចំណែកអ្នកខ្សត់ខ្សោយដែលខ្ចីប្រាក់បន្តពីអ្នកមានជីវភាពបង្គួរ និងមធ្យមមានអត្រាការប្រាក់ខ្ពស់ ១,៥ភាគរយ ទៅ១០ភាគរយ។

### ឃ.ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់ ឬក្រោមរូបភាពផ្សេងៗ

ជាទូទៅប្រជាពលរដ្ឋនៅក្នុងឃុំកំពង់គោ បានប្រើប្រាស់មីក្រូឥណទាន ជាសាច់ប្រាក់សុទ្ធ ដើម្បីយកទៅពង្រីកមុខរបរ ចងការបន្ត ទិញសម្ភារៈកសិកម្ម ទិញជី និងប្រើប្រាស់តាមតម្រូវការចាំបាច់ផ្សេងៗទៀត ក៏នៅមានក្រោមរូបភាព ដែលប្រជាពលរដ្ឋមួយចំនួនទៅទទួលយកជីដាក់ស្រូវមុន និងសន្យាសងប្រាក់នៅពេលប្រមូលផលស្រូវផងដែរ។

### ង.ចំណូលពីប្រភពផ្សេងៗ

ប្រជាពលរដ្ឋនៅក្នុងឃុំកំពង់គោ ពួកគាត់អាចទទួលបាននូវប្រភពចំណូលពីប្រភពផ្សេងៗដូចជា៖

- ចំណាកស្រុកក្រៅប្រទេស(ពលករផ្នែក កសិកម្ម ឧស្សាហកម្ម) ដូចជាប្រទេសថៃ កូរ៉េជាដើម

- និងចំណូលមួយចំនួនតូចទៀត បានមកពីក្រុមគ្រួសារ ឬបងប្អូនរស់នៅជាអចិន្ត្រៃយ៍នៅបរទេស ដែលពួកគាត់បានផ្ញើមកដើម្បីផ្គត់ផ្គង់គ្រួសារនៅស្រុកខ្មែរ។

## ១.១.៨.ស្ថានភាពអប់រំ និងសិក្សាធិការ

### ក.ស្ថានភាពអប់រំ

តាមផែនការអភិវឌ្ឍឃុំកំពង់គោ ៥ ឆ្នាំ (២០១៧-២០២២) បានឱ្យដឹងថា ជារៀងរាល់ឆ្នាំកុមារាកុមារីគ្រប់អាយុចូលរៀន បានចុះឈ្មោះចូលរៀនគ្រប់គ្នា ទោះបីជាកុមារ ស្ថិតនៅក្នុងស្ថានភាពគ្រួសារក្រីក្រ គ្រួសារដែលជាស្ត្រីមេម៉ាយឬក្មេងកំព្រា កុមារពិការក៏ដោយក្តី។ មកដល់ពេលបច្ចុប្បន្ននេះ វិស័យអប់រំនៅក្នុងឃុំកំពង់គោ មានការរីកចម្រើនដូចជា៖ អគារសិក្សាត្រូវបានសាងសង់ថ្មីៗ និងមានការកែលម្អបន្ទប់រៀនថែមទៀត នៅតាមសាលារៀនគ្រប់កម្រិត ដែលផ្តល់លទ្ធភាពឱ្យសិស្សបានរៀនសូត្រគ្រប់ពេលពុំមានការខ្វះខាតឡើយ។ ចំណុចអវិជ្ជមានក៏មាននៅក្នុងឃុំផងដែរ ដូចជា៖ ខ្វះគ្រូបង្រៀន មិនទាន់មានសាលាវិទ្យាល័យ និងសាលាមត្តេយ្យសហគមន៍គ្រប់គ្រាន់នៅតាមតាមភូមិនៅឡើយ មានអ្នកមិនចេះអក្សរ (អនក្ខរជន) ជាពិសេសមនុស្សមានវ័យចំណាស់ពួកគាត់ពុំសូវមានស្មារតីសិក្សារៀនសូត្រ ទោះបីជាមានការយកចិត្តទុកដាក់ជំរុញលើកទឹកចិត្តពីអាជ្ញាធរក្នុងមូលដ្ឋានយ៉ាងណាក៏ដោយ។

រូបភាព 1៖ សាលារៀន



សាលាបឋមសិក្សាឃុំកំពង់គោ




សាលាអនុវិទ្យាល័យឃុំកំពង់គោ

នៅក្នុងឃុំកំពង់គោ មានកម្រិតសិក្សាចាប់ពីមត្តេយ្យសិក្សា រហូតដល់ អនុវិទ្យាល័យ ចំណែកវិទ្យាល័យវិញមិនទាន់មាននោះទេ ប៉ុន្តែមាននៅខាងក្រៅឃុំ។ សាលាមត្តេយ្យមានចំនួន ០៣ កន្លែង ០៣ បន្ទប់ ០៣ ថ្នាក់ ហើយមានគ្រូបង្រៀនចំនួន ០៣ នាក់ ជាស្ត្រី ហើយសិស្សកំពុងរៀនចំនួន ៨៤ នាក់ ក្នុងនោះស្រី ៣៦ នាក់។ សាលាបឋមសិក្សាមានចំនួន ០៥ កន្លែង ១៩បន្ទប់ ១៩ ថ្នាក់ ហើយគ្រូបង្រៀនចំនួន ៣២ នាក់ ក្នុងនោះមានស្ត្រី ១៣ នាក់ និងសិស្សកំពុងរៀនមានចំនួន ១ ១១៩ នាក់ និង ស្រីចំនួន ៥៧៥ នាក់ ចំណែកសាលាអនុវិទ្យាល័យវិញមានចំនួន ០១ កន្លែង ១០ បន្ទប់ ០៧ ថ្នាក់ ហើយគ្រូបង្រៀនមានចំនួន ០៩ នាក់ ក្នុងនោះស្ត្រី ០៥ នាក់ និងសិស្សដែលកំពុងរៀនមានចំនួន ១៦៣ នាក់ នៅក្នុងស្រីចំនួន ៨៣ នាក់ ។

តារាង 10៖ ស្ថិតិសាលារៀន ស្ថានភាពអប់រំ និងសិក្សាធិការក្នុងឃុំឆ្នាំ២០១៧

| ស្ថានភាពសាលា | ចំនួនសាលារៀន | | | ចំនួនសិស្ស | | គ្រូបង្រៀន | |
|---|---|---|---|---|---|---|---|
| | សាលា | បន្ទប់ | ថ្នាក់ | សរុប | ស្រី | សរុប | ស្រី |
| ១.សាលាមត្តេយ្យ | ៣ | ៣ | ៣ | ៨០ | ៤៨ | ៣ | ៣ |
| ២.សាលាបឋមសិក្សា | ៥ | ១៩ | ១៩ | ១១១៩ | ៥៧៥ | ៣២ | ១៣ |
| ៣.អនុវិទ្យាល័យ | ១ | ១០ | ៧ | ១៦៣ | ៨៣ | ៩ | ៥ |
| ៤.វិទ្យាល័យ | 0 | 0 | 0 | 0 | 0 | 0 | 0 |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់គោ ខែមេសា ឆ្នាំ២០១៨*

**ខ.ស្ថានភាពអក្ខរកម្ម**

នៅក្នុងឃុំកំពង់គោ ប្រជាពលរដ្ឋដែលមានអាយុពី ១៥-៤៥ឆ្នាំ មានចំនួន ៣ ៤២៦ នាក់ ហើយនៅក្នុងចំណោមនោះ អ្នកដែលមិនចេះអក្សរមានចំនួន ១២ ភាគរយ។ បើគិតទៅតាមក្រុមអាយុនៅក្នុងឃុំកំពង់គោមានអ្នកមិនចេះអក្សរអាយុពី ១៥-២៤ឆ្នាំមានចំនួន ៨៤ នាក់ ស្មើនឹង ៦,២ ភាគរយ អាយុពី ២៥-៤៥ឆ្នាំ មានចំនួនសរុប ៣២៧ នាក់ ស្មើនឹង ១៥,៩ ភាគរយ។

ប្រជាជនភាគច្រើន មិនបានចូលរៀន ដោយសារតែសាលារៀននៅឆ្ងាយពីភូមិ ឃុំ ប្រជាពលរដ្ឋនៅតែមានកង្វះមធ្យោបាយធ្វើដំណើរទៅសាលារៀន ខ្វះថវិកាសម្រាប់ទិញសម្ភារៈសិក្សា សម្លៀកបំពាក់ និងផ្នត់គំនិតរបស់ឪពុកម្ដាយនៅចាស់គំរឹល ឬមិនជឿនលឿន ហើយនៅក្នុងឃុំនៅមានថ្នាក់អក្ខរកម្មជាប្រចាំ តែពួកគាត់ពុំទាន់មានពេលសិក្សាព្រោះជាប់រវល់ប្រកបរបរចិញ្ចឹមជីវិត ជាហេតុនាំមកនូវការភ្លេចអក្សរ ក្នុងចំណោមអ្នកដែលបានចូលមកសិក្សាក្នុងថ្នាក់អក្ខរកម្មកន្លងមក។

**- អនុវិស័យអប់រំក្រៅប្រព័ន្ធ**

១.បន្តពង្រឹងសកម្មភាពមជ្ឈមណ្ឌលសិក្សាសហគមន៍ បណ្ណាល័យ និងមណ្ឌលអានដែលមានស្រាប់
២.បន្តពង្រឹងការអនុវត្តកម្មវិធីសមមូលបឋមសិក្សា និងមធ្យមសិក្សា
៣.អនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ
៤.បន្តអនុវត្តការងារអក្ខរកម្មតាមការជាក់ស្តែង
៥.បន្តអនុវត្តកម្មវិធីចូលរៀនឡើងវិញ

តារាង 11៖ ស្ថិតិអ្នកមិនចេះអក្សរ

| បរិយាយ | ២០១៦ | ២០១៧ |
|---|---|---|
| ចំនួនអ្នកមិនចេះអក្សរអាយុ១៥-២៤ឆ្នាំ | ៨៤ | ៨៤ |
| %អ្នកមិនចេះអក្សរអាយុ១៥-២៤ឆ្នាំ | ៥,៧ | ៦,២ |
| ចំនួនអ្នកមិនចេះអក្សរអាយុ២៥-៤៥ឆ្នាំ | ៣៤១ | ៣២៧ |
| %អ្នកមិនចេះអក្សរអាយុ២៥-៤៥ឆ្នាំ | ១៧,៤ | ១៥,៩ |
| សរុបមនុស្សអាយុ១៥-៤៥ឆ្នាំ | ៣៤៣៦ | ៣៤២៦ |
| %អ្នកមិនចេះអក្សរអាយុ១៥-៤៥ឆ្នាំ | ១២,៤ | ១២ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់គោ ខែមេសា ឆ្នាំ២០១៨*

### គ.ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត

បើយោងទៅតាមប្រភពទិន្នន័យពីមន្ទីរផែនខេត្តឆ្នាំ ២០១៧ បានបង្ហាញឱ្យឃើញថា លទ្ធភាពនៅក្នុងការបន្តការសិក្សារបស់សិស្សក្នុងឃុំកំពង់គោទៅថ្នាក់ខ្ពស់ទៀតមានដូចខាងក្រោម៖

- អាយុពី១២-១៤ឆ្នាំរៀនអនុវិទ្យាល័យសរុបចំនួន ១៩៦ នាក់ ស្រីមានចំនួន ៨៥ នាក់
- អាយុពី១៥-១៧ឆ្នាំរៀនអនុវិទ្យាល័យសរុបចំនួន ១៦៤ នាក់ ស្រីមានចំនួន ៥៦ នាក់
- អាយុពី១៥-១៧ឆ្នាំរៀនវិទ្យាល័យសរុបចំនួន ៥២ នាក់ ស្រីមានចំនួន ១៩ នាក់
- អាយុពី១៨-២៤ឆ្នាំរៀនវិទ្យាល័យសរុបចំនួន ១០៣ នាក់ ស្រីមានចំនួន ៤៩ នាក់
- អាយុពី១៨-២៤ឆ្នាំរៀនសកលវិទ្យាល័យសរុបចំនួន ៩៦ នាក់ ស្រីមានចំនួន ៣១ នាក់។
- អាយុពី២៥-៣៥ឆ្នាំរៀនសកលវិទ្យាល័យសរុបចំនួន ៦០ នាក់ ស្រីចំនួន ២៣ នាក់
- អាយុពី១៨-២៤ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈមានចំនួន ៩៩ នាក់ ស្រី ៥១ នាក់
- អាយុពី២៥-៣៥ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈមានចំនួន ១៣៦ នាក់ ស្រី ៩៩ នាក់

តារាង 12៖ ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត

| ការអប់រំតាមក្រុមអាយុ | សរុប | ស្រី |
|---|---|---|
| អាយុពី១២-១៤ឆ្នាំរៀនអនុវិទ្យាល័យ | ១៩៦ | ៨៥ |
| អាយុពី១៥-១៧ឆ្នាំរៀនអនុវិទ្យាល័យ | ១៦៤ | ៥៦ |
| អាយុពី១៥-១៧ឆ្នាំរៀនវិទ្យាល័យ | ៥២ | ១៩ |
| អាយុពី១៨-២៤ឆ្នាំរៀនវិទ្យាល័យ | ១០៣ | ៤៩ |
| អាយុពី១៨-២៤ឆ្នាំរៀនសកលវិទ្យាល័យ | ៩៦ | ៣១ |
| អាយុពី២៥-៣៥ឆ្នាំរៀនសកលវិទ្យាល័យ | ៦០ | ២៣ |
| អាយុពី១៨-២៤ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ | ៩៩ | ៥១ |
| អាយុពី២៥-៣៥ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ | ១៣៦ | ៩៩ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់គោ ខែមេសា ឆ្នាំ២០១៨*

### ១.១.៥.ស្ថានភាពសុខាភិបាល

មណ្ឌលសុខភាព គឺជាកន្លែងផ្តល់សេវាអប់រំសុខភាព ថែទាំ និងព្យាបាលអ្នកជម្ងឺផ្សេងៗ ដែលជាកន្លែងសាធារណៈរបស់រដ្ឋ។ ឃុំកំពង់គោ មានមណ្ឌលសុខភាពចំនួន ០១ កន្លែង ដែលស្ថិតនៅខាងជើងឆៀងខាងកើតសាលាឃុំមានចម្ងាយប្រហែល ០,៥ គីឡូម៉ែត្រ។ មណ្ឌលសុខភាពនេះមានគ្រូពេទ្យចំនួន ០៥ នាក់ នៅក្នុងនោះមានឆ្មប ០២នាក់ មានបន្ទប់ចំនួន ០៦ និងគ្រែចំនួន ០៣ ។ ប្រភេទជម្ងឺ ដែលកាចសាហាវ ឬជម្ងឺឆ្លង ដែលកើតញឹកញាប់ គឺជម្ងឺរលាកផ្លូវដង្ហើម។ ស្ថានភាពមាតានិងទារកនៅក្នុងឃុំកំពង់គោមានស្រ្តី ដែលសម្រាលកូនដោយឆ្មបបុរាណក្នុង១ឆ្នាំកន្លងទៅចំនួន ២នាក់ ស្រ្តីសម្រាលកូនដោយឆ្មបមានការបណ្តុះបណ្តាលក្នុង ១ឆ្នាំកន្លងទៅមានចំនួន ៩៥នាក់ ទារកបានកើតរស់ដោយឆ្មបបុរាណចំនួន ២នាក់ ទារកបានកើតរស់ដោយឆ្មបពេទ្យ ៩៥នាក់ មរណភាពរបស់មាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ០-១ខែ ដោយឆ្មបបុរាណមិនមាននោះទេ មរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ០-១ខែដោយឆ្មបពេទ្យមិនមានទេ មរណភាពទារកក្នុងចន្លោះអាយុ០-១ខែ ដោយ

ឆ្មបបុរាណមិននោះទេ មរណភាពទារកក្នុងចន្លោះអាយុ ០-១ខែ ដោយពេទ្យឆ្មបមិនមាននោះទេ ទារកដែលបានចុះសំបុត្រកំណើតមានចំនួន៧៥នាក់ កុមារដែលមានអាយុចន្លោះពី៩-១២ខែមានចំនួន៧១នាក់ កុមារដែលមានអាយុចន្លោះពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់៧១នាក់ ដែលការចាក់ថ្នាំបង្ការជម្ងឺទាំងនេះធ្វើនៅមណ្ឌលសុខភាព និងតាមភូមិជូនប្រជាពលរដ្ឋមានជម្ងឺដូចជា ជម្ងឺ កញ្ជ្រិល ស្វិតដៃជើង ក្អកមាន់ របេង តេតាណូស រលាកថ្លើមប្រភេទបេ ផ្តាសាយបក្សី គ្រុនចាញ់ រាគរូស និងគ្រុនឈាម។ ករណីជម្ងឺធ្ងន់ធ្ងរការបញ្ជូនអ្នកជម្ងឺដោយមធ្យោបាយខ្លួនឯងផ្ទាល់ មកមណ្ឌលសុខភាព ព្រោះមណ្ឌល សុខភាពស្ថិតនៅជិតពួកគាត់ ឯការបញ្ជូនទៅមន្ទីរពេទ្យបង្អែកដោយមធ្យោបាយផ្ទាល់ខ្លួន និងរថយន្តសង្គ្រោះរបស់ពេទ្យបង្អែក តែការចំណាយផ្សេងៗ ជាបន្ទុករបស់អ្នកជម្ងឺក្នុងករណីអ្នកជម្ងឺមិនមានប័ណ្ណក្រីក្រ។

តារាង 13៖ សុខភាពមាតានិងទារក

| ល.រ | សុខភាពមាតានិងទារក | ឆ្នាំ២០១៧ |
|---|---|---|
| ១ | ចំនួនបុគ្គលិកពេទ្យនៅមណ្ឌលសុខភាព | ០៥ នាក់ |
| ២ | ចំនួនពេទ្យឆ្មបនៅមណ្ឌលសុខភាព | ០២ នាក់ |
| ៣ | ចំនួនឆ្មបបុរាណនៅមណ្ឌលសុខភាព | ០ |
| ៤ | ចំនួនបន្ទប់នៅមណ្ឌលសុខភាព | ០៦ បន្ទប់ |
| ៥ | ចំនួនគ្រែនៅមណ្ឌលសុខភាព | ០៣ គ្រែ |
| ៦ | ចំនួនឆ្មបដែលបានបណ្តុះបណ្តាលមានក្នុងភូមិ | ៤ នាក់ |
| ៧ | ចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបបុរាណក្នុង១ឆ្នាំកន្លងទៅ | ២ នាក់ |
| ៨ | ចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបមានការបណ្តុះបណ្តាលក្នុង ១ឆ្នាំកន្លងទៅ | ៩៥ នាក់ |
| ៩ | ចំនួនទារកដែលបានកើតរស់ដោយឆ្មបបុរាណ | ២ នាក់ |
| ១០ | ចំនួនទារកដែលបានកើតរស់ដោយឆ្មបពេទ្យ | ៩៥ នាក់ |
| ១១ | ចំនួនមរណភាពមាតាបន្ទាប់ពីសំរាលកូនក្នុងចន្លោះ ០-១ខែដោយឆ្មបបុរាណ | ០ |
| ១២ | ចំនួនមរណភាពមាតាបន្ទាប់ពីសំរាលកូនក្នុងចន្លោះ ០-១ខែដោយពេទ្យឆ្មប | ០ |
| ១៣ | ចំនួនមរណភាពទារកក្នុងចន្លោះអាយុ ០-១ខែដោយឆ្មបបុរាណ | ០ |
| ១៤ | ចំនួនមរណភាពទារកក្នុងចន្លោះអាយុ ០-១ខែដោយពេទ្យឆ្មប | ០ |
| ១៥ | ចំនួនទារកដែលបានចុះសំបុត្រកំណើត | ៧៥ នាក់ |
| ១៦ | ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែ | ៧១ នាក់ |
| ១៧ | ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន | ៧១ នាក់ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់គោ ខែមេសា ឆ្នាំ២០១៨*

រូបភាព 2 ៖ មណ្ឌលសុខភាពកំពង់គោ




យោងតាមពីទិន្នន័យមន្ទីរផែនការខេត្ត ឆ្នាំ ២០១៧ បានឱ្យដឹងថា ចម្ងាយពីភូមិនីមួយៗទៅកាន់មណ្ឌលសុខភាព មិនឆ្ងាយណាស់ណានោះទេ គឺឆ្ងាយបំផុតត្រឹមពី០-៥គីឡូម៉ែត្រប៉ុណ្ណោះ ដូចមានក្នុងតារាងសង្ខេបខាងក្រោម។ ចំណែកស្ថានភាពផ្លូវទៅកាន់មណ្ឌលសុខភាពក៏មិនពិបាកក្នុងការធ្វើដំណើរដែរ ដែលអំណោយផលដល់ការបញ្ជូនអ្នកជម្ងឺទៅកាន់មណ្ឌលសុខភាពបានទាន់ពេលវេលា។

តារាង 14៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព

| ល.រ | ឈ្មោះភូមិ | ចម្ងាយជាមធ្យម ពីភូមិទៅមណ្ឌលសុខភាព | ផ្សេងៗ |
|---|---|---|---|
| ១ | កំពង់គោលើ | 0 គីឡូម៉ែត | |
| ២ | កំពង់គោក្រោម | ៣ គីឡូម៉ែត | |
| ៣ | ខ្សាច់ជីរស់ | ៥ គីឡូម៉ែត | |
| ៤ | បូពឹង | ២ គីឡូម៉ែត | |
| ៥ | កោះគ្របបាយ | ១ គីឡូម៉ែត | |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់គោ ខែមេសា ឆ្នាំ២០១៨*

ដ្យាក្រាម 2៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព




*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់គោ ខែមេសា ឆ្នាំ២០១៨*

### ១.១.៦.ស្ថានភាពយេនឌ័រ

បើតាមផែនការអភិវឌ្ឍឃុំកំពង់គោរយៈពេល ៥ ឆ្នាំ (២០១៨-២០២២) បានឱ្យដឹងថា សមភាពការងាររបស់ស្ត្រី និងបុរសនៅក្នុងឃុំកំពង់គោនាពេលបច្ចុប្បន្ននេះ គ្មានការរើសអើង ឬគាបសង្កត់ទៅលើស្ត្រីនោះទេ។ ផ្ទុយទៅវិញការងារយេនឌ័រកំពុងតែមានការគាំទ្រយ៉ាងពេញទំហឹង ជាក់ស្តែងការងារមានថ្នាក់ដឹកនាំជាស្ត្រី នៅថ្នាក់ភូមិ និងថ្នាក់ឃុំកំពុងត្រូវបានលើកកម្ពស់ និងលើកទឹកចិត្តស្ត្រីឱ្យមានការចូលរួមយ៉ាងសកម្ម ក្នុងការកសាងផែនការអភិវឌ្ឍឃុំ ក៏ដូចជាផែនការវិនិយោគផងដែរ។ ទោះជាយ៉ាងនេះក្តី បញ្ហាប្រឈមនៅតែកើតមានឡើងទៅលើសមត្ថភាពស្ត្រី ដោយមានមួយចំនួននៅតែមានកម្រិតជីវភាពក្រីក្រ ខ្លះបោះបង់ការសិក្សា ដើម្បីរកចំណូលមកទ្រទ្រង់ជីវភាពនៅក្នុងគ្រួសារ អ្នកខ្លះចំណាកស្រុកទៅភ្នំពេញធ្វើជាកម្មកររោងចក្រដើម្បីដោះស្រាយបញ្ហានេះ ក្រុមប្រឹក្សាឃុំ បានសហការជាមួយមន្ទីរការិយាល័យជំនាញ និងដៃគូអភិវឌ្ឍនានាជុំវិញ និងលើកទឹកចិត្តឱ្យមានការបណ្តុះបណ្តាលពីបច្ចេកទេសនានា និងជំនាញវិជ្ជាជីវៈបង្កើនមុខរបរថ្មីៗ ដើម្បីបង្កើនប្រាក់ចំណូល និងកាត់បន្ថយការចំណាកស្រុក។ ប៉ុន្តែបើយោងតាមរយៈរបាយការណ៍នៃការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំកំពង់គោ នៅឆ្នាំ២០១៧ បានឱ្យដឹងអំពីតួនាទីយេនឌ័រក្នុងការចូលរួមសកម្មភាពការងារផលិតកម្មកសិកម្ម និងការងារទូទៅក្នុងជីវភាពគ្រួសាររបស់កសិករក្នុងឃុំកំពង់គោមានលម្អិតក្នុងតារាងខាងក្រោម។

តារាង 15៖ ការវិភាគលើតួនាទីយេនឌ័រ ឃុំកំពង់គោ

| សកម្មភាព | បុរស | ស្ត្រី | យោបល់បន្ថែម |
|---|---|---|---|
| **ស្រូវប្រដេញទឹក និងស្រូវប្រាំង** | | | |
| ការរៀបចំដីលើកទី១ | ៨០% | ២០% | បុរសធ្វើការតាមទីវាលច្រើនជាងស្ត្រីជួយបានខ្លះ និងការងារផ្ទះ |
| ការរៀបចំដីលើកទី២ | ៥០% | ៥០% | ស្ត្រីជួយជម្រះស្មៅ ធ្វើភ្លឺស្រែ |
| ការត្រាំពូជ | ៥០% | ៥០% | ស្ត្រីជួយកើបស្រូវដាក់បេ បុរសយកទៅត្រាំទឹក |
| ព្រួស | ៥០% | ៣០% | ស្ត្រីជួយជញ្ជូនពូជ បុរសដើរព្រួស |
| ការដាក់ជីបំប៉ន | ៥០% | ២០% | ស្ត្រីជួយជញ្ជូនជី បុរសដើរបាចជី |
| គ្រប់គ្រងទឹកស្រែ | ៥០% | ១០% | ស្ត្រីធ្វើការងារផ្ទះ បុរសទៅមើល និងធ្វើ |
| ការថ្នាំសម្លាប់ស្មៅ | ៥០% | ៤០% | បុរសអ្នកបាញ់ថ្នាំ ស្ត្រីជួយដងទឹកសម្រាប់លាយថ្នាំ |
| ការច្រូតកាត់ | ៥០% | ៥០% | ស្ត្រីមានសកម្មភាពចូលរួមយ៉ាងសកម្មនិងច្រើនជាង |
| ការដឹកជញ្ជូន | ៥០% | ២០% | ចូលរួមស្មើគ្នា |
| ហាលសម្ងួត | ៩០% | ១០% | បុរសជួយលើកបាវស្រូវដាក់កន្លែងទីលានហាល |
| ទុកដាក់ស្រូវ | ៥០% | ៥០% | បុរសជួយលើកដាក់ជង្រុក ឬលើផ្ទះ |
| លក់ស្រូវ | ១០% | ៩០% | ស្ត្រីអ្នកកាន់លុយនិងចចារតម្លៃ |
| **សកម្មភាពមុខរបរចិញ្ចឹមជីវិតសំខាន់ផ្សេងទៀត** | | | |
| សួនបន្លែ | ១០% | ៩០% | ស្ត្រីនៅផ្ទះច្រើននិងជាអ្នកធ្វើ បុរសរកការងារធ្វើនៅឆ្ងាយ |
| ចិញ្ចឹមជ្រូក | ១០% | ៩០% | ស្ត្រីនៅផ្ទះច្រើន បុរសរកការងារធ្វើ រកស៊ីនៅឆ្ងាយ |
| ចិញ្ចឹមគោ ក្របី | ៥០% | ៥០% | បុរសច្រូតស្មៅនិងឃ្វាលនៅឆ្ងាយៗ |
| ចិញ្ចឹមមាន់ ទា | ៣០% | ៧០% | បុរសដើរធ្វើការងារឆ្ងាយ |
| ការប្រមូលអនុផលព្រៃឈើ | ៨០% | ២០% | បុរសចូលព្រៃរកអុសនិងផលផ្សេងៗទៀត |
| រកត្រី | ៨០% | ២០% | ទៅរកទាំងអស់គ្នា |
| ជំនួញទូទៅ | ៥០% | ៥០% | ទៅរកទាំងអស់គ្នា និងមានការសម្រេចចិត្តមុន |

| | | | |
|---|---|---|---|
| ការថែទាំប្រព័ន្ធធារាសាស្ត្រ | ៩០% | ១០% | ជួយគ្នា |
| **ដំណាំរួមផ្សំ** | | | |
| ការរៀបចំដី | ២០% | ៨០% | បុរសអ្នកភ្ជួរ ស្ត្រីក្រោកដាំបាយនិងជួយរៀបចំឧបករណ៍ភ្ជួរ |
| ភ្ជួរ រាស់ | ៩០% | ១០% | បុរសភ្ជួរ ស្ត្រីជួយរៀបចំបាយទឹក |
| ឆូតរង | ៥០% | ៥០% | ស្ត្រីជួយពូនរង |
| ផ្គុំរង លើករង ដាក់ជី | ៥០% | ៥០% | ការងារធ្វើរួមគ្នា |
| ដាំគ្រាប់ | ៥០% | ៥០% | ការងារធ្វើរួមគ្នា |
| ដាក់ជី | ២០% | ៨០% | ការងារធ្វើរួមគ្នា |
| ពូនរង | ៥០% | ០% | បុរសបោះបង្គោល ចងខ្សែ ស្ត្រីជួយរៀបចំសម្ភារៈ |
| បូមទឹក | ៥០% | ៥០% | បុរសអ្នកបូមស្រោចទឹក ស្ត្រីដើរមើលតាមរង |
| ថែទាំ | ២០% | ៨០% | រួមគ្នាធ្វើម្តងម្នាក់ |
| ប្រមូលផល | ៥០% | ៥០% | ជួយបេះផ្លែទាំងអស់គ្នា |
| លក់ដោយម៉ៅ | ១០% | ៩០% | ស្ត្រីសម្រេចចិត្តច្រើនជាងបុរស |

ប្រភព៖ *របាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំកំពង់គោ ២០១៨*

យោងទៅតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំកំពង់គោឆ្នាំ២០១៧ បានរកឃើញពីការវិភាគតួនាទីយេនឌ័រក្នុងឃុំកំពង់គោដូចខាងក្រោម៖

១.ស្ត្រីភាគច្រើនជាអ្នកផលិតកម្មកសិកម្ម

២.បុរសទៅរកចំណូលនៅឆ្ងាយៗផ្ទះ

៣.ស្ត្រីមើលថែការងារនៅផ្ទះជាប្រចាំ

៤.សកម្មភាពការងារមានការចូលរួមធ្វើទាំងអស់គ្នា

៥.ការងារធ្ងន់ៗជាបន្ទុករបស់បុរស

បើយោងតាមប្រភពព័ត៌មាន ដែលទទួលបានដូចមានរៀបរាប់ខាងលើ ពាក់ព័ន្ធការលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិអំណាចស្ត្រីនៅក្នុងឃុំកំពង់គោ យើងសង្កេតឃើញថា បុរស និងស្ត្រីមិនមានការរើសអើងគ្នាធ្ងន់ធ្ងរនោះទេ គឺមានភាពលំអៀងតិចតួចប៉ុណ្ណោះ ដូចជា ការងារធ្វើស្រែឃើញបុរសមានការចូលរួមច្រើនជាងស្ត្រី ជាពិសេសការងាររៀបចំដីស្រែ ឃើញថាការងារនេះបុរសទទួលរ៉ាប់រងស្ទើរតែទាំងស្រុង ដែលស្ត្រីមានកម្លាំងទន់ខ្សោយជាងជាអ្នកចម្អិនអាហារនៅផ្ទះ ហើយក៏ឃើញថាការងារដឹកជញ្ជូនគ្រាប់ស្រូវ បាញ់ថ្នាំសម្លាប់សត្វល្អិតនិងដាក់ជី ច្រូតកាត់ និងការងារទុកដាក់ស្រូវជាដើមគឺ បុរសបានចូលរួមច្រើនជាងស្ត្រី ប៉ុន្តែការងារក្នុងផ្ទះនិងនៅជិតផ្ទះឃើញស្ត្រីបានចូលរួមច្រើនជាងបុរសវិញ តែក្នុងនោះក៏បានរកឃើញថា ការសម្រេចចិត្តនៅក្នុងគ្រួសារបុរសនៅមានសិទ្ធិច្រើនជាងស្ត្រី និងមានស្ត្រីមួយចំនួននៅទទួលរងអំពើហិង្សាក្នុងគ្រួសារនៅឡើយ ។ ប៉ុន្តែទោះបីមានបញ្ហាប្រឈមខ្លះក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិអំណាចស្ត្រីក៏ដោយ ក៏យើងឃើញកិច្ចការនេះមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដែលទៅថ្ងៃអនាគតនឹងឈានទៅកាន់តែប្រសើរឡើង ។

## ១.២.ស្ថានភាពភូមិសាស្ត្រ

### ១.២.១.ទីតាំងភូមិសាស្ត្រ

ឃុំកំពង់គោ ជាឃុំមួយនៅក្នុងរដ្ឋបាលស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ មានទីតាំងផ្អែកលើនិយាមកាផែនទី (អាប់ស៊ីស) ៤៧៧ ១០១,៨៤ និង(អ័រដោនេ) ១ ៤០៤ ៩២២,៥៩ ។ សណ្ឋានដីនៅក្នុងឃុំកំពង់គោ បើផ្អែក

តាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធកៀ្សត្រ-បរិស្ថានឃុំ បានឱ្យដឹងថា ជាដីមិនរាបស្មើមានទាបមានខ្ពស់ ដោយបានចែកចេញជា ០៣ តំបន់គឺ

**តំបន់ ១ ៖** នៅភាគខាងជើងឈាងខាងកើតនៃឃុំ ជាតំបន់ទំនាបមធ្យម ដែលមានប្រភេទដីខ្សាច់ល្បាយ (ពណ៌ប្រផេះ) ល្បាប់ ត្រូវបានប្រើប្រាស់សម្រាប់លំនៅឋាន ដំណាំចម្រុះ និងការចិញ្ចឹមសត្វ។

**តំបន់ ២ ៖** នៅស្ទើតែទូទាំងឃុំ គឺជាតំបន់ទំនាបលិចទឹកតាមរដូវ ដែលមានប្រភេទដីកណ្តោង ខ្លាញ់ក្តាម (ពណ៌ក្រ ហម) ត្រូវបានប្រើប្រាស់សម្រាប់ស្រូវប្រដេញទឹក ស្រូវប្រាំង និងព្រៃលិចទឹក។

**តំបន់ ៣ ៖** នៅភាគខាងលិចឈាងខាងត្បូងនៃឃុំ ជាតំបន់ទំនាបលិចទឹកអចិន្ត្រៃយ៍មានប្រភេទដីពពាយកណ្តុរ (ពណ៌ខ្មៅ) ដីមមោក ត្រូវបានប្រើប្រាស់សម្រាប់ស្រូវឡើងទឹក ស្រូវប្រាំង និងនេសាទ។

ផែនទី 3៖ ផែនទីរយៈកម្ពស់ឃុំកំពង់គោ



ផែនទី 4៖ តំបន់វិភាគប្រព័ន្ធក្បៀត្រ-បរិស្ថានឃុំកំពង់គោ




តារាង 16៖ ក្រាមពំនុះកាត់ទទឹង ឃុំកំពង់គោ ស្រុកកំពង់ស្វាយ

| តំបន់ / បរិយាយ | តំបន់-បរិស្ថាន I | តំបន់ក្សេត្រ-បរិស្ថាន II | តំបន់ក្សេត្រ-បរិស្ថាន III |
|---|---|---|---|
| រូបថតតំណាងតំបន់ក្សេត្រ-បរិស្ថាន |  |  |  |
| ឈ្មោះតំបន់ | **តំបន់ទំនាបមធ្យម** លំនៅឋាន ដំណាំចម្រុះ និងការចិញ្ចឹមសត្វ | **តំបន់ទំនាបលិចទឹកតាមរដូវ** ស្រូវប្រដេញទឹក ស្រូវប្រាំង និងព្រៃលិចទឹក | **តំបន់ទំនាបលិចទឹកអចិន្ត្រៃយ៍** ស្រូវឡើងទឹក ស្រូវប្រាំង និងនេសាទ |
| រៀបរាប់ដោយ | -ជម្រាលខ្សោយ | -ជម្រាលខ្សោយ | -ជម្រាលខ្សោយ |

| | | | |
|---|---|---|---|
| **សង្ខេប** | -លំនៅឋានដំណាំឈើហូបផ្លែ<br>-ស្រោចស្រពដោយទឹកភ្លៀង<br>-អូរ បឹង ប្រឡាយការ៉ាក់<br>-ដំណាំចម្រុះ -ការចិញ្ចឹមសត្វ<br>-លំនៅឋាន | -ស្រូវប្រដេញទឹក ស្រូវប្រាំង<br>-ស្រោចដោយទឹកស្ទឹង ទឹកប្រឡាយ<br>-ប្រឡាយការ៉ាក់ -ប្រឡាយឯកជន<br>-វាលស្មៅចិញ្ចឹមគោ<br>-ដាំបន្លែរដូវប្រាំង -ព្រៃលិចទឹក | -បឹងធម្មជាតិ -ស្ទឹងតូច<br>-ព្រៃលិចទឹក -សហគមន៍នេសាទ<br>-ស្រូវប្រាំង ស្រោចស្រពទឹក ទន្លេ និងអាងទឹក២០០០ |
| **ឋានលេខា** | -តំបន់I ផ្ទៃស្មើរាបស្មី ខ្ពស់ជាង II | -តំបន់II ខ្ពស់ជាង III ទាបជាង I ហូរទៅទន្លេសាប | តំបន់ III ទាបជាង II តាមមាត់ទន្លេ |
| **ប្រភេទដី** | -ដីខ្សាច់ល្បាយ (ពណ៌ប្រផេះ)<br>-ល្បាប់ | -ដីកណ្តេង ខ្លាញ់ក្អម(ពណ៌ក្រហម) | -ដីពពាយកណ្តុរ (ពណ៌ខ្មៅ)<br>-ដីមមោក |
| **ជលសាស្រ្ត** | -ស្រោចស្រពដោយទឹកភ្លៀង<br>-ស្រោចស្រពដោយទឹកជំនន់<br>-ទឹកស្ទឹងសែន | -ស្រោចស្រពដោយទឹកភ្លៀង និងប្រឡាយស្រោចស្រព<br>-ស្រោចស្រពដោយទឹកជំនន់ រយៈពេលខ្លី (៥ខែ) | -ទឹកទន្លេសាប ទឹកស្ទឹងសែន និងបឹងព្រៃប្រស់<br>-បឹង ត្រពាំង ធម្មជាតិ<br>-ប្រឡាយ និងអាងទឹក |
| **ធនធានទឹក** | -ប្រឡាយការីតាស -ប្រឡាយពលកម្ម<br>-ប្រឡាយការ៉ាក់ -ប្រឡាយអង្គរ<br>-ប្រឡាយចន្ទី -ប្រឡាយព្រះគន្លង<br>-ទឹកស្ទឹងសែន -ទឹកអូរតាសេក<br>-ស្ទឹងតូច -ទឹកអូតាឡោ | -ប្រឡាយការីតា -ប្រឡាយពលកម្ម<br>-ប្រឡាយការ៉ាក់ -ប្រឡាយអង្គរ<br>-ប្រឡាយចន្ទី -ប្រឡាយព្រះគន្លង<br>-ទឹកស្ទឹងសែន -ស្ទឹងតូចចង<br>-ទឹកអូរតាឌុច -ទឹកអូរតាសេក<br>-ទឹកអូតាឡោ -ទឹកប្រឡាយឯកជន | -ប្រឡាយសុខមន្ទី -បឹងព្រៃប្រស់<br>-បឹងមហាពពាយ -បឹងរាល<br>-បឹងបរស្នែង -បឹងព្រះគន្លង<br>-បឹងកូនសត្វ<br>-អាងទឹក៨០០ និងទឹកអាង២០០០<br>-អាងតាយាង<br>-អាងយាយលី (ឯកជន) |
| **គម្របដី/ការប្រើប្រាស់ដី** | -លំនៅឋាន ឈើហូបផ្លែចម្រុះ<br>-ដាំដំណាំរួមផ្សំនិងចិញ្ចឹមសត្វ | -វាលស្រែស្រូវប្រាំង<br>-ស្រូវប្រដេញទឹក<br>-ព្រៃលិចទឹក<br>-អាងទឹក ប្រឡាយ | -វាលស្រែស្រូវប្រាំង<br>-ស្រូវប្រដេញទឹក<br>-ព្រៃលិចទឹក<br>-អាងទឹក ប្រឡាយ |
| **ដំណាំសំខាន់ៗ** | -ឈើហូបផ្លែ ដូងស្វាយ ចេក<br>-ដាំបន្លែត្រសក់ ត្រឡាច ល្ពៅ<br>-ពោត សណ្តែកដី ល្ង | -ស្រូវ ៥៤៥១<br>-ស្រូវសែនក្រអូប<br>- | -ស្រូវ ៥៤៥១<br>-ស្រូវសែនក្រអូប<br>- |
| **ពូជស្រូវ** | -ស្រូវ ៥៤៥១<br>-ស្រូវសែនក្រអូប | -ស្រូវ ៥៤៥១ (VN)<br>-ស្រូវសែនក្រអូប (សហគមន៍) | -ស្រូវ ៥៤៥១ (VN)<br>-ស្រូវសែនក្រអូប (សហគមន៍) |
| **ការប្រើប្រាស់ជី** | - DAP ២B /ហត<br>-Urea ២B /ហត -NPK ១B /ហត | -Urea ១,៥B /ហត<br>-NPK ១,៥B /ហត | -Urea ២B /ហត |
| **ការចិញ្ចឹមសត្វ** | -គោក្របី មាន់ ទា ក្ងាន<br>-ចិញ្ចឹមត្រី | -តំបន់ឃ្វាលគោ ក្របី<br>-តំបន់ច្រូតស្មៅ | -ឃ្វាលគោ រដូវប្រាំង |
| **ដីរបស់រដ្ឋ ដីសហគមន៍** | -ស្ទឹងសែន -ស្ទឹងតូច<br>-សហគមន៍ប្រើប្រាស់អង្គរ<br>-សហគមន៍អភិវឌ្ឍកសិកម្មកំពង់គោ | -ប្រឡាយការ៉ាក់ -អូរឡោ<br>-អូរក្លូច -អូរទូកឡាក់<br>-អូរពាមក្រចៅ | -សហគមន៍នេសាទត្រី<br>-អាងទឹក៨០០ និងអាងទឹក២០០០<br>-បឹងរាល -បឹងស្នែង<br>-បឹងព្រះគន្លង -បឹងកូនសត្វ |

| បញ្ហាផ្សេងៗ | -តម្លៃស្រូវទាប<br>-ខ្វះបច្ចេកទេសដំណាំស្រូវ<br>-ខ្វះបច្ចេកទេសចិញ្ចឹមជ្រូក មាន់<br>-សត្វកើតជំងឺ គោ ក្របី ជ្រូក មាន់ ទា<br>-បម្រែបម្រួលអាកាសធាតុ | -ស្រូវមានជំងឺ<br>-សត្វល្អិតបំផ្លាញដំណាំស្រូវ<br>-ខ្វះប្រឡាយរង(ប្រឡាយជើងក្អែប)<br>-ខ្វះផ្លូវលំដឹកជញ្ជូនកសិផល<br>-បទល្មើសនេសាទ<br>-ពូជស្រូវមិនសុទ្ធល្អ | -ស្រូវមានជំងឺ<br>-សត្វល្អិតបំផ្លាញដំណាំស្រូវ<br>-ខ្វះប្រឡាយរង(ប្រឡាយជើងក្អែប)<br>-ខ្វះផ្លូវលំដឹកជញ្ជូនកសិផល<br>-បទល្មើសនេសាទ |
|---|---|---|---|
| កាឡានុវត្តភាព/ឱកាស | -ពង្រីកសមាជិកសហគមន៍កសិកម្ម<br>-បណ្ដុះបណ្ដាលធ្វើបង្ហាញដំណាំស្រូវ<br>-បណ្ដុះបណ្ដាលធ្វើបង្ហាញពីការចិញ្ចឹមសត្វ ជ្រូក<br>-បង្កើតសហគមន៍លក់សម្ភារៈកសិកម្ម<br>-បន្ថែមស្ថានីយ៍បូមទឹក<br>-បង្កើតរោងម៉ាស៊ីនកិនស្រូវសហគមន៍<br>-សាងសង់ទំនប់ស្ទាក់ទឹកនិង ទ្វារទឹក | -ស្ដារនិងជីកប្រឡាយរង (ប្រឡាយជើងក្អែប)<br>-សង់ផ្លូវលំដឹកកសិផល<br>-បង្កើតក្រុមផលិតពូជស្រូវ<br>-ផ្សព្វផ្សាយនិងអនុវត្តច្បាប់ជលផល | -ស្ដារនិងជីកប្រឡាយរង (ប្រឡាយជើងក្អែប)<br>-សង់ផ្លូវលំដឹកកសិផល<br>-បង្កើតក្រុមផលិតពូជស្រូវ<br>-ផ្សព្វផ្សាយនិងអនុវត្តច្បាប់ជលផល |

ប្រភព៖ *របាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំកំពង់គោ ២០១៨*

យោងតាមរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន បានបង្ហាញឱ្យឃើញថា នៅក្នុងឃុំមានប្រភពទឹកពី ១)ទឹកភ្លៀង ២)ទឹកស្ទឹងសែន ៣)អូរចំនួន ០៣ ដូចជា អូរតាសេក អូរតាឌុច និងទឹកអូតាឡោ ៤)បឹងចំនួន ០៦ ដូចជា បឹងព្រៃប្រស់ បឹងមហាពពាយ បឹងរៀល បឹងស្នែង បឹងព្រះគន្លង និងបឹងកូនសត្វ ៥)អាងស្តុកទឹកចំនួន០៤ ដូចជា អាងទឹកប្រាំបីពាន់ អាងទឹកពីរពាន់ អាងទឹកតាយាង(សហគមន៍) និងអាងយាយលី។ ទន្ទឹមនឹងនោះឃុំកំពង់គោមានប្រឡាយនាំទឹកពីប្រភពទឹកខាងលលើចំនួន ១៨ ខ្សែ ប្រវែង ២៥ ២៤៨,៣៩ ម៉ែត្រ នៅក្នុងនោះ ប្រឡាយរងមាន ២ ខ្សែ ប្រវែង ៥ ២៣៥,០៤ ម៉ែត្រ ដែលខ្សែទី ១ ភ្ជាប់ពីប្រឡាយនៅភាគខាងជើងភូមិបូពឹង ទៅឆ្ពោះទៅភាគខាងជើងនៃឃុំ(ប្រឡាយជីក)។ ខ្សែទី ២ ចេញពីភូមិបូពឹងឆ្ពោះទៅភាគខាងលិចនៃភូមិកំពង់គោលើ ព្រមទាំងប្រឡាយតូចៗមានចំនួន ១៦ ខ្សែ ប្រវែង ២០ ០១៣,៣៤ ម៉ែត្រ ។ ចំណែកទឹកក្រោមដីនៅក្នុងឃុំកំពង់គោ មានការប្រើប្រាស់តាមរយៈអណ្ដូងស្នប់សម្រាប់ស្រោចស្រព និងសម្រាប់ការប្រើប្រាស់ទូទៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋតែប៉ុណ្ណោះ ។ ប្រភពទឹកដែលនាំទឹកមកប្រើប្រាស់នៅក្នុងឃុំ បានមកពីស្ទឹងសែន និងទន្លេសាបតាមរយៈប្រឡាយរង ដែលឃុំបានជីក និងស្ដារសម្រាប់នាំយកទឹកមកស្រោចស្រពក្នុងភូមិសាស្ត្រស្រែប្រាំង។ ក្រៅពីស្ទឹងសែនឃុំមានបឹង ស្ទឹង អូរ អាង ស្រះទឹកដែលជាប្រភពទឹកបន្ទាប់បន្សំតែប៉ុណ្ណោះ។

តារាង 17៖ ប្រព័ន្ធធារាសាស្ត្រ

| ល.រ | ប្រភេទប្រឡាយ | ចំនួនប្រឡាយ | ប្រវែង(ម៉ែត្រ) |
|---|---|---|---|
| ១ | ទ្វារទឹក | ៦ | ៥,២៥ |
| ៣ | ប្រឡាយរង | ២ | ៥២៣៥,០៤ |
| ២ | ប្រឡាយតូច | ១៦ | ២០០១៣,៣៤ |
| **ប្រវែងប្រឡាយសរុប** | | **១៨** | **២៥២៤៨,៣៩** |

រូបភាព ៣៖ ប្រព័ន្ធធារាសាស្រ្ត



ផែនទី 5៖ ប្រព័ន្ធធារាសាស្រ្តឃុំកំពង់គោ




## ១.២.២.អាកាសធាតុ (ពិពណ៌នាតាមរដូវកាល)

នៅក្នុងឃុំកំពង់គោ ក៏ដូចជានៅទូទាំងខេត្ត គឺទទួលរបបខ្យល់ពីតំបន់ត្រូពិច ដែលមានអាកាសធាតុក្តៅ ហើយសើម។ របបខ្យល់មូសុង បានពាំនាំមកនូវចំនួនទឹកភ្លៀងយ៉ាងច្រើនមកជាមួយ ដែលអំណោយផលទៅដល់ការធ្វើកសិកម្មនានា និងដាំដំណាំផ្សេងៗ។

បើយោងទៅតាមប្រភពទិន្នន័យពីមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ធំ ប្រចាំស្រុកកំពង់ស្វាយ នៅក្នុងឆ្នាំ ២០១៧ បង្ហាញថាស្រុកកំពង់ស្វាយ មានភ្លៀងធ្លាក់ចំនួន ៩១ ដង ដែលមានបរិមាណទឹកភ្លៀងប្រចាំឆ្នាំចំនួន ១ ៣៦៥,៨ ម.ម ។

**អំពីសីតុណ្ហភាព៖**

- រដូវរងារ៖ ខែ វិច្ឆិកា ដល់ ខែ មីនា (២០ ទៅ ២៨ អង្សា)

- រដូវក្ដៅ៖ ខែ មីនា ដល់ ខែ ឧសភា (៣០ ទៅ ៣៥ អង្សា)

- រដូវភ្លៀង៖ ខែ ឧសភា ដល់ ខែ តុលា (២៣ ទៅ ៣០ អង្សា ជាមួយនិងការឡើងសំណើមទៅដល់ ៩០ ភាគរយ)នៅរដូវនេះជារៀងរាល់ឆ្នាំ គឺមានភ្លៀងធ្លាក់ខ្លាំង នៅពេលរសៀល និងល្ងាច។

នៅក្នុងឃុំកំពង់គោ មានសំណើមជាមធ្យម៥០ភាគរយ និងមានល្បឿនខ្យល់៧គីឡូម៉ែត្រ/១ម៉ោង។

តារាង 18៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ

| ខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| បរិមាណ ទឹកភ្លៀង | ១,៥ | ០ | ៧៣,៨ | ៧៥,៦ | ២១២,៥ | ៨៧,៣ | ២៥៦,៧ | ១៧៣,៥ | ៩៣,៥ | ២៦៣,៧ | ៩៦,៩ | ៣០,៨ |
| ចំនួនថ្ងៃ មានភ្លៀង | ១ | ០ | ៣ | ៥ | ១៥ | ៩ | ១៧ | ១១ | ១០ | ៩ | ៨ | ៣ |

ប្រភព៖ *មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ធំ ឆ្នាំ២០១៧*

ដ្យាក្រាម 3៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ




ប្រភព៖ *មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ធំ ឆ្នាំ២០១៧*

### ១.២.៣.ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន

ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍រួមមាន ផ្លូវគោក ផ្លូវដែក ផ្លូវទឹក និងផ្លូវអាកាស ។ បច្ចុប្បន្នឃុំកំពង់គោមានតែប្រព័ន្ធគមនាគមន៍ផ្លូវគោក និងផ្លូវទឹកប៉ុណ្ណោះ ហើយបានដើរតួយ៉ាងសំខាន់ក្នុងការសម្រួលដល់ការដឹកជញ្ជូន និងការធ្វើដំណើររបស់ប្រជាពលរដ្ឋនៅក្នុងឃុំនេះ ដែលនៅក្នុងនោះមានផ្លូវក្រាលគ្រួសក្រហមចំនួន ១ខ្សែ ប្រវែង ៩ ០៨៩,៣២ ម៉ែត្រ ចេញពីព្រំប្រទល់ឃុំក្តីដូងឆ្លោះទៅភូមិអូរតាសេកស្របនឹងស្ទឹងសែន រហូតដល់ភូមិស្ពឺបិទមាស និងផ្លូវក្រាលគ្រួសក្រហម ១ខ្សែទៀត ប្រវែង ១ ៣១០,២១ ម៉ែត្រ ចេញពីព្រំប្រទល់ឃុំក្តីដូង ស្របតាមបណ្តោយស្ទឹងសែនឆ្លោះទៅដល់ស្ថានីយ៍បូមទឹកភូមិកោះគ្របបាយ ដែលផ្លូវទាំងពីរខ្សែនេះ ជាច្រកចេញ-ចូលយ៉ាងសំខាន់របស់ឃុំដែលមានទំនាក់ទំនងតភ្ជាប់ជាមួយផ្លូវជាតិលេខ៦ និងផ្លូវវាងក្រុងស្ទឹងសែន ដោយឆ្លងកាត់សង្កាត់អូរកន្ធរ ព្រមទាំងមានផ្លូវផ្សេងៗទៀតគ្រប់គ្រាន់អាចតភ្ជាប់ទំនាក់ទំនងពីភូមិមួយទៅភូមិមួយ រួមទាំងអាចទំនាក់ទំនងទៅក្រៅឃុំបានយ៉ាងងាយស្រួល។ ចំណែកផ្លូវទឹកស្ទឹងសែន មានចរាចរចាប់ពីខែកញ្ញាទៅដល់ខែវិច្ឆិកា ដែលទឹកមាន

កម្ពស់ ៧ ទៅ ១០ម៉ែត្រ ល្បឿនទឹកហូរមាន ១០.០០០ម៣ ក្នុងមួយវិនាទីនៅក្នុងរដូវវស្សា ទូកម៉ាស៊ីនតូចៗអាចធ្វើចរាចរបានគ្រប់រដូវ ចំណែកទូកកាណូតធុនធំចាប់ពី ៥តោនឡើងអាចធ្វើចរាចរណ៍បានតែក្នុងរដូវវស្សាប៉ុណ្ណោះ ។ ផ្លូវទឹកនេះបានបម្រើដល់ការដឹកជញ្ជូន និងការធ្វើដំណើររបស់ប្រជាពលរដ្ឋទៅកាន់តំបន់ផ្សេងៗ ហើយជាពិសេសមកកាន់ទីរួមខេត្តកំពង់ធំ។

នៅក្នុងឃុំកំពង់គោ មានប្រព័ន្ធផ្លូវចំនួន ៣០ខ្សែ ប្រវែង ៦៥ ៣៥៦,៦៨ម៉ែត្រ នៅក្នុងនោះផ្លូវក្រាលគ្រួសក្រហមមានចំនួន ៦ខ្សែ ប្រវែង ២៣ ៦៨៩,៧៦ ម៉ែត្រ និងផ្លូវលំដីស ២៤ខ្សែ ប្រវែង ៤១ ៦៦៦,៩២ម៉ែត្រ ព្រមទាំងផ្លូវទឹកតាមដងស្ទឹងសែន។

តារាង 19៖ ប្រព័ន្ធផ្លូវដឹកជញ្ជូន

| ល.រ | ប្រភេទផ្លូវ | ចំនួនខ្សែផ្លូវ | ប្រវែង (ម៉ែត្រ) |
|---|---|---|---|
| ១ | ផ្លូវគ្រួសក្រហម ឬក្រាលថ្ម | ៦ | ២៣៦៨៩,៧៦ |
| ២ | ផ្លូវដីស ឬផ្លូវរទេះ | ២៤ | ៤១៦៦៦,៩២ |
| ប្រវែងផ្លូវសរុប | | ៣០ | ៦៥៣៥៦,៦៨ |

រូបភាព 4៖ ប្រព័ន្ធគមនាគមន៍



ផ្លូវលំដីសនៅក្នុងឃុំកំពង់គោ



ផ្លូវគ្រួសក្រហមនៅក្នុងឃុំកំពង់គោ

ផែនទី ៦៖ ហេដ្ឋារចនាសម្ព័ន្ធឃុំកំពង់គោ




## ១.២.៤.បរិក្ខាសាធារណៈ

### ក.ស្ថានភាពប្រើប្រាស់អគ្គិសនី

បេសកកម្មរបស់មន្ទីររ៉ែ និងថាមពលខេត្តកំពង់ធំ គឺដឹកនាំជំរុញការគ្រប់គ្រង និងសមាហរណកម្មលើវិស័យរ៉ែ និងថាមពលរួមទាំងប្រេងកាត ឧស្ម័ន និងអគ្គិសនី ក្នុងសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ចសង្គម នៅក្នុងមូលដ្ឋាន និងនៅក្នុងខេត្តកំពង់ធំ ក្នុងនាមជាសេធិការឱ្យក្រសួងរ៉ែ និងថាមពល ។

ដោយយោងទៅតាមទិន្នន័យមន្ទីរផែនការឆ្នាំ ២០១៧ បានបង្ហាញថា នៅក្នុងឃុំកំពង់គោ ប្រជាជនប្រើប្រាស់អាគុយសម្រាប់បំភ្លឺផ្ទះមានចំនួន ៤០៨ ខ្នងផ្ទះ ស្មើនឹង ២៨,៨ ភាគរយ បន្ទះសូឡាមានចំនួន ៦២៥ គ្រួសារ ស្មើនឹង ៤៤,១ ភាគរយ ។ នៅក្នុងឃុំពុំទាន់មានបណ្ដាញ អគ្គិសនីប្រើប្រាស់នៅឡើយនោះទេ ។

តារាង 20៖ ស្ថិតិអ្នកប្រើប្រាស់អគ្គិសនី

| បរិយាយ | ២០១៦ភាគរយ | ២០១៧ | |
|---|---|---|---|
| | | ភាគរយ | ចំនួនផ្ទះ |
| ផ្ទះបំភ្លឺដោយបណ្ដាញអគ្គិសនី | 0,0 | 0,0 | 0 |
| ផ្ទះបំភ្លឺដោយអាគុយ | ៣៨,៩ | ២៨,៨ | ៤០៨ |
| ផ្ទះបំភ្លឺដោយបន្ទះសូឡា | ៣២ | ៤៤,១ | ៦២៥ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់គោ ខែមេសា ឆ្នាំ២០១៨*

### ខ.ប្រព័ន្ធទឹកស្អាត

អាជ្ញាធរខេត្តកំពង់ធំ បានអំពាវនាវឱ្យប្រជាពលរដ្ឋ ដែលធ្លាប់ប្រើប្រាស់ទឹក ស្ទឹង ត្រពាំង ឬអណ្តូងដៃងាកមកបរិភោគទឹកស្អាតវិញ ដើម្បីជួយលើកកម្ពស់សុខភាពនិងលើកស្ទួយអនាម័យនៅជនបទ។ យោងទៅតាមទិន្នន័យមន្ទីរផែនការ ឆ្នាំ ២០១៧ បង្ហាញឱ្យឃើញថា នៅក្នុងឃុំកំពង់គោគ្រួសារមានទឹកស្អាតប្រើប្រាស់ចំនួន ៥៩០ គ្រួសារ ស្មើនឹង ៣៨,២ភាគរយ ដែលនៅក្នុងនោះទឹកអណ្តូងស្នប់ ឬអណ្តូងចម្រុះមានចំនួន ៣៤៩ គ្រួសារ ទឹកអណ្តូងជីកមានការការពារ ៣៥ គ្រួសារ និងទឹកភ្លៀងដែលមានការការពារ ២០៦ គ្រួសារ ចំណែកទឹកអណ្តូងជីកមិនមានការការពារ ០៤ គ្រួសារ ស្មើនឹង ០,៣ ភាគរយ ទឹកស្រះមាន១០២គ្រួសារ ស្មើនឹង ៦,៦ ភាគរយ និងទឹកពីប្រភពផ្សេងៗ (ទន្លេ ស្ទឹង អូរ ជ្រោះ)មានចំនួន ៨៤៧ គ្រួសារ ស្មើនឹង ៥៣,៩ភាគរយ ដែលមានចំនួនច្រើនជាងគេ។

តារាង 21៖ ស្ថិតិអ្នកប្រើប្រាស់ការប្រើប្រាស់ទឹក

| បរិយាយ | | ២០១៦ | ២០១៧ |
|---|---|---|---|
| សរុបគ្រួសារមានទឹកស្អាតប្រើប្រាស់ | | ៣២៣ | ៥៩០ |
| ក្នុងនោះ | ទឹកដែលឆ្លងកាត់ប្រព័ន្ធធ្វើទឹកឱ្យស្អាត | ០ | ០ |
| | ទឹកអណ្តូងស្នប់ឬអណ្តូងចម្រុះ | ៣២៣ | ៣៤៩ |
| | ទឹកអណ្តូងជីកមានការការពារ | ០ | ៣៥ |
| | ទឹកភ្លៀងដែលមានការការពារ | ០ | ២០៦ |
| %គ្រួសារមានទឹកស្អាតប្រើប្រាស់ | | ២១,១ | ៣៨,២ |
| ទឹកអណ្តូងជីកមិនមានការការពារ | | ៤ | ៤ |
| %គ្រួសារប្រើប្រាស់ទឹកអណ្តូងជីកមិនមានការការពារ | | ០,៣ | ០,៣ |
| ទឹកស្រះ | | ១០២ | ១០២ |
| %គ្រួសាប្រើប្រាស់ទឹកស្រះ | | ៦,៧ | ៦,៦ |
| ទឹកពីប្រភពផ្សេងៗ(ទន្លេ ស្ទឹង អូរ ជ្រោះ) | | ១១០០ | ៨៤៧ |
| %គ្រួសារប្រើប្រាស់ទឹកពីប្រភពផ្សេងៗ(ទន្លេ ស្ទឹង អូរ ជ្រោះ) | | ៧១,៩ | ៥៤,៩ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំកំពង់គោ ខែមេសា ឆ្នាំ២០១៨*

# ១.៣. ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

## ១.៣.១.ស្ថានភាពការកាន់កាប់ និងគ្រប់គ្រង

ផែនទី 7៖ ផែនទីប្រើប្រាស់ដីសាមញ្ញ



ផែនទី ៩៖ ផែនទីប្រើប្រាស់ដីលម្អិត



តារាង 22៖ តារាងរាយលម្អិតតាមប្រភេទនៃការប្រើប្រាស់ដីបច្ចុប្បន្ន

| **ប្រភេទដីប្រើប្រាស់**<br>(ឈ្មោះហៅតាមបច្ចេកទេស) | **បរិយាយ**<br>(ឈ្មោះហៅតាមអ្នកស្រុក) | **ទំហំ (ហិកតា)** | **ភាគរយ** |
|---|---|---|---|
| **ក.ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ** | | **១៥៨,០១** | **០,៥៦** |
| -ដីលំនៅឋានភូមិក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ដីភូមិ | ១៥៨,០១ | ០,៥៦ |
| **ខ.ដីកសិកម្ម** | | **១៥២៧៣,៨៩** | **៥៤,១៨** |
| - ដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ដីស្រែប្រាំង | ១៤៤,៨៤ | ០,៥២ |
| - ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ដីស្រែប្រាំង | ៥៤០០,៤៩ | ១៩,១៦ |
| - ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប | ដីស្រែប្រាំង | ៩៧២៨,៥៦ | ៣៤,៥១ |
| **គ.ដីព្រៃ/គម្របព្រៃឈើ** | | **៩៤៥១,២៥** | **៣៣,៥៣** |
| **គ.១.ព្រៃតាមដងស្ទឹង** | ព្រៃតាមដងស្ទឹង | **៥៧,១១** | **០,២០** |
| **គ.២.ព្រៃលិចទឹក** | **ព្រៃលិចទឹក** | **៩៣៩៤,១៤** | **៣៣,៣២** |
| **ឃ.ផ្ទៃទឹក និងខ្សែទឹក** | | **៣២៩៨,២៩** | **១១,៧០** |
| **ឃ.១.បឹង** | បឹង | **៩៩១,១៨** | ៣,៥២ |
| **ឃ.២.ស្ទឹងមានទឹកតាមរដូវ** | **ស្ទឹងសែន** | **៤១០,២៥** | **១,៤៦** |
| **ឃ.៣.អាងស្តុកទឹក** | | ១៨៩២,០៥ | ៦,៧១ |
| -អាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប | អាងទឹក | ២៨៣,៥៤ | ១,០១ |
| -អាងស្តុកទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាប | អាងទឹក | ១៦០៨,៥១ | ៥,៧១ |
| **ឃ.៤.ស្រះក្នុងតំបន់២ជុំវិញបឹងទន្លេសាប** | **ស្រះទឹក** | **៤,៨១** | **០,០២** |
| **ផ្ទៃដីឃុំសរុប** | | **២៨១៩១,៤៤** | ១០០ |

ក.ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ

**-ដីលំនៅឋានភូមិក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

ដីលំនៅឋានភូមិ គឺជាដីដែលត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានមានលាយសួនដំណាំ និងឈើហូបផ្លែនៅជុំវិញ។ នៅក្នុងឃុំកំពង់គោ មានដីលំនៅឋានភូមិ ទំហំផ្ទៃដីសរុបចំនួន ១៥៨,២៣ ហិកតា ភាគច្រើនស្ថិតនៅសងខាងតាមបណ្តោយស្ទឹងសែន ដែលស្ថិតនៅក្នុងតំបន់២ជុំវិញបឹងទន្លេសាប មានចំនួន៥ភូមិ គឺភូមិកំពង់គោលើ កំពង់គោក្រោម ខ្សាច់ជីរស់ បូពឹង និងភូមិកោះគ្របបាយ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំកំពង់គោ នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីលំនៅឋាន ភូមិទាំងអស់ ជាតំបន់ទំនាបមធ្យម ដែលមានប្រភេទដីខ្សាច់ល្បាយ(ពណ៌ប្រផេះ) ល្បាប់ ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមអាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ ។ ដីលំនៅឋានភូមិក្នុងតំបន់២ជុំវិញបឹងទន្លេសាប នៅក្នុងពេលបច្ចុប្បន្ននេះ ត្រូវបានប្រជាពលរដ្ឋ ប្រើប្រាស់សម្រាប់ការតាំងលំនៅឋានរស់នៅ។

រូបភាព 5៖ លំនៅឋានភូមិក្នុងតំបន់២ជុំវិញបឹងទន្លេសាប





**ខ.ដីកសិកម្ម**

នាពេលបច្ចុប្បន្ននេះ ដីស្រែប្រាំងនៅក្នុងឃុំកំពង់គោ មានទំហំផ្ទៃដីសរុបចំនួន ១៥ ២៥៧,៦៥ ហិកតា ភាគច្រើនស្ថិតនៅភាគកើតនៃឃុំ និងមានចំនួនតិចតួចស្ថិតនៅភាគខាងលិចនៃឃុំ ដែលបច្ចុប្បន្នបាន និងកំពុងប្រើប្រាស់ជាដីស្រែប្រាំង ហើយស្ថិតនៅតាម ៣តំបន់ផ្សេងៗគ្នា គឺតំបន់១ តំបន់២ និងតំបន់៣ ដូចមានរៀបរាប់ខាងក្រោម៖

**-ដីស្រែប្រាំងក្នុងតំបន់១ ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងនៅក្នុងតំបន់១ជុំវិញបឹងទន្លេសាប ស្ថិតនៅភាគខាងកើតឆៀងខាងជើងនៃឃុំ រហូតទល់នឹងព្រំប្រទល់ឃុំត្រពាំងឫស្សី ដែលមានទំហំផ្ទៃដីសរុបចំនួន ១៤៣,៤ ហិកតា។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំកំពង់គោនៃរបាយការណ៍វិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំ ដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាប គឺជាតំបន់ទំនាបលិចទឹកតាមរដូវ មានប្រភេទដីកណ្តេង និងដីខ្លាញ់ក្តាម (ពណ៌ក្រហម) ជាដីកម្មសិទ្ធិឯកជន ដែលត្រូវបានកាន់កាប់ដោយប្រជាពលរដ្ឋ ប៉ុន្តែមិនទាន់បានដំណើការចុះបញ្ជីកាន់កាប់ដី ដែលមានលក្ខណៈប្រព័ន្ធនោះទេ។ ដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាប មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និងស្ទឹងសែន ដែលបាននាំទឹកមកស្រោចស្រពតាមរយៈប្រឡាយកាវ៉ាក់ និងប្រឡាយឯកជន។

**-ដីស្រែប្រាំងក្នុងតំបន់២ ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប ស្ថិតនៅភាគខាងកើតឆៀងខាងជើងនៃឃុំ បន្តពីដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាបទៅប៉ែកកណ្តាលនៃឃុំ មានទំហំផ្ទៃដីសរុបចំនួន ៥ ៣៨៥,៦៩ ហិកតា ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំកំពង់គោនៃរបាយការណ៍វិភាគប្រព័ន្ធកេ្សត្រ-បរិស្ថាន ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាតំបន់ទំនាបលិចទឹកនៅតាមរដូវ មានប្រភេទដីកណ្តេង ខ្លាញ់ក្តាម (ពណ៌ក្រហម) ហើយជាដីសាធារណៈរបស់រដ្ឋ ដែលមិនទាន់ត្រូវបានចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធនោះទេ ហើយប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងអ្វីនោះឡើយ។ ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ស្ទឹងសែន អូរតាឌុច អូរតាសេក និងទឹកអូរតាឡោ ដែលបាននាំទឹកពីភាគខាងជើងនៃឃុំមកស្រោចស្រពតាមរយៈប្រឡាយការីតា ប្រឡាយពលកម្ម ប្រឡាយកាវ៉ាក់ ប្រឡាយអង្គរ ប្រឡាយចន្ទី ប្រឡាយព្រះគន្លង និងប្រឡាយឯកជន។

**-ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ស្ថិតនៅក្នុងតំបន់ការពារព្រៃលិចទឹក នៅភាគខាងលិចឆៀងខាងត្បូងនៃឃុំមានទំហំផ្ទៃដីសរុបចំនួន ៩ ៧២៨,៥៦ ហិកតា ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំកំពង់គោនៃរបាយការណ៍វិភាគប្រព័ន្ធកេ្សត្រ-បរិស្ថាន ដីស្រែប្រាំងនៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាបជាតំបន់ទំនាបលិចទឹកតាមរដូវ និងលិចទឹកអចិន្ត្រៃយ៍ ដែលមានប្រភេទដីកណ្តេងខ្លាញ់ក្តាម(ពណ៌ក្រហម) ដីពពាយកណ្តុរ(ពណ៌ខ្មៅ) និងដីមមោក ជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅក្នុងតំបន់ដែនព្រៃលិចទឹក ដែលហាមការកាប់រានដី ការដុតបំផ្លាញការរំលោភកាន់កាប់ដីព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប និងការសាងសង់សំណង់គ្រប់ប្រភេទ ។ ករណីដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាបនេះ ជាដីអាស្រ័យផលពិតប្រាកដរបស់ប្រជាពលរដ្ឋដែលរស់នៅឃុំកំពង់គោពិតមែន ត្រូវស្នើសុំធ្វើការដោះស្រាយ ក្នុងការផ្តល់ដីស្រែនៅក្នុងតំបន់នេះពីរាជរដ្ឋាភិបាល ដោយឈរលើឯកសារលិខិតបទដ្ឋានគតិយុត្ត និងបទបញ្ជានានារបស់រាជរដ្ឋាភិបាល ហើយប្រសិនបើមានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យឆ្លៀលដីនេះជូនមែន ក៏ដីនេះមិនមែនជាដីកម្មសិទ្ធិរបស់ប្រជាជនដែរ ប្រជាជនគ្រាន់តែអាចមានសិទ្ធិកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ ។ ដីស្រែប្រាំងនៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាបមានប្រភពទឹកស្រោចស្រពមកពីទឹកភ្លៀង បឹងព្រៃប្រស់ បឹងមហាពពាយ បឹងរាល បឹងបរស្វែង បឹងព្រះគន្លង បឹងកូនសត្វ អាងទឹកប្រាំបីរយ ទឹកអាងពីរពាន់ អាងតាយាង អាងយាយលី (ឯកជន) ដែលនាំទឹកមកស្រោចស្រពតាមរយៈប្រឡាយសុខមន្ទី។

រូបភាព ៦៖ ស្រូវប្រាំង



ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប



ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប

## គ.ដីព្រៃ/គម្របព្រៃឈើ

### គ.១.ព្រៃតាមដងស្ទឹង

ឃុំកំពង់គោមានព្រៃតាមដងស្ទឹងសែន ដែលមានទំហំ ៥៧,១១ ហិកតា ដែលសម្បូរទៅដោយដើមឈើចំរុះដុះលាយឡំគ្នា មានដើមត្រសេក ដើមអំពិលទឹក ដើមភ្នំភ្លើង ត្រល់ កប្បាស់ព្រៃ ស្មាច់ និងដើមរាំងជាដើម ហើយដើមឈើទាំងនេះ មានសារៈប្រយោជន៍ជួយការពារការហូរច្រោះបាក់ដី និងជាជម្រកត្រីមួយយ៉ាងសំខាន់នៅរដូវត្រីពងកូន។ បច្ចុប្បន្ននេះ ព្រៃឈើដែលដុះតាមមាត់ស្ទឹងទាំងនោះមានការកាប់បំផ្លាញពីប្រជាពលរដ្ឋយើង ដើម្បីធ្វើជាសម្រាស់ជម្រកត្រី កាប់ដើម្បីធ្វើឧសដុត និងជាពិសេសការដុតព្រៃដើម្បីចាប់សត្វ ដូចជាអណ្តើក ពស់ សំប៉ុច និងឃ្មុំជាដើម។

រូបភាព 7៖ ព្រៃតាមដងស្ទឹង



### គ.២.ព្រៃលិចទឹក

ព្រៃលិចទឹកនៅក្នុងឃុំកំពង់គោ មានចំនួន ០៣ កន្លែង ស្ថិតនៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ដែលក្នុងនោះ ទីតាំងទី១ ស្ថិតនៅភាគខាងជើងឆៀងខាងលិចឃុំ ទីតាំងទី២ ស្ថិតនៅភាគខាងលិចផ្នែកកណ្តាលនៃឃុំ និងទីតាំងទី៣ ស្ថិតនៅចុងភាគខាងត្បូងនៃឃុំ មានទំហំផ្ទៃដីសរុបចំនួន ៩ ៣៩៤,១៤ ហិកតា ដែលសម្បូរទៅដោយដើមឈើចម្រុះ ដុះលាយឡំគ្នាដូចជា ដើមភ្នំភ្លើង ត្រស់ កប្បាសព្រៃ ស្មាច់ និងដើមរាំងជាដើម ។ ព្រៃលិចទឹកទាំងអស់នេះត្រូវបានហាម ដាច់ខាតក្នុងការកាប់រាន ការដុតបំផ្លាញ ការរំលោភកាន់កាប់ដីព្រៃលិចទឹក និងការសាងសង់សំណង់គ្រប់ប្រភេទ ។

រូបភាព 8៖ ព្រៃលិចទឹក



### ឃ.ផ្ទៃទឹក និងខ្សែទឹក

### ឃ.១.បឹង

នៅឃុំកំពង់គោមានបឹងចំនួន ០៥ ទីតាំង ដូចជា បឹងរៀល បឹងស្នែង បឹងព្រះគន្លង បឹងមហាពពាយ និង បឹងកូនសត្វ ដែលមានទំហំផ្ទៃដីសរុបចំនួន ៩៩១,១៨ ហិកតា។ បឹងធម្មជាតិទាំងនេះ ជាដីសាធារណៈរបស់រដ្ឋ

ហើយបច្ចុប្បន្ននេះ ត្រូវបានប្រើប្រាស់ សម្រាប់ការស្រោចស្រពដំណាំកសិកម្ម ជាពិសេសស្រែប្រាំង និងប្រើប្រាស់ផ្សេងៗទៀតតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ។

រូបភាព ៩ ៖ បឹងធម្មជាតិ



### ឃ.២.ស្ទឹងមានទឹកតាមរដូវ

នៅក្នុងឃុំកំពង់គោមានស្ទឹងចំនួន ០១ ខ្សែ គឺស្ទឹងសែន ដែលមានទំហំផ្ទៃដីសរុបចំនួន ៤១០,២៥ ហិកតា ជាដីសាធារណៈរបស់រដ្ឋ ។ ស្ទឹងនេះ ហូរកាត់ឃុំពីកើតទៅលិច និងជាប្រភពទឹកដ៏សំខាន់ សម្រាប់ការស្រោចស្រពដំណាំកសិកម្ម ជាពិសេសស្រែប្រាំង និងប្រើប្រាស់ផ្សេងៗទៀតទៅតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង។

រូបភាព 10៖ ទិដ្ឋភាពស្ទឹងសែន



### ឃ.៣.អាងស្តុកទឹក

បច្ចុប្បន្ននេះ អាងស្តុកទឹកនៅក្នុងឃុំកំពង់គោមាន ០៧កន្លែង ទំហំផ្ទៃដីសរុបចំនួន ១៨៩២,០៥ហិកតា ស្ថិតនៅភាគខាងត្បូងនៃឃុំលាយឡំជាមួយនឹងដីស្រែប្រាំង ដែលបច្ចុប្បន្ននេះ បាននិងកំពុងប្រើប្រាស់ជាអាងស្តុកទឹក ហើយស្ថិតនៅតាម ០២ តំបន់ ផ្សេងៗគ្នា គឺតំបន់២ និងតំបន់៣ ដូចមានរៀបរាប់ខាងក្រោម៖

**-អាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

អាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាបមាន ១ កន្លែង និងមានផ្ទៃដីសរុបចំនួន ២៨៣,៥៤ ហិកតា។ អាងស្តុកទឹកទាំងនេះជាដីសាធារណៈរបស់រដ្ឋដែលប្រជាពលរដ្ឋមានសិទ្ធត្រឹមតែអាស្រ័យផលតែប៉ុណ្ណោះ ដោយមិនមានសិទ្ធិក្នុងការចាត់ចែងឡើយ ហើយក្នុងបច្ចុប្បន្ននេះ ត្រូវបានប្រើប្រាស់សម្រាប់ការស្រោចស្រព ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង។

**-អាងស្តុកទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាប**

អាងស្តុកទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាបមាន ០៦ កន្លែង ទំហំផ្ទៃដីសរុបចំនួន ១ ៦០៨,៥១ហិកតា។ អាងស្តុកទឹកនេះ ជាដីសាធារណៈរបស់រដ្ឋស្ថិតក្នុងតំបន់ដែនព្រៃលិចទឹក ដែលហាមការរំលោភកាន់កាប់អាងទឹកស្តុកទាំងនេះ ។

រូបភាព 11៖ អាងស្តុកទឹក



ឃ.៤.ស្រះ

ស្រះទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាបមាន ០៨ កន្លែង ទំហំផ្ទៃដីសរុបចំនួន ៤,៨១ ហិកតា។ ស្រះទឹកទាំងនេះ ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋមានសិទ្ធិត្រឹមកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងឡើយ ហើយក្នុងបច្ចុប្បន្ននេះត្រូវបានប្រើប្រាស់សម្រាប់ការស្រោចស្រព និងប្រើប្រាស់ផ្សេងៗទៀតតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង។

រូបភាព 12៖ ស្រះទឹក



ពាក់ព័ន្ធបញ្ហាផ្សេងៗ នៅក្នុងការប្រើប្រាស់ដីនៅក្នុងឃុំកំពង់គោ តាមរយៈការសម្ភាសន៍លោកមេឃុំ បានឱ្យដឹងថា មានប្រជាពលរដ្ឋក្នុងឃុំចំនួន ២៥០ គ្រួសារ មិនមានដីសម្រាប់សាងសង់លំនៅឋាន និង ៣១៣ គ្រួសារ មិនមានដីធ្វើរបរកសិកម្មឡើយ។ ក្នុងចំណោមប្រជាពលរដ្ឋទាំងនេះ មានមួយចំនួនរស់នៅលើដីចិញ្ចើមផ្លូវ រស់នៅលើដីកម្មសិទ្ធិរបស់គេផ្សេង ព្រមទាំងមួយចំនួនទៀត ពួកគាត់រស់នៅជាមួយឪពុកម្តាយ។ ចំណែកបញ្ហាទំនាស់នៅក្នុងការប្រើប្រាស់ដីនៅក្នុងឃុំកំពង់គោវិញ ពុំមានចេញជារូបភាពធំដុំគួរឱ្យកត់សម្គាល់ឡើយ ដោយសារតែដីក្នុងឃុំទាំងមូល កំពុងដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធ។

### ១.៣.២.ផលិតកម្មកសិកម្ម

#### ក.ផលិតកម្មដំណាំស្បៀង

ផលិតកម្មដំណាំស្បៀងនៅក្នុងឃុំកំពង់គោ បានផ្តោតសំខាន់ទៅលើផលិតកម្មដំណាំស្រូវ ហើយដំណាំនេះបានដើរតួយ៉ាងសំខាន់ នៅក្នុងការអភិវឌ្ឍឃុំដោយសារផលិតផលស្រូវ ក្រៅពីប្រជាពលរដ្ឋបានទុកផ្គត់ផ្គង់សម្រាប់ការហូបចុក និងមាននៅសល់បានទុកលក់ សម្រាប់បំពេញតម្រូវការចាយវាយចាំបាច់ក្នុងជីវភាពរស់នៅផងដែរ។ ដំណាំស្រូវបានផលិតនៅលើទំហំផ្ទៃដីស្រែចំនួន ១៥២៥៧,៦៥ហិកតា ជាប្រភេទដីកណ្តោង ខ្លាញ់ក្តាម (ពណ៌ហាម)នៅពេសពេញស្ទើរទូទាំងឃុំ លើកលែងតែដីលំនៅឋាន និងព្រៃលិចទឹកប៉ុណ្ណោះ ដែលបច្ចុប្បន្នធ្វើស្រែបាន ២ ដង នៅក្នុងមួយឆ្នាំ (ស្រែប្រាំង និងស្រូវប្រដេញទឹក) ហើយនិយមប្រើពូជស្រូវ ៥៤៥១ (VN) និងស្រូវសែនក្រអូប(សហគមន៍) ព្រមទាំងប្រភេទដីពពាយកណ្តុរ (ពណ៌ខ្មៅ) និងដីមមោក ស្ថិតនៅប៉ែកខាងលិចភាគខាងត្បូងនៃឃុំ ធ្វើស្រែបានពីរដងក្នុងមួយឆ្នាំក្នុងរដូវប្រាំង គឺស្រែប្រាំងនិងស្រូវប្រដេញទឹក ហើយនិយមប្រើពូជស្រូវ ៥៤៥១ (VN) និងស្រូវសែនក្រអូប (សហគមន៍)។ ក្នុងការស្រោចស្រពសម្រាប់ដំណាំស្រូវនៅក្នុងឃុំកំពង់គោត្រូវបានប្រើប្រាស់ទឹកពីប្រភពទឹកស្ទឹងសែន ស្ទឹងតូច ទឹកអូរតាសេក និងទឹកអូតាឡោ ទឹកអូរតាឌុច បឹងព្រៃប្រស់ បឹងមហាពពាយ បឹងរាល បឹងបរស្នែង បឹងកូនសត្វ អាងទឹកប្រាំរយ និងទឹកអាងពីរពាន់ អាងតាឃាង និងអាងយាយលី(ឯកជន) ដោយមានប្រើប្រាស់ប្រព័ន្ធប្រឡាយមួយចំនួន ដែលបច្ចុប្បន្ននៅមានការខ្វះខាតនៅឡើយ។ ជាទូទៅក្នុងឃុំកំពង់គោប្រជាពលរដ្ឋបានទទួលផលស្រូវប្រាំងជាមធ្យម ០៤ តោន/ហ.ត និងស្រូវបង្កើនរដូវជាមធ្យម ០៨ តោន/ហ.ត ហើយបានពិនិត្យឃើញថាក្នុងឆ្នាំ ២០១៧ នេះ ក្នុងឃុំទទួលបានផលស្រូវសរុបចំនួន ១៣៩ ៦៩២ តោន នៅក្នុងនោះស្រូវទិន្នផលស្រូវប្រាំងមានចំនួន ៤៦ ៥៦៤ តោន/ហ.ត និងទិន្នផលស្រូវបង្កើនរដូវចំនួន ៩៣ ១២៨ តោន/ហ.ត ដោយប្រជាពលរដ្ឋទុកហូបចុក ៣០ ភាគរយ ទុកពូជ១០ភាគរយ និងសល់ពីនេះបានលក់ចេញចំនួន ៨៣ ៨១៥ តោន ក្នុងតម្លៃជាមធ្យម ៧៣១ រៀល/គ.ក្រ ដែលទទួលបានចំណូលសរុបប្រមាណ ៦១២ ៦៩លានរៀល។

តារាង 23៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - ភាពរាំងស្ងួត<br>- សត្វល្អិតបំផ្លាញ និងជម្ងឺលើដំណាំស្រូវ<br>- ប្រើប្រាស់ពូជស្រូវតាមទម្លាប់<br>- ខ្វះបច្ចេកទេសប្រើប្រាស់ជីគីមី និងថ្នាំកសិកម្ម<br>- ខ្វះបច្ចេកទេសដាំ និងថែទាំដំណាំស្រូវ<br>- ប្រព័ន្ធប្រឡាយមានស្រាប់រងការខូចខាត (រាក់) | - មានដីស្រែធំទូលាយរហូតដល់ ៥៤,១៨ភាគរយនៃផ្ទៃដីសរុប<br>- ស្ថានភាពដីស្រែជាវាលទំនាប អាចមានលទ្ធភាពនាំទឹកពីប្រភពទឹកស្ទឹងសែន ស្ទឹងតូច បឹង អូរ អាងស្តុកទឹក មកផ្គត់ផ្គង់ការស្រោចស្រពដើម្បីធ្វើស្រែបង្កើនរដូវ២-៣ដងក្នុងមួយឆ្នាំបាន |

| | |
|---|---|
| - ខ្វះខាតប្រព័ន្ធប្រឡាយនាំទឹកស្រចស្រព<br>- ខ្វះកម្លាំងពលកម្ម(ចំណាកស្រុកច្រើន) | - មានប្រព័ន្ធប្រឡាយស្រាប់<br>- មានកម្លាំងពលកម្មច្រើន<br>- មានគោលការណ៍ជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុង ការពង្រឹងតួនាទីលើវិស័យកសិកម្ម<br>- មានគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ របស់រាជរដ្ឋាភិបាល។ |

### ខ.ផលិតកម្មដំណាំរួមផ្សំ

ផលិតកម្មដំណាំរួមផ្សំ នៅក្នុងឃុំកំពង់គោបច្ចុប្បន្ន ត្រូវបានប្រជាពលរដ្ឋធ្វើការដាំដុះជាលក្ខណៈគ្រួសារនៅជុំវិញដីលំនៅឋាន និងតំបន់ស្រែប្រាំងបន្ទាប់ពីប្រមូលផលរួច ជាប្រភេទដីខ្សាច់ល្បាយ (ពណ៌ប្រផេះ) និងដីល្បាប់មានដំណាំដូចជា៖ សណ្តែក ស្ពៃ ត្រកួន ត្រសក់ ននោង ល្ពៅ។ល។ ដែលទទួលបានការ ទឹកស្ទឹងសែន ទឹកអូរតាសេក ស្ទឹងតូច និងទឹកអូតាឡោហើយផលទទួលបានសម្រាប់ផ្គត់ផ្គង់ការហូបចុកនិងលក់ដូរបន្តិចបន្តួចដើម្បីបានកម្រៃខ្លះក្នុងការជួយបំពេញញការខ្វះខាតក្នុងជីវភាពគ្រួសារតែប៉ុណ្ណោះ។

តារាង 24៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - ការយល់ដឹងពីបច្ចេកទេសដាំដំណាំរបស់ប្រជាពលរដ្ឋនៅមានកម្រិត។<br>- សត្វល្អិតបំផ្លាញ<br>- ដំណាំកើតមានជម្ងឺ<br>- ខ្វះខាតទឹកស្រោចស្រពនៅរដូវប្រាំង | - មានដីល្បាប់តាមមាត់ស្ទឹង<br>- មានដីនៅជុំវិញលំនៅឋាន<br>- មានប្រភពទឹកស្ទឹង បឹង អូរ អាងស្តុកទឹក ស្រះ និងទឹកក្រោមដី សម្រាប់ការស្រោចស្រព<br>- ប្រជាពលរដ្ឋមានការយល់ដឹងពីសារៈប្រយោជន៍នៃដំណាំរួមផ្សំដែលអាចជួយផ្គត់ផ្គង់ដល់ការហូបចុក កាត់បន្ថយបានលើការចំណាយ ហើយបានលក់ខ្លះដោះស្រាយដល់ជីវភាពរស់នៅប្រចាំថ្ងៃ។ |

### គ.ផលិតកម្មឧស្សាហាកម្ម

នៅក្នុងឃុំកំពង់គោ មិនមានប្រជាពលរដ្ឋធ្វើការដាំដុះដំណាំឧស្សាហាកម្មនោះទេ ដោយសារនៅតំបន់នេះជាតំបន់ទំនាបលិចទឹក មិនសមស្របសម្រាប់ដំណាំឧស្សាហាកម្មនោះឡើយ។

## ១.៣.៣.ធនធានធម្មជាតិ

### ក.ធនធានព្រៃឈើ

បច្ចុប្បន្ននៅក្នុងឃុំកំពង់គោមានធនធានព្រៃឈើគ្របដណ្តប់នៅលើផ្ទៃដីប្រមាណ ៩៤៥ ១,២៥ ហិកតាស្មើនឹង ៣៣,៥៣ ភាគរយ នៃផ្ទៃដីឃុំទាំងមូល ដែលក្នុងនោះមានប្រភេទព្រៃតាមដងស្ទឹងទំហំ ៥៧,១១ ហិកតាស្ថិតនៅតាមបណ្តោយដងស្ទឹងសែន ពីកើតទៅភាគខាងលិច ហើយត្រូវបានគ្រប់គ្រង និងថែទាំដោយសហគមន៍មូលដ្ឋាននិងអាជ្ញាធរដែនដីភូមិឃុំ (ជាដីកម្មសិទ្ធិរបស់រដ្ឋ) ដែលមានមុខងារសម្រាប់ទប់ទល់ការហូរច្រោះបាក់ដីមាត់ស្ទឹង និងសម្រាប់ជាឧសដុត និងសម្រាប់យកធ្វើជាសម្រាស់ត្រីជាដើម។ ចំណែកព្រៃលិចទឹកមាន ៣ កន្លែង

ដែលស្ថិតនៅភាគខាងជើងនៃឃុំ ១ កន្លែង ផ្នែកកណ្តាលនៃឃុំ ១ កន្លែង និងស្ថិតនៅចុងភាគខាងត្បូងនៃឃុំ ១ កន្លែង ព្រមទាំងមានទំហំផ្ទៃដីសរុបចំនួន ៩ ៣៩៤,១៤ ហិកតា ដែលជាដែនការពារព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប ហាមដាច់ខាតការកាប់រាន ការដុតបំផ្លាញ ការរំលោភកាន់កាប់ដីព្រៃលិចទឹក និងការសាងសង់សំណង់គ្រប់ប្រភេទ ។

តារាង 25៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបស័គ្គ | ឱកាស |
|---|---|
| - មានការកាប់បំផ្លាញឈើសម្រាប់ធ្វើឧសដុត និងប្រើប្រាស់ផ្សេងៗ<br>- មានការកាប់បំផ្លាញឈើដើម្បីយកដីកាន់កាប់<br>- ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីផលប្រយោជន៍នៃដើមឈើនៅមានកម្រិត<br>- ការអនុវត្តច្បាប់ព្រៃឈើនូវទាន់បានពេញលេញ<br>- ការផ្សព្វផ្សាយច្បាប់ពុំទាន់បានទូលំទូលាយនៅឡើយ | - មានច្បាប់និងអនុក្រឹត្យស្តីពីព្រៃឈើ<br>- មានសហគមន៍ព្រៃឈើការពារ<br>- មានដីព្រៃឈើធម្មជាតិ<br>- មានរដ្ឋបាលព្រៃឈើជាសមត្ថកិច្ចគ្រប់គ្រងព្រៃឈើ |

ខ.ធនធានជលផល

បច្ចុប្បន្ននេះ នៅក្នុងឃុំកំពង់គោ មានស្ទឹងចំនួន ០២ គឺស្ទឹងសែន និងស្ទឹងតូច ដែលមានទំហំផ្ទៃដីសរុប ៤១០,២៥ ហិកតា មានបឹងចំនួន ១៦ គឺបឹងឆ្មៅ បឹងព្រៃប្រស់ បឹងទទឹងថ្ងៃ បឹងស្លាត បឹងកំពីងពួយរាល បឹងព្រះស្ទែង បឹងធ្មឹម បឹងអាជ្រូក បឹងអន្ទោង បឹងរាំងទេ បឹងព្រះគន្លង បឹងពងរាប បឹងអាខ្វាក់តូច បឹងអាខ្វាក់ធំ បឹងដំរីស្លាប់ បឹងដំរីស្អុយ បឹងអ្នកតា បឹងមហាពពាយហើយភាគច្រើននៅភាគខាងលិច និងភាគខាងត្បូង ក្នុងតំបន់ស្រែប្រាំង ដែលមានផ្ទៃដីសរុបទំហំ ៩៩១,១៨ ហិកតា ព្រមទាំងមានអាងស្តុកទឹក ៧កន្លែង គឺអាងតាយាង អាងយាយលី អាងទឹកប្រាំរយ និងអាងទឹកពីរពាន់ ដែលមានផ្ទៃដីសរុប ១ ៨៩២,០៥ ហិកតា និង មានស្រះទឹកចំនួន ៧កន្លែង ដែលស្រះនីមួយៗ ស្ថិតនៅលាយឡំជាមួយនឹងតំបន់លំនៅឋាន ដែលភាគច្រើននៅប៉ែកខាងកើតឆៀងខាងជើងនៃឃុំ មានទំហំផ្ទៃដីសរុប ៤,៨១ ហិកតា។ ស្ទឹង បឹង អាង និងស្រះទាំងអស់នេះមានធនធានជលផលជាច្រើនប្រភេទ ដូចជា ត្រីរ៉ស់ ត្រីឆ្តោរ ត្រីអណ្តែង ត្រីក្រាញ់ ត្រីទីឡាបស្យា អន្ទង់ ក្តាម ខ្យង កង្កែប អណ្តើក និងពស់ជាដើម។ ហើយត្រូវបានធ្វើការនេសាទដោយប្រជាជនក្នុងឃុំ ជាលក្ខណៈគ្រួសារតាមរយៈការប្រើប្រាស់ឧបករណ៍ ដូចជា សំណាញ់ មុង ទ្រ អួន និងសន្ទូច ជាលក្ខណៈប្រពៃណី ដែលផលនេសាទទាំងនេះសម្រាប់តែការហូបចុក និងលក់ដូរតិចតួចប៉ុណ្ណោះ។

តារាង 26៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបស័គ្គ | ឱកាស |
|---|---|
| - មានការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិតមិនសមស្របលើដំណាំកសិកម្ម នាំឱ្យមានការថយចុះបរិមាណធនធានជលផល<br>- ការប្រើឧបករណ៍នេសាទខុសច្បាប់។ | - មានស្ទឹង បឹង អាងស្តុកទឹក ស្រះ និងស្រែ ដែលអំណោយផលដល់ធនធានជលផល<br>- មានច្បាប់ជលផល<br>- ប្រើប្រាស់ឧបករណ៍បែបប្រពៃណី ។ |

គ.ធនធានរ៉ែ

បច្ចុប្បន្ននៅក្នុងឃុំកំពង់គោ មានធនធានរ៉ែ ជាប្រភេទរ៉ែខ្សាច់មួយមុខគត់ សម្រាប់ប្រើប្រាស់ទៅលើវិស័យសំណង់ ស្ថិតនៅតាមដងស្ទឹងសែន ដែលមានក្រុមហ៊ុនឯកជនមួយ បានទទួលអាជ្ញាប័ណ្ណអនុញ្ញាតឱ្យធ្វើអាជីវកម្មពីមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពង់ធំ។ ការធ្វើអាជីវកម្មខ្សាច់នេះ ឃុំមិនបានទទួលចំណូលអ្វីនោះទេ ដោយសារក្រុមហ៊ុនជាអ្នកបង់ថ្លៃសេវា ពន្ធចំណូលជូនទៅរដ្ឋប៉ុណ្ណោះ និងពុំមានទិន្នន័យពីទំហំនៃចំណូលទាំងនេះទេ។ ការធ្វើអាជីវកម្មលើរ៉ែខ្សាច់នេះ មានផលប៉ះពាល់ទៅដល់សង្គម និងបរិស្ថាន ដូចជា បាក់ច្រាំងស្ទឹង ដីហុយទៅលើលំនៅឋានរបស់ប្រជាពលរដ្ឋដែលរស់នៅតាមដងផ្លូវដឹកជញ្ជូនខ្សាច់ចេញ និង ធ្វើឱ្យខូចខាតផ្លូវ ជាដើម។ល។

## ១.៤.ទីផ្សារ និងខ្សែសង្វាក់ផលិតផល

### ១.៤.១.ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ

បច្ចុប្បន្ននេះ នៅក្នុងឃុំកំពង់គោ មានតែផលិតផលដំណាំស្រូវប៉ុណ្ណោះ ដែលអាចនាំចេញទៅរកទីផ្សារបាន ដែលសល់ពីការហូបចុក មានប្រភេទស្រូវប្រដេញទឹក (ពូជ៥៤ ៥១ ) និងស្រូវសែនក្រអូប។ បើយោងតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំកំពង់គោ ឆ្នាំ ២០១៧ បានឱ្យដឹងថា ប្រភេទស្រូវប្រដេញទឹក (ពូជ៥៤ ៥១) មានតែទីផ្សារនៅប្រទេសវៀតណាម និងថៃ ដែលប្រជាពលរដ្ឋតែងលក់ស្រូវសើម ៨០ ភាគរយតាមរយៈឈ្មួញមកទទួលទិញដល់ក្នុងឃុំ មានតម្លៃត្រឹម ៨០០ រៀលក្នុងមួយគីឡូក្រាម ចំណែកស្រូវសែនក្រអូបមានទីផ្សារនៅក្នុងស្រុក និងប្រទេសវៀតណាម ដែលប្រជាពលរដ្ឋតែងតែលក់ស្រូវសើម ៥០ ភាគរយ តាមរយៈឈ្មួញមកទទួលទិញដល់ក្នុងឃុំ មានតម្លៃត្រឹម ១ ២០០ រៀលក្នុងមួយគីឡូក្រាម ។

តារាង 27៖ស្ថិតិផលិតផលស្រូវ និងតម្លៃ

| ល.រ | ប្រភេទផលិតផលស្រូវ | ឯកតា | តម្លៃជារៀល | ទីផ្សារ | |
|---|---|---|---|---|---|
| | | | | ក្នុងស្រុក | ក្រៅប្រទេស |
| ១ | ស្រូវប្រដេញទឹក (៥៤៥១) | ១ គ.ក្រ | ៨០០ | | វៀតណាម |
| ២ | ស្រូវសែនក្រអូប | ១គ.ក្រ | ១២០០ | | វៀតណាម |

### ១.៤.២.ខ្សែសង្វាក់ និងចរាចរផលិតផល

តាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំកំពង់គោឆ្នាំ ២០១៧ បានឱ្យដឹងថា បច្ចុប្បន្ននៅក្នុងឃុំកំពង់គោ ការផលិតដំណាំស្រូវរហូតទៅដល់បានផលលក់ចេញ គឺត្រូវដំណើរការតាមខ្សែសង្វាក់ជាបន្តបន្ទាប់ ដូចជាការផលិតដំណាំស្រូវប្រដេញទឹក (ពូជ ៥៤ ៥១) ពូជត្រូវបានទុកពូជខ្លួនឯង ១០ ភាគរយ និងទិញ ៩០ ភាគរយ ហើយមានការរៀបចំដី រួមទាំងការថែទាំ មានការដាក់ជី និងបាញ់ថ្នាំសម្លាប់សត្វល្អិតរហូតដល់ច្រូតកាត់ ដែលប្រើប្រាស់គ្រឿងយន្ត ១០០ ភាគរយ ចំណែកផលស្រូវ ដែលទទួលបាន ត្រូវហាលសម្ងួតទុកពូជ ១០ ភាគរយ និងលក់ ១០ ភាគរយប៉ុណ្ណោះ ចំណែកផលស្រូវនៅសើម ដែលសល់ប្រមាណជា ៨០ ភាគរយ ត្រូវយកទៅលក់ឱ្យឈ្មួញនៅតាមដងផ្លូវក្នុងឃុំបានតម្លៃ ៨០០រៀល ក្នុងមួយគីឡូក្រាម ហើយឈ្មួញបន្តដឹកយកទៅលក់ឱ្យទីផ្សារនៅប្រទេសវៀតណាម និងប្រទេសថៃ ចំណែកស្រូវសែនអូប ដោយចាប់ផ្តើមពីការត្រៀមពូជស្រូវ ការរៀបចំដី រួមទាំងការថែទាំ មានការដាក់ជី និងការបាញ់ថ្នាំសម្លាប់សត្វល្អិត រហូតទៅដល់ច្រូតកាត់ ដោយប្រើប្រាស់គ្រឿងយន្តរហូតទៅដល់ ១០០ ភាគរយ ។ ទិន្នផលស្រូវដែលទទួលបាន ត្រូវហាលសម្ងួត ទុកហូបប្រមាណ ៥០ ភាគរយ ចំណែកផលស្រូវនៅសើម ដែលសល់ប្រមាណ ៥០ ភាគរយ

ត្រូវបានយកទៅលក់ឱ្យឈ្មួញនៅតាមដងផ្លូវក្នុងឃុំបានតម្លៃ ១២០០រៀលក្នុងមួយគីឡូក្រាម ហើយឈ្មួញបន្តលក់ឱ្យរោងម៉ាស៊ីនកិនស្រូវយកទៅកិនកែច្នៃជាអង្ករនាំទៅទីផ្សារក្នុងប្រទេស និងទីផ្សារក្រៅប្រទេស ។

រូបភាព 13៖ ទិដ្ឋភាពលក់ផលិតផលស្រូវនៅក្នុងឃុំ



**គំនូសតាងនៃការលំហូផលិតផលកសិកម្ម នៅក្នុងឃុំ និង ការប្រើប្រាស់**






## ១.៤.៣.ឧបសគ្គ និងឱកាស

តារាង 28៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - ឈ្មួញជាអ្នកកំណត់តម្លៃស្រូវ<br>- ឈ្មួញកណ្ដាលយកជី ថ្នាំ និងប្រេងមកបណ្ដាក់ដោយគិតការប្រាក់ខ្ពស់រហូតដល់២ភាគរយក្នុងមួយខែ ហើយទូទាត់នៅពេលប្រមូលផល<br>- កសិករប្រើពូជទុកខ្លួនឯងច្រើនជំនាន់<br>- ធាតុចូលកសិកម្មថ្លៃខ្ពស់<br>- តម្លៃស្រូវមិនទៀងទាត់(អាស្រ័យលើឈ្មួញ)<br>- ប្រើប្រាស់ពូជស្រូវវៀតណាម។ | - មានឈ្មួញមកទិញដល់កន្លែង<br>- មានភាពងាយស្រួលក្នុងការដឹកជញ្ជូនផលិតផលស្រូវ<br>- អាចប្រកួតប្រជែងតម្លៃជាមួយប្រទេសជិតខាង<br>- គុណភាពស្រូវស្របតាមស្ដង់ដាសម្រាប់ការនាំចេញ<br>- តម្លៃអង្ករកើនឡើង និងទៀងទាត់<br>- ពូជស្រូវមានទិន្នផលខ្ពស់ និងតម្លៃខ្ពស់<br>- កែច្នៃចេញជាផលិតផលសម្រេច។ |

# ជំពូក២៖ ការវិភាគ តម្រូវការ សក្តានុពល និងឱកាសសម្រាប់អនាគត

## ២.១.តម្រូវការសម្រាប់អនាគត

### ២.១.១.ផែនការអភិវឌ្ឍ ឃុំ

ក.ផែនការអភិវឌ្ឍសង្កាត់៥ឆ្នាំ(២០១៨-២០២២)

ផែនការអភិវឌ្ឍឃុំ ៥ ឆ្នាំ គឺជាមធ្យោបាយយ៉ាងសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហា តម្រូវការជាអាទិភាពយ៉ាងពិតប្រាកដរបស់មូលដ្ឋាន និងយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនោះ សំដៅឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងឃុំយ៉ាងមានប្រសិទ្ធភាព តាមរយៈការរៀបចំឱ្យមានតារាងក្របខ័ណ្ឌអភិវឌ្ឍឃុំមួយ មានរយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិក្រុមប្រឹក្សាឃុំ។ តារាងក្របខ័ណ្ឌអភិវឌ្ឍឃុំ បានរំលេចនូវចក្ខុវិស័យអភិវឌ្ឍ ដែលជាទស្សនៈរបស់ក្រុមប្រឹក្សាចង់បានការប្រែប្រួលជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្លួនឱ្យបាន ស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ហើយដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ ក៏បានរំលេចឱ្យឃើញពីគោលបំណងអភិវឌ្ឍ ដែលជាលទ្ធផលរួមរបស់ក្រុមប្រឹក្សាចង់បានព្រមទាំងគោលដៅអភិវឌ្ឍដែលជាលទ្ធផលនានារបស់ក្រុមប្រឹក្សាចង់បានទៅតាមវិស័យនីមួយៗ។ទន្ទឹមនេះក៏បានរំលេចឱ្យឃើញនូវយុទ្ធសាស្ត្រអភិវឌ្ឍ ដែលជាការកំណត់នូវវិធីសាស្ត្រ ឬសកម្មភាពត្រូវអនុវត្ត ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍនីមួយៗខាងលើ។

ចំណែកឃុំកំពង់គោ ក្រុមប្រឹក្សាឃុំក្នុងអាណត្តិ ២០១៨-២០២២ ក៏បានរៀបចំឱ្យមានផែនការអភិវឌ្ឍឃុំរយៈពេលប្រាំឆ្នាំរបស់ខ្លួន ដែលនៅក្នុងនោះបានលើកឡើង ពីគម្រោងវិនិយោគរយៈពេលប្រាំឆ្នាំទៅក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍឃុំដូចមានខ្លឹមសារដែលក្រុមការងារបានដកស្រង់បញ្ចូលក្នុងតារាងខាងក្រោម៖

តារាង 29៖ ក្របខ័ណ្ឌនៃការអភិវឌ្ឍ និងជម្រើសនៃការប្រាស់ដីធ្លីអនាគត

| កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និង យុទ្ធសាស្ត្រ | | | | | |
|---|---|---|---|---|---|
| តម្រូវការនៃការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ | សកម្មភាពជា អាទិភាព | លេខរៀងនៅលើផែនទី |
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| ១.ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូនល្អប្រសើរ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ស្តារ និងកែលម្អឡើងវិញបណ្តាញគមនាគមន៍ផ្លូវថ្នល់ | -កែលម្អរជួសជុលផ្លូវ និងដាក់លូបង្ហូរទឹក | -កែលម្អរផ្លូវដីសទៅផ្លូវគ្រួសក្រហម<br>-ពីផ្លូវគ្រួសក្រហមទៅផ្លូវបេតុងឬផ្លូវកៅស៊ូ<br>-សាងសង់ផ្លូវបេតុងឬផ្លូវកៅស៊ូ<br>-សាងសង់លូកាត់ផ្លូវ<br>-សាងសង់ស្ពានឆ្លងស្ទឹងសែន<br>-សាងសង់ស្ពាន(បេតុង បេឡេ) | |
| ២.មានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ពង្រីដីស្រោចស្រពដោយប្រព័ន្ធធារាសាស្ត្រ | -ស្តារនិងជួសជុលប្រព័ន្ធធារាសាស្ត្រចាស់ៗឡើងវិញ<br>-សាងសង់សំណង់ធារាសាស្ត្រ | -ស្តារប្រឡាយអមសងខាងផ្លូវ<br>-ស្តារប្រឡាយចាស់ឡើងវិញ | |
| ៣.លើកកម្ពស់ផលិតភាពនិងផលិតកម្មកសិកម្ម | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -បង្កើនចំណេះដឹងបច្ចេកទេសដាំដុះដល់កសិករ | -បង្កើនផលិតកសិកម្ម | -កែលម្អគុណភាពដី<br>-ជ្រើសរើសពូជដែលធនទៅនឹងបំរែបំរួលអាកាសធាតុ<br>-ស្វែងរកទីផ្សារ | |
| ៤.គ្រួសារចិញ្ចឹមសត្វកើនឡើង | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ | ជំរុញកំណើនចិញ្ចឹមសត្វជា | -ជំរុញការផ្តល់បច្ចេកទេសជំនាញ | -ផ្តល់ចំណេះដឹងពីបច្ចេកទេសចិញ្ចឹមសត្វ<br>-ជំរុញការចិញ្ចឹមសត្វលក្ខណៈគ្រួសារ | |

| | | | | | |
|---|---|---|---|---|---|
| | ២០១៨-២០២២ | លក្ខណៈគ្រួសារ និងកសិដ្ឋាន | កសិកម្ម<br>-ជំរុញការផ្តល់បច្ចេកទេសចិញ្ចឹមថែទាំសុខភាពសត្វ និងជ្រើសរើសពូជ | -ទំនាក់ទំនងទីផ្សារ<br>-ផ្តល់បច្ចេកទេសចិញ្ចឹមសត្វលក្ខណៈគ្រួសារនិងជ្រើសរើសពូជដែលធន់និងគ្រោះរាំងស្ងួត | |
| ៥.ឱ្យមានភាពប្រសើរឡើងចំពោះវិស័យឯកជន និងការងារអគ្គិសនី | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | ជំរុញអភិវឌ្ឍវិស័យឯកជន និងការងារអគ្គិសនី | -ពង្រឹងកិច្ចសហការជាមួយវិស័យឯកជន និងអង្គភាពអគ្គិសនី | -បង្កលក្ខណៈងាយស្រួលសម្រាកការវិនិយោគ<br>-បង្កើនទំនាក់ទំនងឱ្យកាន់តែជិតស្និទរវាងវិស័យឯកជន និងស្ថាប័នរដ្ឋ<br>-ពង្រីកបណ្តាញអគ្គិសនី<br>-បង្កើនការយល់ដឹងពីអាជីវកម្ម<br>-បង្កើនការយល់ដឹងពីការប្រើប្រាស់ឥណទាន<br>-ពង្រីកសេវាឥណទាន | |
| ៦.ប្រជាពលរដ្ឋមានការងារ និងមុខរបរបន្ថែម | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | បង្កើនសម្ថភាពវិជ្ជាជីវៈដើម្បីបង្កើតមុខរបរនិងការងារ | បើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវគ្គខ្លីៗ | -បណ្តុះបណ្តាលជំនាញ និងវិជ្ជាជីវៈរយៈពេលខ្លី<br>-ពង្រីកថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ផ្តល់ឱកាសដល់យុវជនបានចូលសិក្សានៅសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ | |
| ៧.កម្រិតអប់រំមានគ្រប់កម្រិត និងសិស្សបានចូលរៀនគ្រប់គ្នានៅក្នុងឃុំ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២២០២ | -ពង្រឹងនិងពង្រីកកម្មវិធីអប់រំកុមារតូច<br>-លើកកម្ពស់គុណភាពនិងប្រសិទ្ធិភាពនៃការសិក្សានៅគ្រប់កម្រិត<br>-កាត់បន្ថយអនក្ខរជនឱ្យនៅមានកម្រិតទាបបំផុត | -ពង្រឹងនិងពង្រីកផ្នែកមត្តេយ្យសាលាឱ្យបានគ្រប់មូលដ្ឋានភូមិ<br>-ជំរុញការយល់ដឹងដល់ឪពុកម្តាយកុមារពីតម្លៃសិក្សា<br>-ពង្រឹងកិច្ចសហការជាមួយមន្ទីរជំនាញ និងអង្គការនានាដើម្បីកាត់បន្ថយអនក្ខរកម្មរបស់ប្រជាពលរដ្ឋ | -អប់រំមាតាបិតាយស់ពីអត្ថប្រយោជន៍នៃការសិក្សាថ្នាក់ដំបូងរបស់កុមារ<br>-ផ្តល់លទ្ធភាពដល់សិស្សក្នុងគ្រួសារក្រីក្របានបន្តការសិក្សា<br>-អប់រំផ្សព្វផ្សាយមាតាបិតាឱ្យយល់ពីតម្លៃនៃការសិក្សារបស់កូន<br>-បង្កើនសាលាមត្តេយ្យសិក្សារដ្ឋ<br>-គាំទ្រដល់មត្តេយ្យសហគមន៍ដែលមានស្រាប់<br>-បង្កើតសាលារៀនឱ្យគ្រប់កម្រិតថ្នាក់ស្របតាមភូមិសាស្ត្រជាក់ស្តែង<br>-កែលម្អគុណភាពនៃការបង្រៀននិងរៀននៅគ្រប់កម្រិតសិក្សា<br>-ផ្តល់លទ្ធភាពដល់សិស្សមកឆ្ងាយស្នាក់នៅសាលា<br>-កែលម្អគុណភាពនៃការចូលរៀនតាមភូមិសិក្សា<br>-ជំរុញសកម្មភាពថ្នាក់អក្ខរកម្ម<br>-អប់រំដល់អក្ខរជនឱ្យទទួលយកសេវាអក្ខរកម្មផ្តល់សម្ភារៈសម្រាប់ថ្នាក់អក្ខរកម្ម | |
| ៨.សុខភាពរបស់ប្រជាជនល្អប្រសើរ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -លើកកម្ពស់សុខភាពមាតានិងទារក<br>-ពង្រឹងវិធានការការពារ ទប់ស្កាត់ជម្ងឺឆ្លងនិងជម្ងឺរ៉ាំងរ៉ៃផ្សេងៗទៀត | -បង្កើននិងកែលម្អសេវាសុខភាព និងចំណេះដឹងដល់ភ្នាក់ងារសុខភាពភូមិ | -លើកកម្ពស់សុខភាពមាតានិងទារក<br>-អប់រំផ្សព្វផ្សាយពីសុខភាពអនាម័យ<br>-ពង្រឹងនិងពង្រីកសេវាសាធារណៈ<br>-អប់រំពីសុខភាពបន្តពូជ<br>-អប់រំពីការថែទាំសុខភាពមាតានិងទារក<br>-អប់រំពីបញ្ហាអាហារូបត្ថម្ភ<br>-ផ្តល់វ៉ាក់សាំងការពារជម្ងឺដល់ស្ត្រីនិងកុមារ<br>-អប់រំពីការសម្រាលកូនដោយសុវត្ថភាព<br>-ផ្តល់សេវាដោយមិនគិតថ្លៃដល់គ្រួសារក្រីក្រ<br>-អប់រំឱ្យមានការចូលរួមធ្វើអនាម័យជាប្រចាំ<br>-អប់រំផ្សព្វផ្សាយវិធីការពារទប់ស្កាត់ជម្ងឺឆ្លងគ្រប់ប្រភេទ<br>-អប់រំឱ្យស្វែងរកសេវាពិគ្រោះនិងព្យាបាលពេលមានជម្ងឺ | |

| | | | | | |
|---|---|---|---|---|---|
| | | | | -មានវិធានការការពារនិងទប់ស្កាត់ផលប៉ះពាល់សុខភាពដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយផ្សេងៗ | |
| ៩.ព្រៃឈើមានចេរភាព | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | គ្រប់គ្រងនិងអភិរក្សធនធានព្រៃឈើនិងសត្វព្រៃប្រកបដោយចីរភាព | -មានវិធានការគ្រប់គ្រងនិងប្រើប្រាស់ព្រៃឈើឱ្យមានប្រសិទ្ធភាព | -ពង្រឹងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងព្រៃឈើ<br>-កំណត់ព្រំប្រទល់ចំណាត់ថ្នាក់និងចុះបញ្ជីដែនព្រៃឈើ<br>-មានវិធានការគ្រប់គ្រងនិងប្រើប្រាស់ព្រៃឈើឱ្យមានប្រសិទ្ធភាព<br>-យកចិត្តទុកដាក់លើកកម្ពស់ជីវភាពនិងបង្កើនការចូលរួមរបស់សហគមន៍ដែលរស់នៅអាស្រ័យផលព្រៃឈើ<br>-យកចិត្តទុកដាក់ពង្រឹងសហគមន៍គ្រប់គ្រងព្រៃឈើ<br>-បង្កើនការដាំមឈើឡើងវិញ | |
| ១០.ឃុំមានបរិស្ថាន និងធនធានធម្មជាតិស្រស់បំព្រង | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | គ្រប់គ្រងនិងអភិរក្សធនធានជលផលប្រកបដោយចេរភាព | -បង្កើនសេវាលើការគ្រប់គ្រធនធានធម្មជាតិ និងបរិស្ថាន | -ពង្រឹងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងធនធានជលផល<br>-បង្កើនប្រសិទ្ធិភាពការគ្រប់គ្រងដែននេសាទ<br>-ពង្រឹងការគ្រប់គ្រងឧបករណ៍នេសាទទាំងរដូវបើកនិងបិទនេសាទ<br>-ទប់ស្កាត់ការកាប់បំផ្លាញព្រៃលិចទឹក<br>-អភិរក្សស្រះជម្រកត្រី | |
| ១១.មានទឹកស្អាតសម្រាប់គ្រួសារប្រើប្រាស់ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០០៨-២០១២ | លើកកម្ពស់សុខភាពប្រជាពលរដ្ឋតាមរយៈការប្រើប្រាស់ទឹកស្អាតនិងបង្គន់អនាម័យ | -ពង្រីក និងកែលំម្អប្រភពផ្គត់ផ្គង់ទឹក | -សាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត<br>-ជួសជុលអណ្តូងដែលមានស្រាប់<br>-ផ្តល់មធ្យោបាយចម្រោះទឹកស្អាត<br>-បណ្តុះបណ្តាលបច្ចេកទេសថែទាំនិងជួសជុលអណ្តូង<br>-សាងសង់បង្គន់អនាម័យ<br>-ផ្តល់សម្ភារៈសាងសង់បង្គន់អនាម័យ<br>-អប់រំប្រជាពលរដ្ឋឱ្យមានការយល់ដឹងពីសុខភាពនិងអនាម័យ | |
| ១២.ពង្រឹងយន្តការគ្រប់គ្រងគ្រោះមហន្តរាយ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ត្រៀមលក្ខណៈគ្រប់គ្រង បង្កានិងដោះស្រាយរាល់បញ្ហាដែលកើតឡើងដោយគ្រោះមហន្តរាយផ្សេងៗ<br>-ត្រៀមលក្ខណៈស្តារឡើងវិញនូវការខូចខាតដែលបណ្តាលមកពីគ្រោះមហន្តរាយ<br>-ភាពងាយរងគ្រោះនិងហានិភ័យគ្រោះមហន្តរាយ | -ការរៀបចំការគ្រប់គ្រងបង្កានិងដោះស្រាយរាល់បញ្ហាដែលកើតឡើងដោយគ្រោះមហន្តរាយផ្សេង<br>-ផ្សព្វផ្សាយបច្ចេកទេសនិងផ្តល់សេវាព្យាបាលកាត់បន្ថយគ្រោះមហន្តរាយកាន់តែមានភាពប្រសើឡើង | -បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋពីមុខសញ្ញាគ្រោះថ្នាក់ភាពងាយរងគ្រោះនិងហានិភ័យគ្រោះមហន្តរាយ<br>-រៀបចំផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ<br>-ពង្រឹងក្រុមការងារអន្តរាគមន៍ឆ្លើយតបគ្រោះមហន្តរាយ<br>-ត្រៀមស្បៀង និងសម្ភារៈបរិក្ខាសង្គ្រោះបន្ទាន់<br>-សាងសង់និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត<br>-ផ្តល់សម្ភារៈកសិកម្ម ពូជ ជី បម្រើឱ្យការដាំដុះឡើងវិញ<br>-ផ្តល់សេវាព្យាបាល អប់រំ ថែទាំសុខភាពនិងអនាម័យ | |

| | | | | | |
|---|---|---|---|---|---|
| ១៣.ធ្វើឱ្យប្រសើរឡើងសម្រាប់ការផ្តល់សេវាអត្រានុកូលដ្ឋាន | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | ពង្រឹងការងារផ្តល់សេវាអត្រានុកូលដ្ឋាន | ការផ្តល់សេវាអត្រានុកូលដ្ឋានដល់ប្រជាពលរដ្ឋឱ្យកាន់ល្អប្រសើរឡើង | -បង្កើនសមត្ថភាពការងាររបស់មន្ត្រីអត្រានុកូលដ្ឋាន<br>-ពង្រឹងការអនុវត្តតួនាទីក្នុងការផ្តល់សេវាអត្រានុកូលដ្ឋាន<br>-ពង្រឹងយន្តការក្នុងការផ្តល់សេវាអត្រានុកូលដ្ឋាន<br>-អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីសារសំខាន់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន | |
| ១៤.ធ្វើឱ្យប្រជាពលរដ្ឋរស់នៅប្រកបដោយភាពសុខសាន្ត និងសុវត្ថិភាព | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | ពង្រឹងការគ្រប់គ្រងព័ត៌មានដើម្បីឆ្លើយតបនឹងគោលនយោបាយគ្រប់វិស័យ | ផ្សព្វផ្សាយពីច្បាប់ផ្សេងៗនិងគោលនយោបាយនានា | -អប់រំផ្សព្វផ្សាយច្បាប់ផ្សេងៗ<br>-អនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថភាព<br>-ពង្រឹងប៉ុស្តិ៍រដ្ឋបាល<br>-ពង្រឹងកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលគ្រប់កម្រិត<br>-ជំរុញការចូលរួមពីប្រជាពលរដ្ឋ<br>-លុបបំបាត់ភាពអនាធិបតេយ្យនៅតាមដងផ្លូវ | |
| ១៥.សមភាព និងសមធម៌ក្នុងការរស់នៅ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -កាត់ន្ថយអំពើហឹង្សាក្នុងគ្រួសារនិងសហគមន៍ | -បង្កើនការផ្សព្វផ្សាយច្បាប់ | -អប់រំច្បាប់ស្តីពីអំពើហឹង្សាក្នុងគ្រួសារនិងកិច្ចការពារជនងាយរងគ្រោះ<br>-ទប់ស្កាត់ការលេងល្បែងស៊ីសងគ្រប់ប្រភេទ<br>-ទប់ស្កាត់ការជួញដូរនិងការប្រើប្រាស់គ្រឿងញៀន<br>-អប់រំកាត់បន្ថយការសេពគ្រឿងស្រវឹង<br>-អប់រំពីការលើកកម្ពស់សីលធម៌ ចរិយាធម៌ | |
| ១៦.លុបបំបាត់កាត់បន្ថយទំនាស់ដីធ្លី | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -បង្កើនសេវាផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី | -ជំរុញឱ្យប្រជាពរដ្ឋបានយល់ដឹងពីច្បាប់ និងមានកម្មសិទ្ធិដីធ្លីដោយស្របច្បាប់<br>-បង្កើនការគ្រប់គ្រងដីធ្លីឱ្យស្របតាមគោលនយោបាយរបស់រដ្ឋ | -ពន្លឿនការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដើម្បីគាំទ្រដំណើរការវាស់វែងដីធ្លីជាប្រព័ន្ធ<br>-បន្តអនុវត្តសកម្មភាពផ្តល់សេវាវាស់វែងដាច់ដោយដុំ<br>-ផ្សព្វផ្សាយច្បាប់ភូមិបាល | |
| ១៧.លើកម្ពស់យេនឌ័រ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | បង្កើនការយល់ដឹងពីការបញ្ជាបយេនឌ័រនិងការចូលរួមក្នុងឆាកនយោបាយរបស់ស្ត្រី | ការយល់ដឹងរបស់ស្ត្រីកាន់តែប្រសើឡើង | -ពង្រឹងបណ្តាញការងារយេនឌ័រ<br>-ជំរុញការគាំទ្រពីសហគមន៍និងគ្រួសារស្ត្រីចូលរួមក្នុងឆាកនយោបាយ<br>-លើកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពសង្គម | |

## ខ.គម្រោងអភិវឌ្ឍផ្សេងៗទៀតដែលបានអនុម័តរួច

នៅក្នុងឃុំកំពង់គោបច្ចុប្បន្ននេះមិនមានគម្រោងអភិវឌ្ឍណាមួយ ដែលត្រូវបានអនុម័តរួចដើម្បីដំណើរការជួយជំរុញក្នុងការអភិវឌ្ឍឃុំឡើយ

ផែនទី ១៖ ផែនទីគម្រោងវិនិយោគជាអាទិភាពឃុំកំពង់គោ




## ២.១.២.ចំណោលប្រជាសាស្ត្រគិតទៅដល់ឆ្នាំ២០៣២

ការព្យាករណ៍ពីកំណើនប្រជាជន ជាចំណុចសំខាន់ណាស់ សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់គោ ដែលអាចឱ្យយើងដឹងជាមុននូវចំនួនប្រជាជនក្នុងឃុំនេះនៅក្នុងរយៈពេល១៥ឆ្នាំខាងមុខដ៏វែង អត្រាកំណើនជាមធ្យមរបស់ប្រជាពលរដ្ឋក្នុងឃុំ ដែលបានបង្ហាញនៅក្នុងជំពូកទី១បានឱ្យដឹងថា គឺ ១,២១ភាគរយ ដូច្នេះ ប្រជាពលរដ្ឋនៅក្នុងឃុំនេះនឹងមានការកើនឡើងរហូតទៅដល់ឆ្នាំ២០៣២ ត្រូវបានធ្វើចំណោលតាមរយៈការគណនាដូចខាងក្រោម៖

-ចំនួនប្រជាជនសរុបក្នុងឆ្នាំ ២០១៧ គឺ ៧ ៦៥៦ នាក់

-អត្រាកំណើនមធ្យមប្រចាំឆ្នាំ: ១,២១ %

-ចំនួនប្រជាជនកើនឡើងក្នុងរយៈពេល១ឆ្នាំ: **៧៦៥៦នាក់** x **១,២១** % = **៩៣នាក់/ឆ្នាំ**

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើនឡើងបាន: ៩៣នាក់/ឆ្នាំ** x **១៥ ឆ្នាំ** = **១ ៣៩៥ នាក់**

**-ដូច្នេះប្រជាជនសរុបក្នុងរយៈពេល១៥ខាងមុខទៀតមាន: ៧៦៥៦នាក់** + **១៣៩៥នាក់** = **៩០៥១នាក់**

ចំណែកចំនួនគ្រួសារនៅក្នុងឃុំ នឹងមានការកើនឡើងនៅក្នុងឆ្នាំ ២០៣២ ត្រូវបានធ្វើចំណោលតាមរយៈការគណនាដូចខាងក្រោម៖

-ចំនួនប្រជាជនសរុបក្នុងឆ្នាំ ២០១៧ គឺ ៧៦៥៦នាក់

-ចំនួនគ្រួសារសរុបក្នុងឆ្នាំ ២០១៧ គឺ ១៥៤៣គ្រួសារ

-ចំនួនសមាជិកមធ្យមក្នុងមួយគ្រួសារក្នុងឆ្នាំ ២០១៧ គឺ:

**៧៦៥៦នាក់ /១៥៤៣គ្រួសារ = ៤,៩៦នាក់/គ្រួសារ**

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខចំនួនគ្រួសារកើនឡើងបាន:

**១៣៩៥នាក់/ ៤,៩៦នាក់/គ្រួសារ = ២៧០គ្រួសារ**

-ដូច្នេះចំនួនគ្រួសារសរុបក្នុងរយៈពេល១៥ឆ្នាំខាងមុខទៀតមាន:

**១៥៤៣គ្រួសារ + ២៧០គ្រួសារ = ១៨១៧គ្រួសារ**

តារាង 30៖ ចំណោលប្រជាសាស្ត្រនៃចំនួនគ្រួសារ និងប្រជាជនសរុប (០៥ឆ្នាំ)

| ឆ្នាំ | ចំនួនគ្រួសារ | ចំនួនប្រជាជន(នាក់) | |
|---|---|---|---|
| | | សរុប | ស្រី |
| ២០១៧ | ១៥៤៣ | ៧៦៥៦ | ៣៩២១ |
| ២០២២ | ១៦៣៤ | ៨១២១ | ៤១៥៩ |
| ២០២៧ | ១៧២៦ | ៨៥៨៦ | ៤៣៩៧ |
| ២០៣២ | ១៨១៧ | ៩០៥១ | ៤៦៣៥ |

តារាង 31៖ ចំណោលប្រជាសាស្ត្រតាមក្រុមអាយុ (០៥ឆ្នាំ)

| ស្ថិតិតាមក្រុមអាយុ | ២០១៧ | | ២០២២ | | ២០២៧ | | ២០៣២ | |
|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អាយុពី០-២ឆ្នាំ | ៣៤៩ | ១៦៣ | ៣៧០ | ១៧៣ | ៣៩១ | ១៨៣ | ៤១២ | ១៩៣ |
| អាយុពី៣-៤ | ៣៥២ | ១៩០ | ៣៧៣ | ២០១ | ៣៩៥ | ២១៣ | ៤១៦ | ២២៤ |
| អាយុ៥ឆ្នាំ | ៣៦២ | ១៨៤ | ៣៨៤ | ១៩៥ | ៤០៦ | ២០៦ | ៤២៨ | ២១៨ |
| អាយុ៦-១១ឆ្នាំ | ៩៣៨ | ៥០៧ | ៩៩៥ | ៥៣៨ | ១,០៥២ | ៥៦៩ | ១,១០៩ | ៥៩៩ |
| អាយុ១២-១៤ឆ្នាំ | ៦៩៥ | ៣២៩ | ៧៣៧ | ៣៤៩ | ៧៧៩ | ៣៦៩ | ៨២២ | ៣៨៩ |
| អាយុ១៥-១៧ឆ្នាំ | ៥១៣ | ២៥៤ | ៥៤៤ | ២៦៩ | ៥៧៥ | ២៨៥ | ៦០៦ | ៣០០ |
| អាយុ១៨-២៤ឆ្នាំ | ៨៥២ | ៤៥០ | ៩០៤ | ៤៧៧ | ៩៥៥ | ៥០៥ | ១,០០៧ | ៥៣២ |
| អាយុ២៥-៦០ឆ្នាំ | ២,៩១៧ | ១,៥៥៣ | ៣,០៩៤ | ១,៦៤៧ | ៣,២៧១ | ១,៧៤២ | ៣,៤៤៨ | ១,៨៣៦ |
| អាយុ៦១ឆ្នាំ | ៦៧៨ | ២៩១ | ៧១៩ | ៣០៩ | ៧៦០ | ៣២៦ | ៨០២ | ៣៤៤ |
| ចំនួនប្រជាជនសរុប | ៧,៦៥៦ | ៣,៩២១ | ៨,១២១ | ៤,១៥៩ | ៨,៥៨៦ | ៤,៣៩៧ | ៩,០៥១ | ៤,៦៣៥ |
| ចំនួនគ្រួសារ | ១,៥៤៣ | | ១,៦៣៤ | | ១,៧២៦ | | ១,៨១៧ | |

## ២.១.៣.តម្រូវការដីជាមូលដ្ឋាន

### ក.តម្រូវការដីលំនៅឋាន

ចំពោះដីភូមិសំដៅទៅលើដីសម្រាប់សាងសង់ផ្ទះ និងសម្រាប់សួនដំណាំជុំវិញផ្ទះតាមគ្រួសារ ។ នៅក្នុងឆ្នាំ២០១៧ ដែលជាឆ្នាំគោលយើងបានដឹងថា ដីលំនៅឋានមានទំហំផ្ទៃដីសរុបចំនួន ១៥៨,០១ ហិកតា និងមានគ្រួសារសរុបចំនួន ១ ៥៤៣ គ្រួសារ ជាស្ថានភាពរស់នៅរបស់ប្រជាជនមានភាពសមស្របមិនមានបញ្ហាពីការខ្វះដីសម្រាប់លំនៅឋានឡើយ លើកលែងតែគ្រួសារមួយចំនួនតូចគឺស្មើចំនួន ២៥០គ្រួសារ ដែលមិនមានដីសម្រាប់សាងសង់លំនៅឋាន ហើយបច្ចុប្បន្នគ្រួសារទាំងនោះកំពុងតែរស់នៅលើដីចំណីស្ពឹងជាដីសាធារណៈ និង គ្រួសារមួយចំនួនទៀតកំពុងរស់នៅលើដីកម្មសិទ្ធិរបស់អ្នកដទៃ (យោងតាមទិន្នន័យក្នុងជំពូកទី១ ត្រង់ចំណុច ១.៣.១

អំពីការកាន់កាប់និងគ្រប់គ្រងការប្រើប្រាស់ដី) ដែលត្រូវការយកចិត្តទុកដាក់ដោះស្រាយជូនតាមរយៈដីសម្បទានដីសង្គមកិច្ច មាននៅទីតាំងក្រៅឃុំតាមការសម្រេចរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ច

ក្នុងឆ្នាំ២០១៧ ផ្ទៃដីលំនៅឋានជាមធ្យមសម្រាប់មួយគ្រួសារមានចំនួន៖

**១៥៨,០១ហិកតា/ ១៥៤៣គ្រួសារ = ០,១០ហិកតា/ គ្រួសារ**

តែបើយោងទៅតាមអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច បានចែងតម្រូវឱ្យមានដីលំនៅឋានយ៉ាងច្រើន ០,២៥ ហិកតា ក្នុងមួយគ្រួសារ ដែលអាចប្រើប្រាស់សម្រាប់ដោះស្រាយជូន ២៥០ គ្រួសារ ដែលគ្មានដីពិតប្រាកដសម្រាប់លំនៅឋាន ដើម្បីអាចទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋ ដែលមាននៅទីតាំងផ្សេងពីឃុំកំពង់គោនេះ។

ដូច្នេះ ដើម្បីធានានិរន្តរភាពនៃការរស់នៅដូចបច្ចុប្បន្ន ចំពោះប្រជាជនដែលមានកំណើនក្នុងរយៈពេល ១៥ឆ្នាំខាងមុខ ត្រូវការដោះស្រាយដីសម្រាប់ធ្វើកសិកម្មចំនួនតាមការគណនាដូចខាងក្រោម៖

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើនឡើងចំនួនៈ ១ ៣៩៥ នាក់

-ចំនួនសមាជិកមធ្យមក្នុងមួយគ្រួសារមានៈ ៤,៩៦ នាក់/គ្រួសារ

-តម្រូវការដីលំនៅឋានក្នុង១គ្រួសារមានចំនួន ០,១០ ហិកតា/ គ្រួសារ

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខចំនួនគ្រួសារកើនឡើងបានៈ

**១៣៩៥ នាក់/ ៤,៩៦ នាក់/គ្រួសារ = ២៧០ គ្រួសារ**

-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ(២០១៧-២០៣២) ដីលំនៅឋានត្រូវកើនឡើងៈ

**២៧០ គ្រួសារ x ០,១០ ហិកតា/គ្រួសារ = ២៧ ហិកតា**

-ដូច្នេះរហូតដល់ឆ្នាំ ២០៣២ ដីលំនៅឋាននៅក្នុងឃុំកំពង់គោត្រូវកើនឡើងដល់ៈ

**១៥៨,០១ ហិកតា + ២៧ ហិកតា = ១៨៥,០១ ហិកតា**

-ចំណែកការដោះស្រាយដីលំនៅឋានជូនគ្រួសារដែលគ្មានដីពិតប្រាកដចំនួន ២៥០ គ្រួសារតាមរយៈ

សម្បទានសង្គមកិច្ចមានចំនួនៈ **២៥០ គ្រួសារ x ០,២៥ ហិកតា/គ្រួសារ = ៦២,៥ ហិកតា**

តារាង 32៖ តម្រូវការដីសម្រាប់លំនៅឋានក្នុងឆ្នាំ២០៣២

| **បរិយាយ** | **២០១៧ បច្ចុប្បន្ន** | **អនាគត ២០៣២** | **បម្រែបម្រួលតម្រូវការដី** |
|---|---|---|---|
| គ្រួសារ | ១៥៤៣គ្រួសារ | ១៨១៧គ្រួសារ | ២៧០ គ្រួសារ |
| តម្រូវការដីលំនៅឋាន | ១៥៨,០១ ហិកតា | ១៨៥,០១ ហិកតា | ២៧ ហិកតា |

### ខ.ដីកសិកម្ម

ចំពោះដីកសិកម្មសំដៅទៅលើដីសម្រាប់ធ្វើស្រែ និងដីចំការដំណាំ។ នៅក្នុងឆ្នាំ២០១៧ ដែលជាឆ្នាំគោលយើងបានដឹងថា ដីកសិកម្មមានទំហំ១៥ ២៧៣,៨៩ ហិកតា និងមានគ្រួសារសរុបចំនួន ១៥៤៣ គ្រួសារអាចធ្វើស្រែផលិតស្រូវបានសល់ពីការហូបចុកខ្លះសម្រាប់ការនាំចេញទៅទីផ្សារដោះស្រាយជីវភាព គឺជាស្ថានភាពដែលប្រជាពលរដ្ឋអាចរស់នៅក្នុងជីវភាពសមរម្យបានលើកលែងតែគ្រួសារចំនួន ៣១៣ គ្រួសារ ប៉ុណ្ណោះ ដែលមិនមានដីសម្រាប់ធ្វើកសិកម្មផ្ទាល់ខ្លួន និងមួយចំនួនស៊ីឈ្នួលគេ។

ដូច្នេះបច្ចុប្បន្នទំហំដីកសិកម្មសម្រាប់មួយគ្រួសារមានចំនួន៖

**១៥ ២៧៣,៨៩ ហិកតា/១៥៤៣គ្រួសារ = ៩,៩០ហិកតា/ គ្រួសារ**

បើយោងតាមអនុក្រឹត្យលេខ១៩ ស្តីពីសម្បទានដីសង្គមកិច្ច បានចែងតម្រូវឱ្យមានដីកសិកម្មយ៉ាងច្រើន ២ហិកតានៅក្នុងមួយគ្រួសារ ដែលអាចប្រើប្រាស់សម្រាប់ដោះស្រាយជូន ៣១៣ គ្រួសារ ដែលគ្មានដីពិតប្រាកដ សម្រាប់ធ្វើកសិកម្ម ជាលក្ខណៈគ្រួសារ ដើម្បីអាចទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋ ដែលមាននៅ ទីតាំងផ្សេងពីឃុំកំពង់គោ។

ដូច្នេះដើម្បីធានានិរន្តរភាពនៃការរស់នៅដូចបច្ចុប្បន្ន ចំពោះប្រជាជនដែលមានកំណើនក្នុងរយៈពេល ១៥ឆ្នាំខាងមុខ ត្រូវការដោះស្រាយដីសម្រាប់ធ្វើកសិកម្មចំនួនតាមការគណនាដូចខាងក្រោម៖

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ គ្រួសារកើនឡើងចំនួនៈ២៧០គ្រួសារ

-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ (២០១៧-២០៣២) ដីកសិកម្មត្រូវកើនឡើងៈ

**២៧០គ្រួសារ x ៩,៩០ហិកតា/គ្រួសារ = ២៦៧៣ ហិកតា**

-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ(២០១៧-២០៣២) ដីកសិកម្មសរុបមានចំនួនៈ

**១៥ ២៧៣,៨៩ ហិកតា + ២ ៦៧៣ ហិកតា = ១៧ ៩៤៦,៨៩ ហិកតា**

-ចំណែកការដោះស្រាយដីកសិកម្មជូនគ្រួសារដែលគ្មានដីពិតប្រាកដចំនួន ៣១៣ គ្រួសារតាមរយៈ សម្បទានសង្គមកិច្ចមានចំនួនៈ **៣១៣ គ្រួសារ x ២ ហិកតា/គ្រួសារ = ៦២៦ ហិកតា**

តារាង 33៖ តម្រូវការដីសម្រាប់កសិកម្មក្នុងឆ្នាំ២០៣២

| បរិយាយ | ២០១៧ បច្ចុប្បន្ន | អនាគត ២០៣២ | បម្រែបម្រួលតម្រូវការដី |
|---|---|---|---|
| គ្រួសារ | ១៥៤៣គ្រួសារ | ១៨១៧គ្រួសារ | ២៧០ គ្រួសារ |
| តម្រូវការដីកសិកម្ម | ១៥ ២៧៣,៨៩ ហិកតា | ១៧ ៩៤៦,៨៩ ហិកតា | ២ ៦៧៣ ហិកតា |

### គ.ដីព្រៃឈើ

ព្រៃឈើផ្តល់នូវផលិតផលនានា ដែលមានដូចជា ឈើហ៊ុប ឈើគ្រឿងសង្ហារឹម ឈើបង្គោល ឧស និង អនុផលនានា មានជ័រ វល្លិ ឱសថដែលគាំទ្រដល់ការចិញ្ចឹមជីវិតរបស់ប្រជាជននៅជនបទតាមរយៈការប្រើប្រាស់ ដោយផ្ទាល់ឬតាមរយៈការលក់ដូរ។ ទន្ទឹមនេះព្រៃឈើក៏បានដើរតួយ៉ាងសំខាន់នៅក្នុងចំណោមតួនាទីដទៃទៀត ដូចជា ទាក់ទាញទឹកភ្លៀង បញ្ចុះសីតុណ្ហភាព មានអាកាសធាតុបរិសុទ្ធ (ផ្តល់ខ្យល់អាកាសបរិសុទ្ធ) បញ្ចេញ ឧស្ម័នអុកស៊ីសែន (ជួយស្រូបយកឧស្ម័នកាបូននិច និងបញ្ចេញនូវឧស្ម័នអុកស៊ីសែនទៅដល់មនុស្ស)ការពារគ្រោះ ធម្មជាតិ (ជួយទប់ទល់ខ្យល់ព្យុះ ទឹកជំនន់ ជួយការពារការហូរច្រោះដី និងបាក់ដី)ធ្វើឱ្យដីមានជីជាតិ ជាតំបន់ ទេសចរធម្មជាតិ។ ចំណែកព្រៃលិចទឹកសាប ជាជម្រកត្រីពង ផ្តល់ជីជាតិដី សម្រាប់ធ្វើកសិកម្ម រក្សាជីវសាស្ត្រ ចម្រុះ...។

ចំពោះឃុំកំពង់គោ មានព្រៃតាមដងស្ទឹងមានចំនួន ៥៧,១១ហិកតា ស្មើនឹង ០,២ ភាគរយ ព្រៃលិចទឹក ចំនួន ៣ កន្លែង ដែលមានទំហំសរុបប្រមាណ ៩៣៩ ៤,១៤ ហិកតា ស្មើនឹង ៣៣,៣២ ភាគរយ និងព្រៃដាំឈើ ឡើងវិញ១កន្លែង ទំហំផ្ទៃដីចំនួន១៨,០១ហិកតា ហើយឃុំក៏មានផែនការដាំដើមឈើបន្ថែមនៅលើដីសាធារណៈ ផ្សេងៗ ដូចជា នៅតាមដងផ្លូវ ប្រឡាយ ស្ទឹង អាងស្តុកទឹក សាលាឃុំ សាលារៀន មណ្ឌលសុខភាព និងនៅតាម វត្តអារាមជាដើម សម្រាប់ផ្តល់ផលជាម្លប់ ពណ៌បៃតង ធ្វើឱ្យដីមានជីជាតិ ផ្តល់អុកស៊ីសែន និងស្រូបយកឧស្ម័ន កាបូនិកពីបរិយាកាសជួយដល់សុខភាពប្រជាពលរដ្ឋ។ល។

### ឃ.ធនធានទឹក

ឃុំកំពង់គោ ជាឃុំមានសក្តានុពលទៅលើផ្នែកកសិកម្មដំណាំស្រូវ ដែលនាំឱ្យឃុំកំពង់គោ មានគោលដៅអភិវឌ្ឍរយៈពេលវែងរបស់ខ្លួន ដោយផ្តោតសំខាន់ទលើកសិកម្មដំណាំស្រូវនេះមិនអាចគេចចេញបានឡើយ។ ដូច្នេះ ដើម្បីជំរុញវិស័យកសិកម្មដំណាំស្រូវ កត្តាចាំបាច់មួយនៅក្នុងចំណោមកត្តាជាច្រើន គឺមានកត្តាទឹក ជាកត្តាសំខាន់ដែរ ដែលត្រូវការយកចិត្តទុកដាក់ ដោយត្រូវធ្វើយ៉ាងណាឱ្យមានទឹកគ្រប់គ្រាន់ សម្រាប់ការស្រោចស្រពបានគ្រប់រដូវកាលលើដីស្រែទាំងអស់ដែលឃុំមាន ដើម្បីដោះស្រាយទឹកពេលមានគ្រោះរាំងស្ងួត និងធ្វើស្រែបង្កើនរដូវឱ្យទទួលបានផលិតភាពខ្ពស់ជួយផ្គត់ផ្គង់ដល់ការហូបចុក និងជំរុញការនាំចេញបង្កើនសេដ្ឋកិច្ចគ្រួសារ ក៏ដូចសេដ្ឋកិច្ចជាតិ ដើម្បីឆ្លើយតបបានទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ។

ចំពោះឃុំកំពង់គោបច្ចុប្បន្នមាន ស្ទឹង បឹង អាងស្តុកទឹក និងស្រះ ទំហំផ្ទៃដីសរុប ៣ ២៩៨,២៩ ហិកតា ស្មើនឹង ១១,៧០ ភាគរយ នៃផ្ទៃដីឃុំ ។ នាពេលអនាគត ស្ថានភាពដីនៅក្នុងឃុំកំពង់គោ មិនមានអំណោយផលសមស្របដល់ការរៀបចំអាងស្តុកទឹកបន្ថែម ដើម្បីបំពេញតម្រូវការដល់ការស្រោចស្រព ដែលនាំឱ្យឃុំកំពង់គោមិនមានតម្រូវការដីបន្ថែម សម្រាប់ប្រភពធនធានទឹកនោះទេ ប៉ុន្តែនៅក្នុងឃុំមានផែនការស្តារអាងស្តុកទឹកចំនួន ១ កន្លែង ទំហំផ្ទៃដី ៣៧៥,២៣ហិកតា និងស្តារស្ទឹង ទំហំផ្ទៃដី ៦,៤៤ ហិកតា។

### ង.ហេដ្ឋារចនាសម្ព័ន្ធសង្គម និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត

### ង.១.វិស័យអប់រំ

កុមារគ្រប់រូបមានសិទ្ធិរៀនសូត្រ មិនថាពួកគេស្ថិតនៅក្នុងកាលៈទេសៈបែបណានោះឡើយ។ ការផ្តល់ការគាំទ្រគ្រប់គ្រាន់ដល់ការរៀនសូត្ររបស់កុមារ មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីឱ្យពួកគេអាចអភិវឌ្ឍខ្លួនឈានទៅសម្រេចបានសក្តានុពលរបស់ពួកគេ។ យ៉ាងណាមិញក្នុងឃុំកំពង់គោទៅថ្ងៃអនាគត រយៈពេល១៥ឆ្នាំ ទៅមុខនឹងមានការកើនឡើងនូវចំនួនកុមារនិងមនុស្សវ័យជំទង់ក្នុងវ័យសិក្សា ដូចមាន ការគណនានៅក្នុងចំណុច ២.១.២ ស្តីពីចំណោលប្រជាសាស្ត្រខាងលើ ដែលចាំបាច់ត្រូវគិតគូរធ្វើការដោះស្រាយបន្ទប់រៀនបន្ថែម គ្រប់កម្រិតនៅតាមទីតាំងសាលារៀនដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ន។

- **មត្តេយ្យសិក្សាៈ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ កុមារមានអាយុពី ៣-៥ឆ្នាំ នឹងកើនឡើងចំនួនៈ ៨៤៤ នាក់

-តាមរយៈមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ បានឱ្យដឹងពីការកំណត់សម្រាប់មត្តេយ្យសាលាក្នុងមួយថ្នាក់មានចំណុះកុមារសិក្សារៀនសូត្រ **៥០នាក់**

-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់មត្តេយ្យត្រូវការបន្ថែមចំនួនៈ

**៨៤៤ នាក់ /៥០ នាក់/បន្ទប់ = ១៧ បន្ទប់**

-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ

**១៧ បន្ទប់ / ៥ បន្ទប់/អគារ= ៣ អគារ**

- **បឋមសិក្សា**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ៦-១១ ឆ្នាំនឹងកើនឡើងចំនួនៈ ១១០៩នាក់

-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់បឋមសិក្សាត្រូវការបន្ថែមចំនួនៈ

**១១០៩ នាក់ ៖ ៤៥នាក់/បន្ទប់ = ២៥ បន្ទប់**

-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៦ បន្ទប់បន្ថែមចំនួនៈ

**២៥ បន្ទប់ ៖ ៦ បន្ទប់/អគារ = ៤ អគារ**

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាតែចំនួនៈ

**៤ អគារ/វេន ៖ ២ វេន = ២ អគារ**

❖ **អនុវិទ្យាល័យ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ១២-១៤ ឆ្នាំនឹងកើនឡើងចំនួនៈ ៨២២ នាក់

-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់អនុវិទ្យាល័យសិក្សាត្រូវការបន្ថែមចំនួនៈ

**៨២២ នាក់ ៖ ៤៥ នាក់/បន្ទប់ = ១៨ បន្ទប់**

-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ

**១៨ បន្ទប់ ៖ ១២បន្ទប់/អគារ = ២ អគារ**

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាតែចំនួនៈ

**២ អគារ / វេន ៖ ២ វេន = ១ អគារ**

❖ **វិទ្យាល័យ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ១៥-១៧ឆ្នាំនឹងកើនឡើងចំនួនៈ ៦០៦ នាក់

-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់អនុវិទ្យាល័យសិក្សាត្រូវការបន្ថែមចំនួនៈ

**៦០៦ នាក់ ៖ ៤៥នាក់/បន្ទប់ = ១៣ បន្ទប់**

-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ

**១៣ បន្ទប់ ៖ ១២បន្ទប់/អគារ = ១ អគារ**

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាតែចំនួនៈ

**១ អគារ / វេន ៖ ២ វេន = 0,៥ អគារ**

តារាង 34៖ កំណើនកុមារ តម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១៨ ដល់ឆ្នាំ ២០៣២

| បរិយាយ | បច្ចុប្បន្ន២០១៧ | អនាគត ២០៣២ | បម្រែបម្រួល |
|---|---|---|---|
| | សាលាមត្តេយ្យ | | |
| សិស្ស | ៨០នាក់ | ៨៤៤ នាក់ | ៧៦៤ នាក់ |
| បន្ទប់ | ៣បន្ទប់ | ១៧ បន្ទប់ | ១៤ បន្ទប់ |
| អគារ | ៣ អគារ | ៣ អគារ | 0 អគារ |
| | សាលាបឋមសិក្សា | | |
| សិស្ស | ១១១៩នាក់ | ១១០៩នាក់ | -១០នាក់ |
| បន្ទប់ | ១៩បន្ទប់ | ២៥បន្ទប់ | ៦បន្ទប់ |
| អគារ | ៥ អគារ | ៤អគារ | -១អគារ |
| | អនុវិទ្យាល័យ | | |
| សិស្ស | ១៦៣នាក់ | ៨២២ នាក់ | ៦៥៩ នាក់ |

| | | | |
|---|---|---|---|
| បន្ទប់ | ១០ បន្ទប់ | ១៨ បន្ទប់ | ៨ បន្ទប់ |
| អគារ | ១អគារ | ២ អគារ | ១ អគារ |
| វិទ្យាល័យ | | | |
| សិស្ស | 0 | ៦០៦ នាក់ | ៦០៦ នាក់ |
| បន្ទប់ | 0 | ១៣ បន្ទប់ | ១៣ បន្ទប់ |
| អគារ | 0 | ១ អគារ | ១ អគារ |

### ង.២.សម្រាប់វិស័យសុខាភិបាល

យោងទៅតាមការស្រាវជ្រាវរកឃើញដែលបានរៀបរាប់នៅក្នុងជំពូកទី១ នៃរបាយការណ៍នេះបានឱ្យដឹងថា នៅក្នុងឃុំកំពង់គោ មានមណ្ឌលសុខភាពមួយកន្លែង ដែលមានលទ្ធភាពផ្តល់សេវាកម្ម នៅក្នុងការព្យាបាលជូនប្រជាពលរដ្ឋនៅក្នុងឃុំបានសមស្របរួចហើយ ដែលទៅថ្ងៃអនាគត១៥ឆ្នាំទៅមុខ នឹងមិនមានតម្រូវការដីសម្រាប់រៀបចំទីតាំងផ្តល់សេវាកម្មសុខាភិបាលបន្ថែមនោះទេ ដោយគ្រាន់តែធ្វើការជំរុញការផ្តល់សេវាពីមណ្ឌលសុខភាពដែលមានស្រាប់មួយនេះ ដើម្បីបម្រើជូនដល់ប្រជាពលរដ្ឋក្នុងឃុំឱ្យបានប្រសើរឡើងតែប៉ុណ្ណោះ ហើយក៏នឹងអាចផ្តល់លទ្ធភាពឱ្យមានគ្លីនិចឯកជនបំពេញបន្ថែមទៀតផងដែរ។

### ង.៣.អគ្គិសនី

អគ្គិសនីពិតមានសារៈសំខាន់ណាស់ សម្រាប់ជីវិតរស់នៅរបស់មនុស្សយើង។ អគ្គិសនីផ្តល់ឱ្យយើងនូវសន្តិសុខ សុវត្ថិភាព សុខភាព និងភាពសម្បូររុងរឿង ដូចជា ជួយដោះស្រាយបញ្ហា និងធ្វើឱ្យកាន់តែប្រសើរឡើងនូវសន្តិសុខ សុវត្ថិភាព ការប្រែប្រួលអាកាសធាតុ ផលិតកម្មស្បៀងអាហារ និងការពង្រឹងសេដ្ឋកិច្ចដោយរួមទាំងការអប់រំ និងកម្សាន្តផងដែរ។

បើយោងទៅតាមទិន្នន័យមន្ទីរផែនការឆ្នាំ ២០១៧ បានបង្ហាញថា នៅក្នុងឃុំកំពង់គោ ប្រជាជនប្រើប្រាស់អាគុយសម្រាប់បំភ្លឺផ្ទះមានចំនួន ៤០៨ ខ្នងផ្ទះ ស្មើនឹង ២៨,៨ ភាគរយ បន្ទះសូឡាមានចំនួន ៦២៥ គ្រួសារ ស្មើនឹង ៤៤,១ ភាគរយ ចំណែកបណ្តាញអគ្គិសនីមិនទាន់មាននៅក្នុងឃុំនៅឡើយនោះទេ។ ដូច្នេះនាពេលអនាគត ១៥ឆ្នាំទៅមុខនឹងមានការកើនឡើងចំនួនគ្រួសារថែមទៀត អាជ្ញាធរពាក់ព័ន្ធនៅគ្រប់ជាន់ថ្នាក់ ជាពិសេសក្រុមប្រឹក្សាឃុំកំពង់ស្វាយត្រូវខិតខំយកចិត្តទុកដាក់ក្នុងការដោះស្រាយពង្រីកបណ្តាញអគ្គិសនីតភ្ជាប់ផ្គត់ផ្គង់ឱ្យដល់គ្រប់គ្រួសារបានប្រើប្រាស់។

### ង.៤.ទីលានចាក់សំរាម

សំរាម គឺជារបស់អ្វីៗ ដែលធ្លាក់ក្បែរខ្លួនមនុស្ស ឬធ្លាក់ទៅកន្លែងផ្សេង។ ដូច្នេះសំរាម គឺជាអ្វីៗដែលបំបែកចេញពីបរិស្ថានយើង និងជាការបង្កើតកន្លែងគរមួយផ្សេងទៀត ប្រសិនបើយើងមិនប្រុងប្រយ័ត្ន។ មានគំនរសំរាម នៅពេលមានភ្លៀងធ្លាក់ចុះមក គឺដូចជា ការចម្រោះជាតិពុល គ្រប់បែបយ៉ាង ឱ្យហូរជ្រាបទៅបំពុលដី បំពុលទឹក និងបំពុលដល់ប្រភពទឹកក្នុងស្រទាប់ដីខាងក្រោម ជាហេតុធ្វើឱ្យទឹកស្អាតក្លាយជាទឹកមិនស្អាត មានលោហៈធ្ងន់ និងជួនកាលមានបាក់តេរីកាចៗ ដែលនៅពេលនោះ មានលេចឡើងនូវជម្ងឺរាតត្បាតផ្សេងៗដោយសារតែការទទួលទានទឹកមិនស្អាត។

ចំពោះសំរាមនៅក្នុងឃុំកំពង់គោ បច្ចុប្បន្នប្រជាពលរដ្ឋភាគច្រើនបោះចោលសំរាមនៅក្បែរផ្ទះ ខ្លះចោលរាយប៉ាយនៅតាមផ្លូវ ខ្លះដុតចោល ដែលធ្វើឱ្យរងការបំពុលពីផ្សែងដុត និងបាត់បង់សោភ័ណភាពក្នុងភូមិ ឃុំ។ ដើម្បីអាចគ្រប់គ្រងសំរាមបាន ឃុំត្រូវរកទីតាំងនៅក្នុងឃុំ ដែលនៅដាច់ដោយឡែកឆ្ងាយពីភូមិ ដើម្បីធ្វើទីលានចាក់សំរាមមួយកន្លែង ដើម្បីប្រមូលសំរាមដែលមាននៅក្នុងឃុំ ទៅរក្សាទុកឱ្យបានគត់មត់ ឬត្រូវប្រមូលសំរាមប្លាស្ទីកយកទៅកែច្នៃផលិតឡើងវិញ ចំណែកសំរាមចេញពីផ្ទះបាយ និងស្លឹកឈើផ្សេងពីប្លាស្ទីកអាចកែច្នៃធ្វើជីដូចជា ជីកំប៉ុស្តជាដើម ដើម្បីប្រើប្រាស់នៅក្នុងការបង្កើនគុណភាពដីដាំដុះ។ ជារួមសំខាន់ជាងគេបំផុត គឺត្រូវលុបបំបាត់សំរាមប្លាស្ទីកឱ្យអស់ពីភូមិ ឃុំ។

### ង.៥.ដីកប់ខ្មោច

ជាទូទៅពិធីបូជាសព មានពីរបែបគឺពិធីដុតសព និងកប់សពរក្សាក្នុងដី ដែលពិធីទាំងពីរនេះពីធីកប់សពត្រូវការប្រើប្រាស់ដី ដែលធ្វើឱ្យមានការបាត់បង់ដី សម្រាប់ប្រើប្រាស់បម្រើឱ្យការអភិវឌ្ឍក្នុងសហគមន៍ ដែលមនុស្សរស់នៅ។ នៅក្នុងឃុំកំពង់គោបច្ចុប្បន្ន ក៏មានប្រើពិធីទាំងពីរនេះដែរ ហើយការប្រើប្រាស់ដីក្នុងឃុំកំពង់គោ ក៏មានតម្រូវការកាន់តែច្រើនឡើង ស្របទៅនឹងកំណើនប្រជាពលរដ្ឋទៅអនាគត ដែលចាំបាច់អាជ្ញាធរដែនដីពាក់ព័ន្ធជាពិសេសក្រុមប្រឹក្សាឃុំកំពង់គោ ត្រូវខិតខំយកចិត្តទុកដាក់គិតគូរអំពីពិធីបូជាសពនេះ ដែលនឹងកើតឡើងជាបន្តបន្ទាប់ ដោយគួរខិតខំលប់បំបាត់ការបញ្ចុះសពដោយកប់ក្នុងដី ហើយជំនួសមកវិញដោយការរៀបចំឱ្យមានកន្លែងបូជាសពនៅតាមវត្តអារាម ឬកន្លែងណាផ្សេងដាច់ឆ្ងាយពីភូមិដែលជាជម្រើសល្អបំផុត។

### ង.៦.ស្រះ និងអណ្តូងទឹក

ទឹក គឺជាផ្នែកមួយនៃធាតុដ៏សំខាន់បំផុតសម្រាប់រាងកាយមនុស្ស ជាពិសេសសម្រាប់សុខភាព ដើម្បីធានាបាននូវការរស់រានមានជីវិតរបស់មនុស្ស។ ទឹកអាចមាននៅគ្រប់ទីកន្លែង ប៉ុន្តែមិនត្រូវបានយកមកសម្រាប់ការទទួលទានបានទាំងអស់នោះទេ គឺត្រូវការទឹកដែលស្អាត។ នៅក្នុងឃុំកំពង់គោបច្ចុប្បន្ន មានការប្រើប្រាស់ទឹកស្អាតសម្រាប់ទទួលទានតាមរយៈការប្រើទឹកស្រះ និងអណ្តូងដូចបានរៀបរាប់នៅក្នុងជំពូកទី១នៃរបាយការណ៍នេះ ប៉ុន្តែបានរកឃើញថា ចំនួនស្រះទឹក និងអណ្តូងទាំងអស់នេះ នៅមិនទាន់មានបរិមាណគ្រប់គ្រាន់សម្រាប់បំពេញតម្រូវរបស់មនុស្ស និងសត្វចិញ្ចឹមគ្រប់គ្រាន់នារដូវប្រាំងបានឡើយ។

ដូច្នេះដើម្បីឆ្លើយតបទៅនឹងការខ្វះខាតនាពេលបច្ចុប្បន្ន ក៏ដូចជាឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋនៅក្នុងរយៈពេល១៥ឆ្នាំខាងមុខបាន អាជ្ញាធរដែនដីពាក់ព័ន្ធទាំងអស់ ជាពិសេសក្រុមប្រឹក្សាឃុំកំពង់គោ ត្រូវយកចិត្តទុកដាក់លើកទឹកចិត្តឱ្យប្រជាពលរដ្ឋក្នុងឃុំត្រងទឹកភ្លៀងនៅរដូវវស្សា រក្សាទុកក្នុងអាងស្តុកតាមផ្ទះរៀងៗខ្លួនសម្រាប់ទុកដោះស្រាយការប្រើប្រាស់នៅរដូវប្រាំង ដែលខ្សត់ទឹកហើយថែមពីលើនេះទៀត ក៏ត្រូវបំផុសឱ្យមានការរៀបចំជីកស្រះសហគមន៍ផងដែរ ព្រមទាំងជំរុញលើកទឹកចិត្តដល់វិស័យឯកជន ឱ្យផលិតទឹកស្អាតតបណ្តាញឱ្យដល់គ្រប់ខ្នងផ្ទះ ប្រជាពលរដ្ឋបានប្រើប្រាស់គ្រប់ក្រុមគ្រួសារដែលជាជម្រើសដ៏ល្អបំផុត។

## ២.២.តំបន់រសើប

តំបន់រសើប ជាតំបន់ដែលត្រូវទាមទារនូវការការពារបន្ថែម និងជាពិសេសដោយផ្អែកទៅលើសារៈសំខាន់ឬជីវចម្រុះនៃបរិស្ថាន បេតិកភ័ណ្ឌវប្បធម៌ តម្លៃខាងផ្លូវចិត្ត ដែលមានលក្ខណៈដូចជាតំបន់ប្រពៃណីសម្រាប់ជនជាតិដើមភាគតិច ឬក៏មូលហេតុសំខាន់ៗផ្សេងទៀត។ តំបន់បង្ហាញបញ្ហាចោទចាំបាច់ត្រូវតែកំណត់ ដើម្បីធានាថាឃុំ/សង្កាត់ត្រូវការដឹងឮនូវតម្រូវការ និងប្រធានបទពិសេសទាំងនេះ។

នៅក្នុងឃុំកំពង់គោ តំបន់រសើបមានតំបន់ការពារព្រៃលិចទឹកនៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដីចំនួន ៩ ៧២៨,៥៦ហិកតា ដែលទាមទារនូវកិច្ចការពារបន្ថែមពិសេសនោះ ដោយសារតំបន់នេះមានសារៈសំខាន់ដល់ការធានាលំនឹងធម្មជាតិ ជម្រកមច្ឆាជាតិ របបជលសាស្ត្រ ការសាយភាយនៃល្បាប់ និងជីវចម្រុះនៃបឹងទន្លេសាបនិងតំបន់ពាក់ព័ន្ធ ហើយតំបន់សង្ស័យថាមានមីនក្នុងទីតាំងដីលំនៅឋាន ដែលត្រូវទាមទារនូវកិច្ចការពារគ្រប់គ្រង និងដោះស្រាយជាពិសេស ដោយសារទីតាំងទាំងនេះ ត្រូវធ្វើការហាមឃាត់ប្រជាពលរដ្ឋចូលទៅតំបន់នេះដែលនាំឱ្យមានគ្រោះថ្នាក់ពីគ្រាប់មីនមិនទាន់ផ្ទុះ ព្រមទាំងសហគមន៍នេសាទពីរកន្លែង ក្នុងនោះ១កន្លែង ស្ថិតនៅភាគខាងលិច និង១កន្លែងទៀតស្ថិតនៅខាងកើតនៃឃុំ ដែលទាមទារនូវកិច្ចការពារបន្ថែម ពិសេសនោះដោយសារតំបន់នេះមានសារៈសំខាន់ដល់ជម្រកមច្ឆាជាតិនិងជីវចម្រុះផ្សេងៗទៀត។ តំបន់រសើប ដែលមានក្នុងឃុំកំពង់គោ ដូចបានរៀបរាប់ខាងលើមានបង្ហាញនៅក្នុងផែនទីតំបន់រសើបខាងក្រោម។

ផែនទី 10៖ តំបន់រសើបឃុំកំពង់គោ



## ២.៣.ការប្រឈម

### ២.៣.១.ការប្រឈមដោយធម្មជាតិ

#### ក.កំណើនប្រជាជន

បច្ចុប្បន្ននេះ នៅក្នុងឃុំកំពង់គោ បានរកឃើញថា មានការកើនឡើងចំនួនប្រជាជន ជាមធ្យមប្រចាំឆ្នាំ ១,២១ភាគរយ ។ ដូច្នេះ ទៅថ្ងៃអនាគតបើផ្អែកទៅតាមកំណើន ដែលបានរកឃើញនេះប្រជាពលរដ្ឋក្នុងកំពង់គោ នឹងមានការកើនឡើងបន្ថែមទៀត ដែលនឹងនាំឱ្យមានបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

-មានការខ្វះខាតដីលំនៅឋាន ដែលនាំឱ្យមានការដោះស្រាយផលប៉ះពាល់ទៅដល់ដីស្រែ

-មានការខ្វះខាតដីស្រែ ដែលនាំឱ្យពិបាកដោះស្រាយ ដោយនៅក្នុងឃុំពុំមានដីសល់ទំនេរសម្រាប់បំពេញការខ្វះខាតនេះ

-មានការខ្វះខាតដល់ការផ្តល់សេវាអប់រំ ដែលត្រូវដោះស្រាយការសាងសង់សាលារៀន គ្រូបង្រៀន និងសម្ភារៈសិក្សាបន្ថែម

-ការខ្វះខាតសេវាសុខាភិបាល ដែលត្រូវដោះស្រាយគ្រូពេទ្យ ឧបករណ៍ សម្ភារៈពេទ្យ និងថ្នាំពេទ្យបន្ថែម

-មានការខ្វះខាតទឹកស្អាត អគ្គិសនី ដែលត្រូវដោះស្រាយផ្គត់ផ្គង់បន្ថែម

#### ខ.គ្រោះធម្មជាតិការរេចរឹលនៃធម្មជាតិ

បច្ចុប្បន្នក្នុងឃុំកំពង់គោ បានរកឃើញថា មានជួបប្រទះនូវគ្រោះធម្មជាតិកើតឡើងដូចជា គ្រោះរាំងស្ងួត ហើយដីធ្លី ដែលជាធនធានធម្មជាតិកម្រក៏មានភាពរេចរឹលទៅៗ ដូចជាធ្វើឱ្យដីស្រែរឹងនិងខ្សោះជីជាតិដោយសារការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិតលើដំណាំស្រូវ ដែលទាំងនេះជាការប្រើប្រាស់ដីខុសទំនងមិនសមស្រប ទៅនឹងបច្ចេកទេសកសិកម្ម។ ទន្ទឹមនេះ មានការថយចុះ និងបាត់បង់ធនធានមច្ឆាជាតិ ដោយសារការប្រើប្រាស់ឧបករណ៍ឆក់ដែលជាការនេសាទខុសច្បាប់ ដែលទៅថ្ងៃអនាគតនៅតែជួបប្រទះនូវបញ្ហាប្រឈមនេះដដែល បើមិនមានដំណោះស្រាយសម្រាប់ទប់ទល់ទៅនឹងគ្រោះរាំងស្ងួត និងមានការកែប្រែឥរិយាបថក្នុងការប្រើប្រាស់ដីធ្លីសម្រាប់កសិកម្មឱ្យបានសមស្របទេនោះ។

### ២.៣.២.ការប្រឈមដោយ ការអភិវឌ្ឍដែលពុំមាននិរន្តរភាព

ជាការពិតណាស់រាល់គម្រោងអភិវឌ្ឍនានា ដែលពាក់ព័ន្ធការប្រើប្រាស់ធនធានធម្មជាតិ ជាពិសេស ការប្រើប្រាស់ដីក្នុងទីតាំងភូមិសាស្ត្រណាមួយ តែងនាំមកការរីកចម្រើនជានិច្ច តែផ្ទុយទៅវិញបើគម្រោងអភិវឌ្ឍទាំងនោះពុំទាន់បានគិតគូរគ្រប់ជ្រុងជ្រោយទៅដល់ទីតាំងភូមិសាស្ត្រនីមួយៗ និងសក្តានុពលនៃធនធាន ដែលមាន វានឹងនាំមកនូវផលប៉ះពាល់ដល់សេដ្ឋកិច្ច សង្គម និងបរិស្ថាននូវពេលអនាគត ដោយមិនអាចធានាចីរភាពនៃគម្រោងទាំងនោះដល់កូនចៅជំនាន់ក្រោយនៅក្នុងតំបន់នោះបានឡើយ ដូចជា ស្ថានភាពនៅក្នុងឃុំកំពង់គោ ដែលជាឃុំគោលដៅសិក្សារៀបចំផែនការប្រើប្រាស់ដី ដូចដែលបានរៀបរាប់នៅក្នុងជំពូកទី ១ នៃរបាយការណ៍នេះ បានឱ្យដឹងថា ឃុំកំពង់គោមានស្ថានភាពភូមិសាស្ត្រជាវាលទំនាបដែលមានធនធានដីអំណោយផលដល់ដំណាំស្រូវ ដែលជាសក្តានុពល សម្រាប់ការអភិវឌ្ឍដល់ឃុំនេះ ដោយមិនមានការអះអាងណាផ្សេងក្រៅពីនេះនៅឡើយ។ ដូចនេះឃុំកំពង់គោ គួរចៀសវាងដាច់ខាតនៅគម្រោងអភិវឌ្ឍទាំងឡាយណាដែលនាំឱ្យមានផលប៉ះពាល់ដល់ការបាត់បង់ដីស្រែដែលខ្លួនមាន ធ្វើឱ្យឃុំកំពង់គោមានការថយចុះឱកាសអភិវឌ្ឍ ដូចជា គម្រោងចាក់លុបដីស្រែ បង្កកទុកលក់ឬពុះដីឡូត៍លក់ ដើម្បីកេងផលចំណេញពីឈ្មួញគម្រោងជីកយកអាចម៍ដីលក់ជាដើម លើកលែង

តែគម្រោងណា ដែលពាក់ព័ន្ធដែលធ្វើឱ្យប្រសើរឡើងដល់ប្រព័ន្ធកសិកម្ម ដូចជា កសិដ្ឋានផលិតពូជស្រូវ ស្រែគម្រូ ផលិតជី ទុកដាក់គ្រឿងយន្តកសិកម្ម ទន្ទឹមនិងនេះ ក៏មានគម្រោងអភិវឌ្ឍដល់ការរស់នៅនិងបរិស្ថាន ដែលគួរជៀសវាងផងដែរ ដូចជា គម្រោងបង្កើតសិប្បកម្ម ឧស្សាហកម្ម ដែលធ្វើឱ្យមានការបង្ហូរទឹកស្អុយ កខ្វក់។ ទន្ទឹមនឹងការប្រឈមដោយការអភិវឌ្ឍខាងលើត្រូវជៀសវាង ក៏នៅមានការប្រឈមផ្សេងទៀតទៅ និងអំពើអនាធិបតេយ្យ ដែលកើតឡើងពីការដោះស្រាយការខ្វះខាតរបស់ប្រជាពលរដ្ឋក្នុងឃុំផងដែរ ដូចជាការស្នាក់នៅលើដីតាមមាត់ស្ទឹង ប្រឡាយ តាមចិញ្ចើមផ្លូវសាធារណៈ ការទន្ទ្រានដីទួលសាធារណៈ ធ្វើស្រែបំពានលើប្រឡាយ ការនេសាទខុសច្បាប់ជាដើម។

## ២.៤.ឱកាស

### ២.៤.១.ដោយអំណោយផលពីធម្មជាតិ

នៅលើលោកយើងនេះ ធម្មជាតិ គឺពិតជាបានផ្តល់នូវធនធានដ៏មានសារសំខាន់ សម្រាប់ធ្វើអ្វីៗគ្រប់យ៉ាង ដែលមនុស្សចង់ធ្វើ ដូចជាមនុស្សបានប្រើប្រាស់ធនធានដី និងទឹកសម្រាប់ការដាំដុះ ឈើធ្វើឧសដុត សម្រាប់ផ្តល់កំដៅ ឬសាងសង់ទីជម្រក ខ្យល់អាកាស ធ្យូងថ្ម ប្រេង ឧស្ម័នធម្មជាតិ និងរ៉ែជាវត្ថុធាតុដើមជាច្រើនទៀត ដូចជាដែកទង់ដែងជាដើម សម្រាប់ធ្វើឧបករណ៍ប្រើប្រាស់ផ្សេងៗ។ ចំណែកនៅក្នុងឃុំកំពង់គោ យើងផ្តោតសំខាន់លើធនធានដី ដែលមានសក្តានុពលលើសលប់ទៅលើការអភិវឌ្ឍឃុំ ដូចបានរកឃើញ និងរៀបរាប់នៅក្នុងជំពូកទី១ នៃរបាយការណ៍នេះ។ នៅក្នុងឃុំកំពង់គោមានស្ថានភាពអំណោយផលពីធម្មជាតិដូចខាងក្រោម៖

- ស្ថានភាពដី ជាវាលទំនាប ដែលអំណោយផលដល់ការដាំដុះដំណាំស្រូវ
- នៅជិតប្រភពស្ទឹង បឹង អាងស្តុកទឹក អូរ អាចមានលទ្ធភាពនាំទឹកមកស្រោចស្រពដំណាំស្រូវ នៅពេលជួបប្រទះគ្រោះរាំងស្ងួត និងមានលទ្ធភាពនាំទឹកមកស្រោចស្រពបង្កើនរដូវធ្វើស្រែបានច្រើនដង។
- នៅរដូវវស្សាមានភ្លៀងធ្លាក់ច្រើនអាចស្រោចស្រពដំណាំស្រូវ ។
- អាកាសធាតុ ក្តៅ ហើយសើម អំណោយផលដល់ការលូតលាស់របស់រុក្ខជាតិ ។

### ២.៤.២.ដោយបច្ចេកវិទ្យាថ្មីៗ

ជីវិតរស់នៅ ដែលយើងកំពុងទទួលបានភាពប្រសើរឡើងនាពេលបច្ចុប្បន្ននេះ គឺដោយសារតែមានការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា។ បច្ចេកវិទ្យាថ្មីៗ ធ្វើឱ្យមានការផ្លាស់ប្តូរកាន់តែប្រសើរឡើង សម្រាប់ជីវិតរស់នៅរបស់ពលរដ្ឋ ដែលធ្វើឱ្យអ្វីៗនៅក្នុងពេលបច្ចុប្បន្នកាន់តែប្រសើរឡើង និងងាយស្រួលជាងមុន។ បច្ចេកវិទ្យាថ្មីអាចកាត់បន្ថយបាននូវពេលវេលា គុណភាព និងការចំណាយទៅលើកម្លាំងពលកម្មក្នុងផលិតកម្មនានា។

បច្ចុប្បន្នស្ថានភាពនៅក្នុងឃុំកំពង់គោ គឺមានសក្តានុពលខ្លាំងដោយពឹងផ្អែកទៅលើផលិតកម្មដំណាំស្រូវ ហើយនាពេលអនាគត ក៏នៅតែពឹងផ្អែកលើផលិតកម្មដំណាំទាំងនេះ ដដែលដែរនោះ ប្រជាពលរដ្ឋនឹងចាំបាច់ត្រូវការបច្ចេកវិទ្យាទំនើបទាន់សម័យ សម្រាប់វិស័យកសិកម្មដំណាំស្រូវ ដើម្បីជួយជំរុញឱ្យមានការកើនឡើងទិន្នផលខ្ពស់ ដើម្បីអាចដោះស្រាយបាននូវសន្តិសុខស្បៀង និងមានប្រាក់ចំណូលកាន់តែខ្ពស់ ដែលនាំឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង ក្នុងពេលដែលមានកំណើនប្រជាពលរដ្ឋកាន់តែខ្ពស់ នាពេលខាងមុខ ។ តាមរយៈបច្ចេកវិទ្យាថ្មីៗ នឹងនាំឱ្យប្រជាពលរដ្ឋមានឱកាសអាចប្រើប្រាស់គ្រឿងយន្តកសិកម្មទំនើបទាន់សម័យ សម្រាប់ការផលិតដំណាំស្រូវ ដែលរួមមានដូចជា៖ ម៉ាស៊ីនភ្ជួររាស់ដី ម៉ាស៊ីនពង្រាបដីស្រែដោយ

ប្រើប្រព័ន្ធឡាស៊ែរ ម៉ាស៊ីនដកស្ទូង ជ្រូនបាញ់ថ្នាំសម្លាប់សត្វល្អិត និងដាក់ជី ម៉ាស៊ីនច្រូតកាត់ និងបោកបែន ព្រមទាំងគ្រឿងយន្តដឹកជញ្ជូនជាដើម។ល។

### ២.៤.៣.ដោយគម្រោងវិនិយោគ

សម្រាប់នាពេលអនាគត ឃុំកំពង់គោ ដែលមានសក្តានុពលខ្ពស់ទៅលើដំណាំស្រូវនោះ នឹងនាំឱ្យមានការផ្តួចផ្តើមបង្កើតគម្រោងវិនិយោគនានា ដែលភាគច្រើនផ្តោតទៅលើដំណាំស្រូវ ដូចជាគម្រោងបង្កើតកសិដ្ឋានកសិកម្ម ដើម្បីជំរុញផលិតកម្មដំណាំស្រូវ និងដំណាំចម្ការ ព្រមទាំងគម្រោងវិនិយោគទៅលើការកែច្នៃផលិតផលកសិកម្ម ដើម្បីនាំចេញ ដែលនឹងផ្តល់ការងារបន្ថែមទៀតទៅដល់ប្រជាពលរដ្ឋ ដើម្បីបង្កើនប្រាក់ចំណូលឱ្យបានកាន់តែខ្ពស់ ដែលអាចធ្វើឱ្យជីវភាពរស់នៅកាន់តែប្រសើរឡើង ព្រមទាំងកាត់បន្ថយបាននូវភាពក្រីក្រ ស្របទៅតាមគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

## ២.៥.បញ្ហា មូលហេតុ និងដំណោះស្រាយ

ផ្អែកទៅតាមការរកឃើញ នៅក្នុងជំពូកទី១ នៃរបាយការណ៍នេះ អាចឱ្យយើងធ្វើការវិភាគ និងចងក្រងបាននូវបញ្ហា ដែលកើតមាននៅក្នុងឃុំកំពង់គោ។ មូលហេតុដែលនាំឱ្យកើតមានបញ្ហា និងដំណោះស្រាយលើបញ្ហាទាំងអស់នេះ គឺត្រូវបានបង្ហាញនៅក្នុងតារាង និងនៅក្នុងផែនទី ដូចមាននៅខាងក្រោមនេះ៖

តារាង 35៖ បញ្ហាប្រឈម (ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ)

| បញ្ហា | ទីតាំងបញ្ហា | មូលហេតុ | ដំណោះស្រាយ |
|---|---|---|---|
| ១.លំនៅឋាន នៅលើដីចំណីស្ទឹង ២៥០ គ្រួសារ)  | ស្ទឹងសែន | ក-រស់នៅតាំងពីដូនតាមក | ក-ខ- ដោះស្រាយតាមរយៈដីសម្បទានសង្គមកិច្ច |
| | | ខ-កំណើនគ្រួសារក្នុងភូមិ | |
| ២.ខ្វះដីកសិកម្ម ៣១៣ គ្រួសារ | គ្រប់ភូមិ | ក-លក់សងបំណុល | ក-ខ-គ-១-ស្នើសុំសម្បទានសង្គមកិច្ច<br>ក-ខ-គ-២-ផ្តល់បច្ចេកទេសកសិកម្មទំនើបៗ |
| | | ខ-កំណើនគ្រួសារក្នុងភូមិ | |
| | | គ-ដីកសិកម្មតិច | |
| ៣.គ្រប់មីននៅសេសសល់  | -កំពង់គោក្រោម<br>-ខ្សាច់ជីរស់<br>-កោះគ្របបាយ | ក-ជាកន្លែងសមភូមិប្រយុទ្ធ | ក-១-ដាក់សញ្ញាសំគាល់ដីដែលមានមីន និងគ្រាប់មិន ទាន់ផ្ទុះ<br>ក-២-ដាក់សំណើទៅអង្គភាពកំចាត់មីនឬអង្គការដើម្បី ជួយអន្តរាគមន៍ |
| ៤-ទិន្នផលស្រូវទាប  | ដីស្រែ | ក-ដីខ្វះជីជាតិ | ក-១-បណ្តុះបណ្តាលផលិតជីកំប៉ុស្ត<br>ក-២-បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី<br>ក-៣-ជំរុញការចិញ្ចឹមសត្វដើម្បីបានលាមក |
| | | ខ-ខ្វះបច្ចេកទេសកសិកម្ម | ខ-១-បណ្តុះបណ្តាលពីបច្ចេកទេសផលិតពូជស្រូវ |

| | | | |
|---|---|---|---|
| | | | ខ-២-បណ្តុះបណ្តាលពីការដាំដំណាំស្រូវ<br>ខ-៣-បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី<br>ខ-៤-បណ្តុះបណ្តាលបច្ចេកទេសផលិតជីកំប៉ុស្ត<br>ខ-៥-ប្រើប្រាស់ពូជស្រូវសុទ្ធល្អតាមស្តង់ដា |
| ៥-ខ្វះទឹកស្រោចស្រព<br> | ដីស្រែ | ក-ប្រព័ន្ធធារាសាស្ត្ររងការខូចខាត | ក-១-ស្តារប្រឡាយឡើងវិញ<br>ក-២-ជួសជុល និងរៀបចំទ្វារទឹក |
| | | ខ-ធ្វើស្រែក្នុងប្រឡាយ | ខ-១-ស្រង់ស្ថិតិអ្នកធ្វើស្រែក្នុងប្រឡាយ<br>ខ-២-ផ្សព្វផ្សាយពីច្បាប់ភូមិបាល និងច្បាប់ពាក់ព័ន្ធនានា។<br>ខ-៣-រកវិធីដោះស្រាយនិងធ្វើកិច្ចសន្យាបញ្ឈប់ |
| ៦-ផ្លូវរងការខូចខាត<br><br> | -ផ្លូវគ្រួសក្រហមពីភូមិកោះគ្របបាយទៅកំពង់គោក្រោម<br>-ផ្លូវគ្រួសក្រហមពីភូមិកំពង់គោលើទៅភូមិខ្សាច់ជីរស់ | ក-ឡានធុនធ្ងន់ដឹកលើសទំងន់ឆ្លងកាត់ | ក-១-ជួសជុលផ្លូវដែលរងការខូចខាត<br>ក-២-ពង្រឹងការអនុវត្តន៍ច្បាប់ចរាចរទប់ស្កាត់ឡានដឹកលើសទំងន់តាមរយៈដាក់សញ្ញាកំណត់ទំងន់ដឹកជញ្ជូនរបស់រថយន្ត<br>ក-៣-ដាក់បារាស់ផ្លូវមានរថយន្តធំឆ្លងកាត់ |
| | | ខ-ចងគោ ក្របីលើផ្លូវ | ខ-១-ជួសជុលផ្លូវដែលរងការខូចខាត<br>ខ-២-ដាក់បំរាមហាមចងគោ ក្របីលើផ្លូវ |
| | | គ-ខ្វះការថែទាំផ្លូវ | គ-១-ជួសជុលផ្លូវដែលរងការខូចខាត<br>គ-១-បង្កើតគណៈកម្មការថែទាំផ្លូវ |
| ៧. បាត់បង់ព្រៃលិចទឹក<br> | តំបន់៣ | ក-កាប់រានយកដីធ្វើស្រែប្រាំង | ក-១- ទប់ស្កាត់ការកាប់បំផ្លាញព្រៃលិចទឹក<br>ក-២-ត្រូវអនុវត្តច្បាប់ដោយការដាក់ទោសទណ្ឌចំពោះអ្នកកាប់បំផ្លាញព្រៃលិចទឹក<br>ក-៣-ផ្សព្វផ្សាយច្បាប់ជលផល |
| ៨-ធនធានមច្ឆាថយចុះនិងបាត់បង់<br> | បឹង ស្ទឹង អាងស្តុកទឹក | ក-នេសាទខុសច្បាប់ | ក-១-ផ្សព្វផ្សាយច្បាប់ជលផល និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា<br>ក-២-ហាមឃាត់ការប្រើប្រាស់ឧបករណ៍ឆក់ខុសច្បាប់<br>ក-៣-ធ្វើវារីវប្បកម្ម |
| ៩-ខ្វះទឹកស្អាតប្រើប្រាស់ | ក្នុងឃុំ | ក-គ្មានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត | ក-១-យកចិត្តទុកដាក់ជម្រុញឱ្យមានសេវាកម្មផ្គត់ផ្គង់ប្រព័ន្ធទឹកស្អាតបានដល់គ្រប់ភូមិ |
| | | ខ-គ្រួសារមួយចំនួនខ្វះសម្ភារៈបរិក្ខារចម្រោះទឹកស្អាត | ខ-១-បំផុសឱ្យប្រជាពលរដ្ឋមានការប្រើប្រាស់ធុងចម្រោះទឹកស្អាត |

ផែនទី 11៖ បញ្ហា មូលហេតុ និងដំណោះស្រាយ



# ជំពូក៣ ៖ ផែនការប្រើប្រាស់ដីអនាគតឆ្នាំ ២០១៧-២០៣២

## ៣.១.តម្រូវការ ស្ថានភាព និងសក្តានុពលដីជាក់ស្តែង

### ៣.១.១.តម្រូវការដីទៅតាមប្រភេទ

នៅពេលអនាគតរហូតទៅដល់ឆ្នាំ ២០៣២ នៅក្នុងឃុំកំពង់គោ នឹងមានការកើនឡើងចំនួនប្រជាជន ១ ៣៩៥ នាក់ ដែលត្រូវនឹងចំនួន ២៧០ គ្រួសារ ដែលនៅបច្ចុប្បន្ននេះមានអ្នកគ្មានដីលំនៅឋានពិតប្រាកដចំនួន ២៥០ គ្រួសារ និងអ្នកគ្មានដីកសិកម្មពិតប្រាកដ ដែលត្រូវការដោះស្រាយទៅអនាគតមានចំនួន ៣១៣ គ្រួសារ ។ ដោយសារកំណើនប្រជាពលរដ្ឋនេះហើយ ដែលតម្រូវឱ្យមានការគិតគូរយកចិត្តទុកដាក់ទៅដល់ការរកដីបន្ថែមសម្រាប់លំនៅឋាន និងដីស្រែជូនទៅដល់ប្រជាពលរដ្ឋដែលមានចំនួនកើនឡើង ដើម្បីធានាឱ្យមាននិរន្តរភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋ នៅក្នុងឃុំកំពង់គោទៅថ្ងៃអនាគតបន្តពីពេលបច្ចុប្បន្ន ដូចបានរកឃើញនៅក្នុងជំពូក ២ ខាងលើនៃរបាយការណ៍នេះ។ តែដោយសារទំហំផ្ទៃដីដែលត្រូវបានប្រើប្រាស់បច្ចុប្បន្ននៅក្នុងឃុំ ពុំមានប្រែប្រួលកើនឡើងស្របគ្នាទៅនឹងកំណើនប្រជាពលរដ្ឋនាពេលអនាគត ដើម្បីអាចដោះស្រាយបានតាមតម្រូវការដីសម្រាប់លំនៅឋាន និងដីស្រែបន្ថែមនោះជាដំណោះស្រាយសមស្របដីសម្រាប់លំនៅឋានត្រូវប្រើប្រាស់ដីភូមិលំនៅឋានដែលមានស្រាប់ ពីព្រោះស្ថានភាពការតាំងលំនៅឋានបច្ចុប្បន្នមិនទាន់មានភាពចង្អៀត ដែលអាចមានលទ្ធភាពទ្រទ្រង់ដល់ការសាងសង់លំនៅឋានបន្ថែមទៀតបានសម្រាប់រយៈពេល ១៥ ឆ្នាំទៅមុខ ហើយម្យ៉ាងទៀតការតាំងលំនៅឋានមានលក្ខណៈប្រមូលផ្តុំនឹងផ្តល់ភាពងាយស្រួលដល់ការផ្គត់ផ្គង់ទឹកស្អាត ភ្លើង និងសេវាសង្គមផ្សេងៗទៀតដូចជាសេវាអប់រំ សេវាសុខភាព ជាដើម។ល។

ចំណែកដីស្រែមិនត្រឹមតែមិនបានពង្រីកបន្ថែមទៅតាមការគិតគូរខាងលើនោះទេ តែត្រូវបានថយចុះទំហំផ្ទៃដីមួយចំនួនថែមទៀត ដោយសារផ្ទៃដីស្រែប្រាំងដែលមានបច្ចុប្បន្ននេះមួយចំនួនស្ថិតនៅក្នុងតំបន់ការពារជុំវិញបឹងទន្លេសាប ដែលក្នុងនោះមានទំហំផ្ទៃដីចំនួន ១៨,០១ ហិកតា ដែលស្ថិតនៅជុំវិញបឹងរៀល ទៅថ្ងៃអនាគតត្រូវរក្សាទុកជាដីការពារនឹងត្រូវដាំព្រៃឡើងវិញ និងបន្ថែមពីលើនេះប្រសិនបើដីស្រែប្រាំងក្នុងតំបន់៣ ដែលជាដីការពារជុំវិញបឹងទន្លេសាបមានផ្ទៃដីទំហំ៩៧១០,៥៥ហិកតា មិនត្រូវបានទទូលការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យប្រជាពលរដ្ឋកាន់កាប់និងអាស្រ័យផល ដោយមានការស្នើសុំពីអាជ្ញាធរដែនដីទេនោះ ផ្ទៃដីទាំងនេះនឹងត្រូវប្រើប្រាស់ជាដីព្រៃលិចទឹកដែលត្រូវការពារឡើងវិញ។ ជាដំណោះស្រាយ ត្រូវតែគិតគូរពិចារណាដោយធ្វើការយកចិត្តទុកដាក់ តាមរយៈការបង្កើនផលិតភាព គុណភាព និង ពិពិធកម្មកសិកម្មដំណាំស្រូវ ដោយត្រូវធ្វើស្រែបង្កើនរដូវឱ្យបានពី២ដងក្នុងមួយឆ្នាំ និងធ្វើស្រែតាមបែបប្រពលវប្បកម្ម ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍកសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា។

ចំពោះដីបឹងវិញបច្ចុប្បន្នមានផ្ទៃដីទំហំ៩៩១,១៨ហិកតា ទៅថ្ងៃអនាគតនឹងត្រូវបានកំណត់ការប្រើប្រាស់តាមតម្រូវការទៅលើផ្ទៃដីបឹងទំហំ ៧៥,៩ ហិកតា ជាបឹងសហគមន៍នេសាទ ដែលត្រូវមានកិច្ចការពារពិសេស។

### ៣.១.២.ស្ថានភាពនៃដីធ្លី និងសក្តានុពល

នៅពេលអនាគត ធនធានដីនៅក្នុងឃុំកំពង់គោនៅតែរក្សាទំហំក្រឡាផ្ទៃសរុប ២៨ ១៩១,៤៥ ហិកតាដដែល ដោយពុំមានការប្រែប្រួលអ្វីឡើយ ហើយដីធ្លីទាំងនេះ នឹងមានការប្រើប្រាស់សម្រាប់សាងសង់លំនៅឋាន ( រួមទាំងហេដ្ឋារចនាសម្ព័ន្ធមួយចំនួននិងដំណាំជុំវិញលំនៅឋាន ) ដីស្រែ (រួមទាំងប្រព័ន្ធធារាសាស្ត្រនឹងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន) ដីព្រៃឈើ ដីស្មៅ បឹង អាងស្តុកទឹក និងស្រះ ដូចការប្រើប្រាស់ដីធ្លីបច្ចុប្បន្នដដែល ដោយគ្រាន់តែមានការប្រែប្រួលតិចតួចពីដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាបទៅជាដីដាំព្រៃឡើងវិញ ដីស្រែប្រាំងនៅក្នុង

តំបន់៣ ដែលជាដីការពារនៅជុំវិញបឹងទន្លេសាបនឹងទៅជាដីព្រៃលិចទឹកវិញ ប្រសិនបើមិនត្រូវបានអនុញ្ញាតពីរាជរដ្ឋាភិបាល ឱ្យប្រជាពលរដ្ឋកាន់កាប់អាស្រ័យផល ដោយមានការស្នើសុំពីអាជ្ញាធរដែនដីទេនោះ ពីព្រោះដីធ្លីដែលបានប្រើប្រាស់ក្នុងពេលបច្ចុប្បន្ននេះបានសមស្របនិងចំសក្តានុពលនៃដីរួចហើយ។ ចំណែកទំហំផ្ទៃដីតំបន់ប្រើប្រាស់នីមួយៗដូចមានរៀបរាប់នៅក្នុងសេចក្តីអត្ថាធិប្បាយអំពីការបែងចែកដីតាមតម្រូវការប្រើប្រាស់ខាងក្រោមនេះ។ ជាទូទៅធនធានដីនៅក្នុងឃុំកំពង់គោមាន សក្តានុពលខ្ពស់សមស្របទៅលើកសិកម្មដំណាំស្រូវ ដោយសារដីនៅក្នុងឃុំមានទីតាំងភូមិសាស្ត្រ អំណោយផលពីធម្មជាតិដូចបានរៀបរាប់ក្នុងជំពូកទី២ខាងលើ។ ដូច្នេះការប្រើប្រាស់ដីនាពេលបច្ចុប្បន្ន និងការសម្រេចចិត្តប្រើប្រាស់ដីទៅថ្ងៃអនាគតនៅក្នុងឃុំ ដែលបានផ្តោតសំខាន់ទៅលើកសិកម្មដំណាំស្រូវជាចំបង គឺជាការប្រើប្រាស់បានត្រឹមត្រូវចំសក្តានុពលនៃដី ហើយក៏ជាការគាប់ជួនដែលភាពអំណោយផលពីធនធានដីនៅក្នុងឃុំសមស្របទៅលើវិស័យកសិកម្មដំណាំស្រូវ ក៏ស្របទៅនឹងគោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងតួនាទីវិស័យកសិកម្មក្នុងការបង្កើតការងារ ការធានាសន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍជនបទដែលមានចែងក្នុងមុំទី១ ចតុកោណទី៤ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា ដែលជាការផ្តល់ឱកាស ដ៏ល្អដល់អាចអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួនឱ្យឃុំមានការរីកចម្រើន បានតាមរយៈការជំរុញធ្វើពិពិធកម្មកសិកម្មដំណាំស្រូវនៅលើ ផ្ទៃដីកសិកម្មដ៏ធំល្វឹងល្វើយស្ទើរតែពេញដែនដីឃុំទាំងមូល ដើម្បីបង្កើនទិន្នផលស្រូវ ដែលជាដំណាំដ៏មានសារៈសំខាន់ សម្រាប់ជាស្បៀងផ្គត់ផ្គង់ការហូបចុកមិនអាចខ្វះបាននិងការនាំចេញទៅលក់នៅទីផ្សារ ដើម្បីបានចំណូលផ្គត់ផ្គង់តម្រូវការចាំបាច់ក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង រួមទាំងចូលរួមក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ តាមរយៈសកម្មភាពធ្វើពាណិជ្ជកម្មនាំអង្ករចេញ របស់រាជរដ្ឋាភិបាលកម្ពុជា។

ចំណែកដីដែលមានទំហំតិចតួច ដែលបានកំណត់ជាការប្រើប្រាស់ដីសម្រាប់សាងសង់លំនៅឋាននៅលើដីខ្ពស់ជាប់តាមដងផ្លូវសំខាន់ៗ ដែលមិនលិចទឹកនៅរដូវវស្សា បានផ្តល់ភាពងាយស្រួលក្នុងការធ្វើដំណើរចេញចូល និងងាយស្រួលនៅក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត សម្រាប់បម្រើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំបានប្រកបដោយផាសុកភាព ព្រមទាំងដីប្រើប្រាស់សម្រាប់ប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត គឺជាការប្រើប្រាស់បានត្រឹមត្រូវផងដែរ។

ស្ថានភាពដី ដែលត្រូវប្រើប្រាស់ទាំងនោះ មានដីកសិកម្មដំណាំស្រូវមួយចំនួនតូច នៅភាគខាងជាងឆៀងខាងកើតជាកម្មសិទ្ធិរបស់ឯកជន។ ដីលំនៅឋាន និងដីកសិកម្មដំណាំស្រូវភាគច្រើននៅភាគកណ្តាលនៃឃុំគឺស្ថិតនៅក្នុងតំបន់២នៃតំបន់ព្រៃលិចទឹក ដែលជាដីរបស់រដ្ឋ ត្រូវបានកាន់កាប់អាស្រ័យផលដោយប្រជាពលរដ្ឋ និងដីស្រែមួយផ្នែកធំនៅភាគចុងខាងត្បូងនៃឃុំស្ថិតនៅក្នុងតំបន់៣នៃតំបន់ព្រៃលិចទឹក ជាដីសាធារណៈរបស់រដ្ឋដែលត្រូវបានកាន់កាប់អាស្រ័យផលដោយប្រជាពលរដ្ឋ ។ ដីអាងជាច្រើនស្ថិតនៅភាគខាងត្បូងឆៀងខាងលិចនៃឃុំ គឺស្ថិតនៅក្នុងតំបន់២ និងតំបន់៣នៃតំបន់ព្រៃលិចទឹក ដែលជាដីសាធារណៈរបស់រដ្ឋត្រូវបានកាន់កាប់អាស្រ័យផលដោយប្រជាពលរដ្ឋ ហើយចំណែកដីស្ទឹង ដីបឹង ប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធ គឺជាដីសាធារណៈរបស់រដ្ឋ ដែលយើងទាំងអស់គ្នាត្រូវធ្វើការការពារថែទាំឱ្យបានគង់វង្ស សម្រាប់បម្រើឱ្យជាផលប្រយោជន៍សាធារណៈ ដោយមិនត្រូវឱ្យមានការរំលោភកាន់កាប់ប្រើប្រាស់ បម្រើផលប្រយោជន៍បុគ្គលផ្ទាល់ខ្លួនបានឡើយ។

## ៣.២.ការបែងចែកដីទៅតាមតម្រូវការប្រើប្រាស់

### ៣.២.១.ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ

ជាទូទៅរាល់ការកំណត់តំបន់ប្រើប្រាស់ដី ត្រូវបានផ្ដោតសំខាន់លើមុខងារនៃការប្រើប្រាស់ដី សម្រាប់គោលបំណងផ្សេងៗដូចជា ផ្លូវ កសិកម្ម លំនៅឋាន ពាណិជ្ជកម្ម សួនកម្សាន្ត ព្រៃឈើ ។ល។ ទន្ទឹមនឹងនោះ ការប្រើប្រាស់ដីតែងតែមានការផ្លាស់ប្ដូរមុខងាររបស់វា តែការផ្លាស់ប្ដូរមុខងារប្រើប្រាស់ដីទាំងនេះត្រូវតែគិតគូរពិចារណាឱ្យបានហ្មត់ចត់ ដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវទៅតាមស្ថានភាពច្បាប់ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ហើយត្រូវតែប្រាកដថា ដីដែលក្រោយពីបានប្ដូរមុខងារប្រើប្រាស់ហើយនោះ ត្រូវតែមានតម្លៃសេដ្ឋកិច្ច ឬផលប្រយោជន៍ខ្ពស់ជាងមុខងារប្រើប្រាស់ពីមុន តាមរយៈការរក្សាជំហរច្បាស់លាស់ ក្នុងការបង្កើនធនធានប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពជាមួយនឹងផលប៉ះពាល់ដ៏តិចតួចបំផុតចំពោះមនុស្សនៅជំនាន់ក្រោយ។ ឧទាហរណ៍ដូចជា ការផ្លាស់ប្ដូរពីដីព្រៃឈើរេចរឹលទៅជាដីសម្រាប់កសិកម្ម ដែលវានឹងនាំឱ្យមានការបាត់បង់បរិមាណដីព្រៃឈើ ដែលផ្ដល់ប្រយោជន៍ច្រើនយ៉ាងដល់សហគមន៍មូលដ្ឋាន តែជំនួសមកវិញដោយវាលស្រែសម្រាប់ផលិតកម្មស្រូវ ដែលជាចំណីអាហារដ៏សំខាន់ សម្រាប់ជីវិតរស់នៅមិនអាចខ្វះបាន ទាំងនេះជាការបង្ហាញឱ្យឃើញអំពីអន្តរអំពើរវាងមុខងារប្រើប្រាស់ដីមួយ ជាមួយមុខងារប្រើប្រាស់ដីមួយផ្សេងទៀត នៅលើទីតាំងដីដដែល។

យ៉ាងណាមិញក្នុងរយៈពេល១៥ឆ្នាំខាងមុខ រហូតដល់ឆ្នាំ២០៣២ ការប្រើប្រាស់ដីនៅក្នុងឃុំកំពង់គោ ត្រូវបានធ្វើការគិតគូរយ៉ាងយកចិត្តទុកដាក់ ដើម្បីដោះស្រាយបញ្ហា និងឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋដូចបានរៀបរាប់ខាងលើ ជាពិសេស គឺការដោះស្រាយក្នុងការបែងចែកការប្រើប្រាស់ដីធ្លី ដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ទៅតាមគោលការណ៍របស់រាជរដ្ឋាភិបាល និងដោយឈរលើស្មារតីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការប្រើប្រាស់ដីធ្លីក្នុងឃុំ។ បញ្ហាដែលត្រូវដោះស្រាយតាមតម្រូវការប្រើប្រាស់ខាងលើនេះ យើងសង្កេតឃើញក្នុងឃុំមានការផ្លាស់ប្ដូរមុខងារប្រើប្រាស់ដីពីស្រែប្រាំងស្ថិតក្នុងតំបន់២ ដែលជាតំបន់ការពារជុំវិញបឹងទន្លេសាប សម្រាប់ធ្វើការធានាបាននូវនិរន្តរភាពបរិស្ថាន និងប្រព័ន្ធជីវចម្រុះបឹងទន្លេសាប ជាពិសេសធានាជម្រកមច្ឆា របបជលសាស្ត្រ ការសាយភាយនៃល្បាប់ជាដើម ដើម្បីឱ្យក្លាយទៅជាដី ’’**ព្រៃដាំឡើងវិញ**’’ សម្រាប់ជាតំបន់ការពារជុំវិញបឹងទន្លេសាបឡើងវិញ ចំណែកការបាត់បង់ដីស្រែប្រាំងនឹងនាំឱ្យមានការប្រែប្រួលថយចុះបរិមាណផ្ទៃដីស្រែប្រាំង ដែលអាចនាំឱ្យមានការថយចុះផលិតផលស្រូវធ្វើឱ្យប៉ះពាល់ដល់ប្រាក់ចំណូលសម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងជាពិសេសប៉ះពាល់ដល់ការអភិវឌ្ឍឃុំកំពង់គោ។

តារាង 36៖ តារាងប្រើប្រាស់ដីនាពេលអនាគត

| ប្រភេទដីប្រើប្រាស់ | ផ្ទៃដីបច្ចុប្បន្ន (ហិកតា) | ផ្ទៃដី១៥ក្រោយ (ហិកតា) | បម្រែបម្រួល (ហិកតា) |
|---|---|---|---|
| **ក.ដីលំនៅឋាន ភូមិ** | **១៥៨,០១** | **១៥៨,០១** | **0** |
| -ដីលំនៅឋានភូមិក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ១៥៨,០១ | ១៥៨,០១ | 0 |
| **ខ.ដីស្រែប្រាំង** | **១៥២៧៣,៨៩** | **១៥ ២៥៥,៨៨** | **-១៨,០១** |
| - ដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ១៤៤,៨៤ | ១៤៤,៨៤ | 0 |
| - ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ៥៤០០,៤៩ | ៥៤០០,៤៩ | 0 |
| - ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប | ៩៧២៨,៥៦ | ៩៧១០,៥៥ | -១៨,០១ |

| | | | |
|---|---|---|---|
| **គ.ព្រៃដាំឡើងវិញ** | **0** | **១៨,០១** | **១៨,០១** |
| **ឃ.ព្រៃតាមដងស្ទឹង** | **៥៧,១១** | **៥៧,១១** | **0** |
| **ង.ព្រៃលិចទឹក** | **៩៣៩៤,១៤** | **៩៣៩៤,១៤** | **0** |
| **ច.បឹង** | **៩៩១,១៨** | **៩៩១,១៨** | **0** |
| -បឹង | ៩៩១,១៨ | ៩១៥,២៨ | -៧៥,៩ |
| -សហគមន៍នេសាទ | 0 | ៧៥,៩ | ៧៥,៩ |
| **ឆ.ស្ទឹងមានទឹកតាមរដូវ** | **៤១០,២៥** | **៤១០,២៥** | **0** |
| **ជ.អាងស្តុកទឹក** | ១៨៩២,០៥ | ១៨៩២,០៥ | **0** |
| -អាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ២៨៣,៥៤ | ២៨៣,៥៤ | **0** |
| -អាងស្តុកទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាប | ១៦០៨,៥១ | ១៦០៨,៥១ | **0** |
| **ឈ.ស្រះក្នុងតំបន់២ជុំវិញបឹងទន្លេសាប** | **៤,៨១** | **៤,៨១** | **0** |
| **ផ្ទៃដីឃុំសរុប** | **២៨១៩១,៤៤** | **២៨១៩១,៤៤** | **0** |

តារាង 37៖ តារាងផែនការផ្អែកហេដ្ឋារចនាសម្ព័ន្ធនាពេលអនាគត

| ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ប្រវែង/ចំនួន ឆ្នាំ២០១៧ (ម៉ែត្រ) | ប្រវែង/ ចំនួន ១៥ឆ្នាំ(ម៉ែត្រ) | បំរែបំរួល(ម៉ែត្រ) |
|---|---|---|---|
| ផ្លូវកៅស៊ូ | | ១៨៣៣៤,៧៥ | ១៨៣៣៤,៧៥ |
| ផ្លូវក្រាលគ្រួសក្រហម | ២៣៦៨៩,៧៦ | ៣១១២៧,១១ | ៧៤៣៧,៣៥ |
| ផ្លូវលំដីស/ផ្លូវរទេះ | ៤១៦៦៦,៩២ | ១៥៨៩៤,៨២ | -២៥៧៧២,១ |
| ប្រឡាយមេ | 0 | 0 | 0 |
| ប្រឡាយរង | ៥២៣៥,០៤ | ៥២៣៥,០៤ | 0 |
| ប្រឡាយតូច | ២០០១៣,៣៤ | ២៣១៦០,៦៧ | ៣១៤៧,៣៣ |
| ចំនួនស្ពានថ្ម/ប្រវែង | ១០ កន្លែង | ១៣ កន្លែង | ៣ កន្លែង |
| ចំនួនទ្វារស្នាក់ទឹក | ៧ កន្លែង | ១០ កន្លែង | ៣ កន្លែង |
| ចំនួនលូកាត់ផ្លូវ | ១១ កន្លែង | ៣៣ កន្លែង | ២២ កន្លែង |

តារាង 38៖ តារាងផែនការផ្អែកសេវាកម្មនាពេលអនាគត

| ហេដ្ឋារចនាសម្ព័ន្ធ | ចំនួនក្នុងឆ្នាំ២០១៧ | ចំនួនសម្រាប់១៥ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាមតេយ្យ | ៣ អគារ ៣ បន្ទប់ | ៣ អគារ ១៧ បន្ទប់ | ៥ អគារ ១៤ បន្ទប់ |
| សាលាបឋមសិក្សា | ៥ អគារ ១៩ បន្ទប់ | ៤ អគារ ២៥ បន្ទប់ | ១ អគារ ៦ បន្ទប់ |
| អនុវិទ្យាល័យ | ០១ អគារ ១០ បន្ទប់ | ២ អគារ ១៨ បន្ទប់ | ១ អគារ ៨បន្ទប់ |
| វិទ្យាល័យ | 0.0 | ១ អគារ ១៣ បន្ទប់ | ១ អគារ ១៣ បន្ទប់ |
| មណ្ឌលសុខភាព | ០១ | ០១ | 0.0 |

### ៣.២.២.ផែនទីប្រើប្រាស់ដីអនាគត

ការកំណត់ការប្រើប្រាស់ដីនាពេលអនាគតតនៅក្នុងឃុំ គឺជាការសម្រេចចិត្តមួយដ៏ត្រឹមត្រូវបំផុត ដោយពឹងផ្អែកទាំងស្រុងទៅលើការវិភាគដីដ៏សមស្របមួយ តាមរយៈការវាយតម្លៃបែបសាមញ្ញទៅលើធនធានដី រយៈកម្ពស់ ទីជំរាល ធនធានទឹក ការកាន់កាប់ដី និងសក្តានុពលនៃការប្រើប្រាស់ដីនៅក្នុងឃុំនេះនាពេលបច្ចុប្បន្ន ដោយយកផែនទីប្រើប្រាស់ដីធ្លីបច្ចុប្បន្នធ្វើជាមូលដ្ឋាននៅក្នុងការគិតពិចារណា ដូចមានរំលេចឱ្យឃើញនៅក្នុងតារាងទី៣៦ខាងលើនេះ ដោយមានភ្ជាប់នូវផែនទីប្រើប្រាស់ដីនាពេលអនាគតមួយដូចខាងក្រោម ដែលសមស្របអាចទទួលយកបាន និងអាចប្រើប្រាស់មានប្រសិទ្ធិភាព តាមរយៈការបង្ហាញយ៉ាងពិស្តារពីជម្រើសដ៏ល្អសម្រាប់ការប្រើប្រាស់ដីនាពេលអនាគតរបស់ឃុំនេះ។ ទន្ទឹមនឹងនោះផែនទីប្រើប្រាស់ដីនាពេលអនាគតខាងក្រោម ក៏មានការអត្ថាធិប្បាយលម្អិតទៅលើតំបន់ប្រើប្រាស់ដីនីមួយៗដែលបានកំណត់នៅលើផែនទីនេះផងដែរ។

ផែនទី 12៖ ផែនទីប្រើប្រាស់ដីអនាគត ឃុំកំពង់គោ



### ៣.២.៣.សេចក្តីអត្ថាធិប្បាយអំពីការប្រើប្រាស់ដីនាពេលអនាគត

ផ្អែកតាមផែនទីប្រើប្រាស់ដីអនាគតខាងលើ បានបង្ហាញឱ្យឃើញពីប្រភេទនៃការប្រើប្រាស់ដីនៅក្នុងឃុំកំពង់គោ ដូចខាងក្រោម៖

#### ក.ដីលំនៅឋាន ភូមិ

ដីលំនៅឋានភូមិ គឺជាដែលដីត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានមានលាយសួនដំណាំ និងឈើហូបផ្លែនៅជុំវិញ។ នាពេលអនាគតដីលំនៅឋាន ភូមិ ក្នុងឃុំកំពង់គោ មានផ្ទៃដីសរុបទំហំ ១៥៨,០១ ហិកតា ភាគច្រើនស្ថិតនៅសងខាងតាមបណ្តោយស្ទឹងសែននៅក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានចំនួន ០៥ភូមិ គឺភូមិកំពង់គោលើ កំពង់គោក្រោម ខ្សាច់ជីរស់ បូពឹង និងភូមិកោះគ្រុបបាយ។ ដីលំនៅឋាន ភូមិទាំងអស់ ជាតំបន់ទំនាបមធ្យម ដែលមានប្រភេទដីខ្សាច់ល្បាយ(ពណ៌ប្រផេះ) និងដីល្បាប់ ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមតែអាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងអ្វីនោះឡើយ ហើយបច្ចុប្បន្ននេះត្រូវបានប្រើប្រាស់ជាដីលំនៅឋានភូមិ ដោយពុំមានការពង្រីកបន្ថែមសម្រាប់ធ្វើការដោះស្រាយនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២ នោះឡើយ ដោយសារបច្ចុប្បន្ន ដីលំនៅឋានភូមិ នៅមានភាពទូលាយ ដែលត្រូវបានប្រើប្រាស់ទំហំដីប្រមាណជា ០,១០ហិកតា នៅក្នុងមួយគ្រួសារដែលអាចធ្វើការដោះស្រាយការសាងសង់លំនៅឋានរហូតដល់ឆ្នាំ២០៣២បាន ដោយនឹងត្រូវប្រើប្រាស់ទំហំដីថយចុះតិចតួចនៅសល់ប្រមាណជា ០,៩ហិកតា នៅក្នុងមួយគ្រួសារ ។ ដីដែលបានកំណត់ជាដីភូមិនេះ ពឹងផ្អែកលើប្រភពទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ និងស្រោចស្រពដំណាំរួមផ្សំជុំវិញលំនៅឋានបានមកពីស្ទឹង អណ្តូងស្នប់ ត្រពាំង ស្រះ ហើយត្រូវនាំទឹកមកប្រើប្រាស់ដោយម៉ូទ័របូម និងស្នប់សប់ដៃ។ នាពេលអនាគតទីតាំងដីលំនៅឋានភូមិ ដែលមានស្រាប់នាពេលបច្ចុប្បន្ននេះ នឹងត្រូវរក្សាទុកជាដី សម្រាប់ការសាងសង់លំនៅឋានដដែល ដោយសារតែទីតាំងដីនេះ មានស្ថានភាពជាដីខ្ពស់មិនលិចទឹកនៅក្នុងរដូវវស្សា និងនៅជាប់ផ្លូវសំខាន់ៗនៅក្នុងឃុំងាយស្រួលក្នុងការចេញចូលប្រកបរបររកស៊ីរបស់ប្រជាពលរដ្ឋ និងសមស្របសម្រាប់ការតាំងលំនៅឋាន ជាជម្រកដ៏កក់ក្តៅសម្រាប់ជិវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ។

#### ខ.ដីស្រែប្រាំង

នាពេលអនាគត ដីស្រែប្រាំងនៅក្នុងឃុំកំពង់គោ មានទំហំផ្ទៃដីសរុបចំនួន ១៥ ២៥៥,៨៨ ហិកតា ភាគច្រើនស្ថិតនៅភាគកើតនៃឃុំ និងមានចំនួនតិចតួចស្ថិតនៅភាគខាងលិចនៃឃុំ ដែលបច្ចុប្បន្នបាននិងកំពុងប្រើប្រាស់ជាដីស្រែប្រាំង ដោយពុំមានការពង្រីកបន្ថែម សម្រាប់ការដោះស្រាយទៅនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២នោះឡើយ។ ដីស្រែប្រាំងទាំងនេះ ជាតំបន់ទំនាបលិចទឹកតាមរដូវ ដែលមានប្រភេទដី និងប្រភពទឹកស្រោចស្រពខុសគ្នាទៅតាមស្ថានភាពតំបន់នីមួយៗ។ នាពេលអនាគតទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីស្រែប្រាំងដដែល ដោយសារដីនេះមានស្ថានភាពជាដីទាបលិចទឹកខ្លាំងនៅរដូវវស្សា ដែលមិនអាចធ្វើស្រែវស្សាបាននោះទេ គឺសមស្របសម្រាប់តែដំណាំស្រូវប្រាំងនាពេលទឹកស្រកចុះវិញប៉ុណ្ណោះ ដើម្បីទទួលបានផលក្នុងការជួយផ្គត់ផ្គង់ដល់ការហូបចុកសម្រាប់ជិវិតរស់នៅរបស់មនុស្ស និងនៅសល់លក់ទៅទីផ្សារក្នុង និងក្រៅប្រទេសបានចំណូលបង្កើនប្រាក់ចំណូលជាតិ និងគ្រួសារ ។ ដីស្រែប្រាំងនាពេលអនាគត មានទីតាំងស្ថិតនៅក្នុងបីតំបន់ការពារជុំវិញបឹងទន្លេសាបផ្សេងគ្នាដូចខាងក្រោម៖

**-ដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងនៅក្នុងតំបន់១ជុំវិញបឹងទន្លេសាប ស្ថិតនៅភាគខាងកើតឆៀងខាងជើងឃុំ រហូតទៅទល់នឹងព្រំប្រទល់ឃុំត្រពាំងឫស្សី ដែលមានទំហំផ្ទៃដីសរុបចំនួន ១៤៣,៤ ហិកតា។ ដីស្រែប្រាំងនៅក្នុងតំបន់១ជុំវិញបឹងទន្លេសាប គឺជាតំបន់ទំនាបលិចទឹកតាមរដូវ មានប្រភេទដីកណ្តេង និងដីខ្លាញ់ក្តាម (ពណ៌ក្រហម) ជាដីកម្មសិទ្ធិឯកជន ដែលត្រូវបានកាន់កាប់ និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋ និងមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និងស្ទឹងសែន ដែលបាននាំទឹកមកស្រោចស្រពតាមរយៈប្រឡាយកាវ៉ាក់ និងប្រឡាយឯកជន។

**- ដីស្រែប្រាំងក្នុងតំបន់២ ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប ស្ថិតនៅភាគខាងកើតឆៀងខាងជើងនៃឃុំ បន្តពីដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាបទៅប៉ែកកណ្តាលនៃឃុំមានទំហំផ្ទៃដីសរុបចំនួន ៥៣៨៥,៦៩ហិកតា។ ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាតំបន់ទំនាបលិចទឹកតាមរដូវ មានប្រភេទដី កណ្តេង ខ្លាញ់ក្តាម (ពណ៌ក្រហម) ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមអាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ។ ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ស្ទឹងសែន អូរតាឌុច អូរតាសេក និងទឹកអូតាឡោ ដែលបាននាំទឹកពីភាគខាងជើងនៃឃុំមកស្រោចស្រពតាមរយៈប្រឡាយការីតា ប្រឡាយពលកម្ម ប្រឡាយកាវ៉ាក់ ប្រឡាយអង្គរ ប្រឡាយចន្ទី ប្រឡាយព្រះគន្លង និងប្រឡាយឯកជន។

**-ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ស្ថិតនៅក្នុងតំបន់កាពារព្រៃលិចទឹក នៅភាគខាងលិចឆៀងខាងត្បូងនៃឃុំ មានទំហំផ្ទៃដីសរុបចំនួន ៩ ៧១០,៥៥ ហិកតា ។ ដីស្រែប្រាំងនៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ជាតំបន់ទំនាបលិចទឹកតាមរដូវ និងលិចទឹកអចិន្ត្រៃយ៍ មានប្រភេទដីកណ្តេងខ្លាញ់ក្តាម (ពណ៌ក្រហម) ដីពពាយកណ្តុរ(ពណ៌ខ្មៅ) និងដីមមោក ជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅក្នុងតំបន់ដែនព្រៃលិចទឹក ដែលហាមការកាប់រានដី ការដុតបំផ្លាញ ការរំលោភកាន់កាប់ដីព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប និងការសាងសង់សំណង់ថ្មីៗគ្រប់ប្រភេទ។ នាពេលអនាគត ក្នុងករណីដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាបទាំងនេះ មិនមានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យឆៀលចេញពីតំបន់ការពារព្រៃលិចទឹកទៅតាមការស្នើសុំរបស់អាជ្ញាធរដែនដីពាក់ព័ន្ធ ដោយផ្អែកលើឯកសារលិខិត បទដ្ឋានគតិយុត្តិ និងបទបញ្ជានានារបស់រាជរដ្ឋាភិបាលទេនោះ ដីស្រែប្រាំងទាំងនេះនឹងនៅតែកំណត់ការប្រើប្រាស់ជាដីព្រៃលិចទឹកនៅក្នុងតំបន់ការពារជុំវិញបឹងទន្លេសាប ដែលត្រូវធ្វើការការពារដដែល។ តែទោះបីមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ឱ្យឆៀលដីទាំងនេះជូនសម្រាប់ប្រើប្រាស់ជាដីស្រែក៏ដោយ ក៏ដីទាំងនេះមិនមែនជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋដែរ គឺពួកគាត់គ្រាន់តែអាចមានសិទ្ធិអាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ។ ដីស្រែប្រាំងនៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាប មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង បឹងព្រៃប្រស់ បឹងមហាពពាយ បឹងរាល បឹងបរស្នែង បឹងព្រះគន្លង បឹងកូនសត្វ អាងទឹកប្រាំបីរយ ទឹកអាងពីរពាន់ អាងតាយាង អាងយាយលី (ឯកជន) ដែលនាំទឹកមកស្រោចស្រពតាមរយៈប្រឡាយសុខមន្នី។

## គ.ព្រៃដាំឡើងវិញ

នៅឃុំកំពង់គោ នាពេលអនាគតនឹងមានដីព្រៃដាំឡើងវិញចំនួន ០១កន្លែង មានទំហំផ្ទៃដី ១៨,០១ហិកតា ស្ថិតនៅចុងភាគខាងត្បូងឃុំក្នុងភូមិខ្សាច់ជីរស់ ដែលបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាដីស្រែប្រាំង។ ព្រៃដាំឡើងវិញមានស្ថានភាពដី ជាតំបន់ទំនាបលិចទឹកតាមរដូវ និងលិចទឹកអចិន្ត្រៃយ៍ ដែលមានប្រភេទដីកណ្តេងខ្លាញ់ក្តាម (ពណ៌ក្រហម) ដីពពាយកណ្តុរ(ពណ៌ខ្មៅ)និងដីមមោកជាដីសាធារណៈរបស់រដ្ឋ។ នាពេលអនាគតទីតាំងដីនេះ

នឹងត្រូវបានកំណត់ជាដីព្រៃដាំឡើងវិញ ដោយសារទីតាំងដីនេះ ស្ថិតនៅមាត់បឹងធម្មជាតិ ហើយជាដីស្ថិតនៅក្នុងតំបន់ការពារព្រៃលិចទឹកជុំវិញបឹងទន្លេសាបស្រាប់ សម្រាប់ការធានាបាននូវនិរន្តរភាពបរិស្ថាន និងប្រព័ន្ធជីវចម្រុះបឹងទន្លេសាប ជាពិសេសធានាជម្រកមច្ឆាជាតិ របបជលសាស្ត្រ និងការសាយភាយនៃល្បាប់ជាដើម។

### ឃ.ព្រៃតាមដងស្ទឹង

ឃុំកំពង់គោ មានព្រៃតាមដងស្ទឹងសែន ស្ថិតនៅតាមបណ្តោយស្ទឹងសែនពីកើតទៅលិច មានទំហំផ្ទៃដីសរុបចំនួន ៥៧,១១ ហិកតា ជាដីសាធារណៈរបស់រដ្ឋ ដែលសម្បូរទៅដោយដើមឈើចំរុះដុះលាយឡំគ្នា មានដើមត្រសេក ដើមអំពិលទឹក ដើមភ្នំភ្លើង ត្រល់ កប្បាស់ព្រៃ ស្នាច់និងដើមរាំងជាដើម។ នាពេលអនាគត តំបន់នេះនឹងត្រូវរក្សាទុកជា ដីព្រៃតាមដងស្ទឹងដដែល ដើម្បីជាប្រយោជន៍ក្នុងការជួយការពារការហូរច្រោះបាក់ដីមាត់ស្ទឹង ជាជម្រកត្រីពងកូន ផ្តល់ឈើសម្រាប់ប្រើប្រាស់ផ្សេងៗ ធ្វើឱ្យដីក្នុងតំបន់នោះមានជីជាតិ ផ្តល់ឧស្ម័នអុកស៊ីសែនទៅដល់មនុស្សសត្វ និងស្រូបយកឧស្ម័នកាបូនិក ជាជម្រកសត្វព្រៃ ផ្តល់ខ្យល់អាកាសបរិសុទ្ធ ជួយទប់ទល់ខ្យល់ព្យុះ និងទឹកជំនន់ ជួយទាក់ទាញទឹកភ្លៀង ជួយរក្សាលំនឹងអាកាសធាតុ ។ល។

### ង.ព្រៃលិចទឹក

នាពេលអនាគតនៅក្នុងឃុំកំពង់គោ មានព្រៃលិចទឹកចំនួន ០៣ កន្លែង ស្ថិតនៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ដែលនៅក្នុងនោះទីតាំងទី១ ស្ថិតនៅភាគខាងជើងឆៀងខាងលិចនៃឃុំ ទីតាំងទី២ ស្ថិតនៅភាគខាងលិចផ្នែកកណ្តាលនៃឃុំ និងទីតាំងទី៣ ស្ថិតនៅចុងភាគខាងត្បូងនៃឃុំ មានទំហំផ្ទៃដីសរុបចំនួន ៩ ៣៩៤,១៤ ហិកតា ជាដីសាធារណៈរបស់រដ្ឋ ដែលសម្បូរទៅដោយដើមឈើចម្រុះដុះលាយឡំគ្នាដូចជា ដើមភ្នំភ្លើង កប្បាស់ព្រៃ ស្នាច់ និងដើមរាំងជាដើម ។ នាពេលអនាគត ទីតាំងដីព្រៃលិចទាំងទឹកនេះ នឹងត្រូវរក្សាទុកជាដីព្រៃលិចទឹកដដែល ដោយសារតំបន់នេះបានផ្តល់ជាជម្រកត្រីពងកូន ជាកន្លែងស្នាក់អាស្រ័យរបស់សត្វស្លាប ពស់ ឃ្មុំ និងអណ្តើកជាដើម ព្រមទាំងផ្តល់ឈើសម្រាប់ប្រើប្រាស់ផ្សេងៗ ធ្វើឱ្យដីក្នុងតំបន់នោះមានជីជាតិ ជួយផ្តល់ឧស្ម័នអុកស៊ីសែនដល់មនុស្ស និងស្រូបយកឧស្ម័នកាបូនិក ផ្តល់ខ្យល់អាកាសបរិសុទ្ធ ជួយទប់ទល់ខ្យល់ព្យុះនិងទឹកជំនន់ ជួយទាក់ទាញទឹកភ្លៀង ជួយរក្សាលំនឹងអាកាសធាតុ។ល។

### ច.បឹង

នៅឃុំកំពង់គោ មានបឹងចំនួន ០៥កន្លែង ដូចជា បឹងរៀល បឹងស្នែង បឹងព្រះគន្លង បឹងមហាពពាយ និងបឹងកូនសត្វដែលមានទំហំផ្ទៃដីសរុបចំនួន ៩៩១,១៨ហិកតា។ ក្នុងចំណោមបឹងធម្មជាតិទាំងនេះត្រូវបានកំណត់បឹងរៀលមួយមានផ្ទៃដីទំហំ ៧៥,៩ ហិកតា ជាបឹងសហគមន៍នេសាទ ។ បឹងធម្មជាតិទាំងអស់នេះ ជាដីសាធារណៈរបស់រដ្ឋ ដែលនៅពេលអនាគតត្រូវការពារ និងថែរក្សាទុកប្រើប្រាស់ សម្រាប់ជាប្រភពទឹកនៅក្នុងការស្រោចស្រពដំណាំកសិកម្ម និងប្រើប្រាស់ច្រើនយ៉ាងនៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល ព្រមទាំងជាប្រភពធនធានជលផលសម្រាប់ជាអាហារផ្តល់ប្រូតេអ៊ីន ជាប្រយោជន៍យ៉ាងសំខាន់នៅក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ចំណែកបឹងសហគមន៍នេសាទ ដែលត្រូវយកចិត្តទុកដាក់ការពារពិសេសដោយឡែក សម្រាប់ការធានាការគ្រប់គ្រងធនធានមច្ឆាជាតិឱ្យបានគង់វង្សថែមទៀត ។

ឆ.ស្ទឹង

នាពេលអនាគត នៅក្នុងឃុំកំពង់គោ មានស្ទឹងចំនួន ០១ ខ្សែ គឺស្ទឹងសែន ដែលមានទំហំផ្ទៃដីសរុបចំនួន ៤១០,២៥ ហិកតា ហើយជាដីសាធារណៈរបស់រដ្ឋ ។ ស្ទឹងនេះហូរកាត់ឃុំកើតទៅលិច ដែលជាប្រភពទឹកដ៏សំខាន់សម្រាប់ការស្រោចស្រពដំណាំកសិកម្ម ជាពិសេសស្រែប្រាំង និងប្រើប្រាស់ផ្សេងៗទៀតទៅតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ហើយអាចប្រើប្រាស់បានពេញមួយឆ្នាំ ។ នាពេលអនាគតស្ទឹងនេះ គឺជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់នៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានជលផល ជាអាហារផ្តល់ប្រូតេអ៊ីនមានប្រយោជន៍យ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋ។

ជ.អាងស្តុកទឹក

ឃុំកំពង់គោ នាពេលអនាគតមានអាងស្តុកទឹក ០៧កន្លែង និងមានទំហំផ្ទៃដីសរុប ១៨៩២,០៥ហិកតា ស្ថិតនៅភាគខាងត្បូងនៃឃុំលាយឡំជាមួយនឹងដីស្រែប្រាំង ដែលច្បុប្បន្នបាននិងកំពុងប្រើប្រាស់ជាអាងស្តុកទឹកដោយពុំមានការពង្រីកបន្ថែមសម្រាប់ការដោះស្រាយទឹកស្រោចស្រពរហូតដល់ឆ្នាំ២០៣២នោះឡើយ ។ នាពេលអនាគតអាងស្តុកទឹកទាំងនេះ នឹងនៅតែជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល និងព្រមទាំងជាប្រភពធនធានជលផលសម្រាប់ជាអាហារផ្តល់ប្រូតេអ៊ីន ដែលជាប្រយោជន៍យ៉ាងសំខាន់នៅក្នុងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ។ ហើយស្ថិតនៅតាម ០២តំបន់ផ្សេងគ្នា គឺតំបន់២ និងតំបន់៣ ដូចមានរៀបរាប់ខាងក្រោម៖

**-អាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

អាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាបមាន ០១ កន្លែង ទំហំផ្ទៃដីសរុបចំនួន ២៨៣,៥៤ ហិកតា ។ អាងស្តុកទឹកទាំងនេះជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋមានសិទ្ធត្រឹមតែកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិក្នុងការចាត់ចែងឡើយ ។

**-អាងស្តុកទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាប**

អាងស្តុកទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាបមាន ០៦ កន្លែង ទំហំផ្ទៃដីសរុបចំនួន ១ ៦០៨,៥១ហិកតា។ អាងស្តុកទឹកនេះ ជាដីសាធារណៈរបស់រដ្ឋស្ថិតក្នុងតំបន់ដែនព្រៃលិចទឹក ដែលហាមការរំលោភកាន់កាប់អាងស្តុកទឹកទាំងនេះ ។ នាពេលអនាគត ក្នុងករណីអាងស្តុកទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាបនេះ មិនមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ឱ្យផ្ទៀលចេញពីតំបន់ការពារព្រៃលិចទឹក តាមកាស្នើសុំរបស់អាជ្ញាធរដែនដីពាក់ព័ន្ធ ដោយផ្អែកលើឯកសារលិខិតបទដ្ឋានគតិយុត្ត និងបទបញ្ជានានារបស់រាជរដ្ឋាភិបាលទេនោះ អាងស្តុកទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាបទាំងនេះនឹងនៅតែកំណត់ការប្រើប្រាស់ជាដីព្រៃលិចទឹកជុំវិញបឹងទន្លេសាប ដែលត្រូវការពារដដែល ហើយទោះបីមានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យផ្ទៀលដីទាំងនេះ ជូនសម្រាប់ប្រើប្រាស់ជាអាងស្តុកទឹកក៏ដោយ ក៏អាងស្តុកទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាបនេះ មិនមែនជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋដែរ ពួកគាត់គ្រាន់តែអាចមានសិទ្ធិអាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ។

ឈ.ស្រះក្នុងតំបន់២ជុំវិញបឹងទន្លេសាប

នៅក្នុងពេលអនាគត ឃុំកំពង់គោ មានចំនួន ០៨ កន្លែង មានផ្ទៃដីសរុបទំហំ ៤,៨១ ហិកតា ស្ថិតនៅក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋមានសិទ្ធិត្រឹមតែកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិក្នុងការចាត់ចែងឡើយ ។ នាពេលបច្ចុប្បន្នស្រះទាំងនេះ ត្រូវបានប្រើប្រាស់ជាប្រភព

ទឹកស្រោចស្រពនិងប្រើប្រាស់ផ្សេងៗទៀតតាមការចាំបាច់របស់ប្រជាពលរដ្ឋព្រមទាំង ជាប្រភពធនធានមច្ឆាជាតិទៀតផង។ នាពេលអនាគតស្រះនេះ នឹងនៅតែជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដែល ព្រមទាំងជាប្រភពធនធានជលផលសម្រាប់ជាអាហារផ្តល់ប្រូតេអ៊ីនដែលជាប្រយោជន៍យ៉ាងសំខាន់ក្នុងការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ។

## ៣.៣.ដំណោះស្រាយផ្សេងៗ ក្នុងករណីខ្វះខាតដីធ្លី

ជាការពិត បច្ចុប្បន្នយើងបានរកឃើញនៅក្នុងឃុំកំពង់គោ មានប្រជាពលរដ្ឋក្រីក្រខ្វះខាតដីលំនៅឋានពិតប្រាកដចំនួន ២៥០ គ្រួសារ និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារពិតប្រាកដចំនួន ៣១៣ គ្រួសារ ដូចបានរកឃើញនៅក្នុងជំពូកទី១ នៃរបាយការណ៍នេះ ដែលបច្ចុប្បន្នគ្រួសារមួយចំនួនកំពុងរស់នៅលើចិញ្ចើមផ្លូវ លើដីចំណីប្រឡាយ ចំណីស្ទឹង និងមួយចំនួនទៀតរស់នៅក្នុងខ្ទមលើដីរបស់អ្នកដទៃ ដែលពួកគាត់ត្រូវស៊ីឈ្នួលឱ្យគេដើម្បីចិញ្ចឹមជីវិត។ ដូច្នេះ ដើម្បីដោះស្រាយដីសម្រាប់ការសាងសង់លំនៅឋាន និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ដែលអាចផ្តល់ឱកាសឱ្យពួកគាត់មានជម្រករស់នៅសមរម្យ និងបង្កើតឱកាសការងារ ដើម្បីទទួលបានប្រាក់ចំណូលជូនពួកគាត់បាន អាជ្ញាធរដែនដីនៅគ្រប់ជាន់ថ្នាក់ត្រូវខិតខំដោះស្រាយដីតាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ចនៅថ្នាក់ក្រោមជាតិ ដែលត្រូវបានផ្តួចផ្តើមឡើងដោយក្រុមប្រឹក្សាឃុំកំពង់គោ។ ដីធ្លីដែលត្រូវដោះស្រាយជូនពួកគាត់ ដូចដែលបានធ្វើការវិភាគដោះស្រាយក្នុងជំពូកទី ២ ត្រង់ចំណុច ២.១.៣ ខាងលើ គឺដីសម្រាប់លំនៅឋានមានទំហំផ្ទៃដី **៦២,៥** ហិកតា និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារមានទំហំផ្ទៃដី **៦២៦** ហិកតា ។

## ៣.៤.កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព

និរន្តរភាពនៃការប្រើប្រាស់ដី គឺជាការធានាឱ្យបាននូវគោលដៅ និងអត្ថប្រយោជន៍នៃការប្រើប្រាស់ដីទាំងនោះ ដែលការធានាទាំងអស់នេះ ត្រូវតែកើតមានឡើងជាបន្តបន្ទាប់ជារៀងរហូត ដោយពុំមានឈប់ឈរ។ និរន្តរភាព គឺជាចំណុចស្នូលសម្រាប់ការប្រើប្រាស់ដីនៅគ្រប់តំបន់គោលដៅទាំងអស់តាមរយៈការកំណត់កត្តាចាំបាច់នានា សម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធភាព និងធានាឱ្យមាននិរន្តរភាព។

### ៣.៤.១.កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព

ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍ សេដ្ឋកិច្ចសង្គម ព្រមទាំងថែរក្សាការពារបរិស្ថាន និងធនធានធម្មជាតិប្រកបដោយចីរភាព។ ដោយធានាបានការផ្គត់ផ្គង់សេចក្តីត្រូវការ និងការទទួលខុសត្រូវចំពោះផលប្រយោជន៍របស់ប្រជាពលរដ្ឋនាពេលបច្ចុប្បន្ន និងបន្តទៅដល់កូនចៅ របស់ពួកគាត់ទៅជំនាន់ក្រោយទៀតបាននោះ ត្រូវតែយកចិត្តទុកដាក់ដល់ការគ្រប់គ្រងទៅលើការប្រើប្រាស់សេវាកម្ម និងលើវិស័យទាំងអស់នៅក្នុងឃុំដែលបានកំណត់រួចតាមរយៈការខិតខំប្រឹងប្រែងអនុវត្តឱ្យសម្រេចបានទៅលើកត្តាចាំបាច់មួយចំនួនដូចខាងក្រោម៖

#### ក.ការគ្រប់គ្រងប្រព័ន្ធកសិកម្ម

បើពិនិត្យទៅលើលក្ខណៈភូមិសាស្ត្រ និងសក្តានុពលនៃធនធាន ដែលមានក្នុងឃុំកំពង់គោ ដែលក្រុមការងារបានធ្វើការសិក្សាស្រាវជ្រាវរកឃើញនោះត្រូវបានកំណត់យ៉ាងច្បាស់ថាសង្កាត់មានគោលដៅអភិវឌ្ឍ ទៅថ្ងៃអនាគតពឹងផ្អែកទៅលើវិស័យកសិកម្មជាចម្បង ដែលនៅក្នុងនោះបានផ្តោតសំខាន់ទៅលើដំណាំស្រូវ ។ ដូចនេះឃុំកំពង់គោ នឹងមានតួនាទីសំខាន់មួយក្នុងការធ្វើឱ្យសម្រេចបាននូវគោលនយោបាយ ជំរុញផលិតកម្មស្រូវនិង

នាំចេញអង្ករបស់រាជរដ្ឋាភិបាល ដែលត្រូវចាំបាច់ទាមទារឱ្យមានការគ្រប់គ្រងប្រព័ន្ធកសិកម្ម ក្នុងមូលដ្ឋានឱ្យបានរឹងមាំនិងមាននិរន្តរភាពទៅថ្ងៃអនាគត ដោយត្រូវយកចិត្តទុកដាក់ជំរុញផលិតកម្មស្រូវ ដើម្បីបង្កើនទិន្នផលស្រូឱ្យបានខ្ពស់អស់សក្តានុពល ដើម្បីមានលទ្ធភាពនាំស្រូវចេញបានច្រើនសល់ពីការហូបចុក ដើម្បីឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋ ។

ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍឃុំកំពង់គោដូចខាងលើ ត្រូវមានការគ្រប់គ្រងដីស្រែក្នុងឃុំឱ្យបានច្បាស់លាស់ ដោយរាល់ការសម្រេចចិត្តប្តូរមុខងារប្រើប្រាស់ដី ពីកសិកម្មទៅបម្រើឱ្យការសាងសង់និងបម្រើឱ្យការប្រើប្រាស់ផ្សេងៗទៀត ត្រូវតែមានការចូលរួមពីប្រជាពលរដ្ឋ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ប្រកបទៅដោយតម្លាភាព ដោយអនុលោមតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងត្រូវមានការផ្សព្វផ្សាយជាសាធារណៈ។ ម្យ៉ាងទៀតដីស្រែប្រាំងនៅក្នុងឃុំកំពង់គោបច្ចុប្បន្ន បានរកឃើញថាមានផ្ទៃដីទំហំ ១៨,០១ ហិកតា នឹងត្រូវរក្សាទុកជាដីដាំព្រៃឡើងវិញ ព្រមទាំង ៩៧១០,៥៥ ហិកតា ស្ថិតនៅក្នុងដែនការពារព្រៃលិចទឹកដែលកំណត់ដោយរាជរដ្ឋាភិបាល ដែលនៅពេលអនាគតនឹងត្រូវរក្សាទុកជាដីព្រៃលិចទឹកវិញ ដែលនឹងនាំឱ្យទំហំផ្ទៃដីស្រែប្រាំងមានការថយចុះ ប្រសិនបើមិនមានការអនុញ្ញាតពីរាជរដ្ឋាភិបាលក្នុងការឃ្មៀលដីស្រែទាំងនេះ ចេញពីដីព្រៃលិចទឹក ដើម្បីជូនប្រជាពលរដ្ឋប្រើប្រាស់អាស្រ័យផលទេនោះ។ ទន្ទឹមនឹងការគ្រប់គ្រងដីស្រែ ត្រូវគិតគូរពីទឹកស្រោចស្រព ដោយធ្វើយ៉ាងណា អាចធ្វើស្រែបង្កើនរដូវ និងស្រែប្រាំងឱ្យបានពីរដងក្នុងមួយឆ្នាំ តាមរយៈការស្តារអាងស្តុកទឹកចំនួន ១ កន្លែង មានទំហំផ្ទៃដី ៣៧៥,២៣ ហិកតា ស្តារអូរឡោ ទំហំ ៣,៧៣ ហិកតា ស្តារអូរលូ ទំហំ ០,៧៣ ហិកតា ស្តារអូរសំរោង ទំហំ ០,៦៧ ហិកតា ស្តារអូរអោន ទំហំ ០,៣៥ ហិកតា និងស្តារអូរអែង ទំហំ ០,៩៥ ហិកតា សម្រាប់ជាប្រភពទឹកស្រោចស្រព និងស្តារប្រព័ន្ធប្រឡាយចាស់ៗ ព្រមទាំងស្តារប្រឡាយថ្មីៗ ៣ ខ្សែ ប្រវែង ៣ ១៤៧,៣៣ ម៉ែត្រសម្រាប់ជាមធ្យោបាយក្នុងការនាំទឹកទៅស្រោចស្រពដីស្រែទាំងអស់បានគ្រប់គ្រាន់។ បន្ទាប់ពីកត្តាដី និងទឹក នៅមានកត្តាបច្ចេកទេសក្នុងការដាំដុះបន្ថែមទៀត ដោយត្រូវគិតគូរជំរុញការធ្វើស្រែ ទៅតាមបែបប្រពលវប្បកម្មទំនើបដូចដែលមានលើកឡើងតាមការវិភាគក្នុងជំពូកទី២ ត្រង់ចំណុចការផ្តល់ឱកាសដោយបច្ចេកវិទ្យាទំនើប ដែលកត្តានេះនឹងលើកទឹកចិត្តឱ្យយុវជនចូលរួមក្នុងការងារកសិកម្មបានច្រើនផងដែរ ព្រោះយុវជនតែងគិតថាការធ្វើស្រែនាំឱ្យមានការនឿយហត់ ប្រឡាក់ប្រឡូកដីភក់មិនស្អាតបាត ដែលជាការយល់ខុស គឺតាមពិតទៅការធ្វើស្រែចម្ការតាមបច្ចេកទេសទំនើបកសិករ ក៏អាចស្លៀកពាក់បានស្អាតបាត និងពាក់ក្រវាត់កប្រើប្រាស់កុំព្យូទ័រនៅក្នុងបន្ទប់ម៉ាស៊ីនត្រជាក់បានដូចគ្នា។ ក្នុងការគ្រប់គ្រងប្រព័ន្ធកសិកម្មនៅឃុំកំពង់គោ មិនមែនយកចិត្តទុកដាក់តែនៅលើការជំរុញផលិតកម្មកសិកម្មដូចខាងលើប៉ុណ្ណោះទេ តែត្រូវខិតខំពង្រឹងការប្រមូលគ្នាចងក្រង ជាសហគមន៍កសិករដើម្បីជ្រើសរើសតំណាងអាចទៅចូលរួមតស៊ូមតិក្នុងការចចាររកទីផ្សារ ក៏ដូចជាមួយឈ្មួញ ដោយធានាការធ្វើស្រែចម្ការបានទិន្នផលខ្ពស់មានគុណភាពតាមស្តង់ដារតម្រូវការទីផ្សារ និងធានាលំនឹងតម្លៃក្នុងទីផ្សារផងដែរ។

តាមការគណនា ដែលផ្អែកទៅលើការការគិតគូរនៅក្នុងជំពូក២ ត្រង់ចំណុច ១.២.៣ អាចឱ្យយើងរំពឹងទុកអំពីបរិមាណផលស្រូវនាំចេញនាពេលអនាគតក្នុងអំឡុងពេល១៥ឆ្នាំខាងមុខដូចខាងក្រោមៈ

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ប្រជាពលរដ្ឋកើនឡើងដល់ ៩០៥១នាក់

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ដីស្រែមានទំហំ ១៥ ២៥៥,៨៨ ហិកតា

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ កំណត់ទិន្នផលស្រូវ ៥ តោន ក្នុងមួយហិកតា

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ កំណត់ធ្វើស្រែបាន២ដងក្នុងមួយឆ្នាំ

-ដូច្នេះក្នុងអំឡុងពេល១៥ឆ្នាំ(២០១៧-២០៣២) ផលិតផលស្រូវទទួលបានក្នុង១ឆ្នាំជាមធ្យមៈ

**១៥ ២៥៥,៨៨ ហិកតា x ៥តោន/ហិកតា x ២ ដង = ១៥២ ៥៥៨,៨ តោន/ឆ្នាំ**

-ប្រជាពលរដ្ឋ១នាក់ ត្រូវការអង្ករសម្រាប់ហូបក្នុងមួយឆ្នាំមានចំនួន ១៤៣ គីឡូក្រាម ដែលបើគិតជាស្រូវត្រូវការចំនួន ២២៤ គីឡូក្រាម (ផ្អែកតាមរបាយការណ៍ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ)

- ក្នុងអំឡុងពេល១៥ឆ្នាំខាងមុខត្រូវការបរិមាណស្រូវសម្រាប់ផ្គត់ផ្គង់ការហូបចុកក្នុងមួយឆ្នាំជាមធ្យម

**៩០៥១ នាក់ x ២២៤ គីឡូក្រាម = ២ ០២៧ ៤២៤ គីឡូក្រាម/ឆ្នាំ ស្មើនឹង ២ ០២៧,៤២ តោន/ឆ្នាំ**

-ក្នុងអំឡុងពេល១៥ឆ្នាំខាងមុខត្រូវការបរិមាណពូជស្រូវក្នុងមួយឆ្នាំជាមធ្យម ៖

**១៥ ២៥៥,៨៨ ហិកតា x ៣០០ គីឡូក្រាម = ៤ ៥៧៦ ៧៦៤គីឡូក្រាម/ឆ្នាំ ស្មើនឹង ៤៥៧៦,៧៦តោន/ឆ្នាំ**

-ដូច្នេះក្នុងអំឡុងពេល១៥ឆ្នាំខាងមុខ ផលិតផលស្រូវទទួលបានសម្រាប់ការនាំចេញក្នុងមួយឆ្នាំជាមធ្យមៈ

**១៥២ ៥៥៨,៨ តោន/ឆ្នាំ - ២ ០២៧,៤២តោន/ឆ្នាំ - ៤៥៧៦,៧៦តោន/ឆ្នាំ =១៤៥៩៥៤,៦២តោន/ឆ្នាំ**

-តែបើគិតជាអង្ករវិញអាចនាំចេញបានក្នុងមួយឆ្នាំជាមធ្យមៈ

**១៤៥ ៩៥៤,៦២ តោន/ឆ្នាំ x ៦០%=៨៧៥៧២,៧៧តោន/ឆ្នាំ**

### ខ.ការគ្រប់គ្រងព្រៃឈើ ជលផល និង ធនធានសំខាន់ៗផ្សេងៗទៀត

នៅពេលអនាគត ទោះបីក្នុងឃុំកំពង់គោ បានកំណត់រក្សាទុកតំបន់ប្រើប្រាស់ដី សម្រាប់ព្រៃឈើមួយចំនួនដូចជា ព្រៃដាំឡើងវិញ ព្រៃលិចទឹក និងព្រៃតាមដងស្ទឹងហើយក៏ដោយ ក៏នៅក្នុងឃុំនៅមានដីតាមដងផ្លូវ ប្រឡាយទឹក ទីធ្លាសាលាឃុំ សាលារៀន មណ្ឌលសុខភាព វត្តអារាម និងនៅតាមលំនៅឋានជាដើម ដែលត្រូវធ្វើការជំរុញការដាំដើមឈើបន្ថែមទៀតដែរ ដើម្បីធ្វើឱ្យមានដើមឈើពណ៌បៃតងនៅពាសពេញទូទាំងឃុំ បម្រើផលប្រយោជន៍ដូចបានលើកឡើងនៅក្នុងជំពូកទី២នៃរបាយការណ៍នេះហើយត្រូវបន្តថែទាំដើមឈើទាំងនោះឱ្យបាននៅគង់វង្សនិងលូតលាស់បានល្អ។ ដូច្នេះដើម្បីគ្រប់គ្រងធានានិរន្តរភាពព្រៃឈើទាំងនេះ អាជ្ញាធរមានសមត្ថកិច្ចទាំងអស់ ជាពិសេសក្រុមប្រឹក្សាឃុំ ត្រូវមានវិធានការទប់ស្កាត់ការបាត់បង់ព្រៃឈើដូចមានរៀបរាប់ខាងក្រោម៖

- ជំរុញការចុះបញ្ជីដីរដ្ឋ
- ត្រូវបង្កើនការគោរពច្បាប់ដើម្បីការពារព្រៃឈើ
- ត្រូវដាក់ទោសចំពោះជនប្រព្រឹត្តបទល្មើសកាប់បំផ្លាញព្រៃឈើ
- ផ្សព្វផ្សាយពីផលប្រយោជន៍នៃព្រៃឈើ
- បណ្តុះបណ្តាលឱ្យប្រជាពលរដ្ឋមានស្មារតីម្ចាស់ការដាំដើមឈើ និងថែរក្សាព្រៃឈើ។

ដោយឡែកមច្ឆាជាតិ ដែលជាធនធានជលផលនៅក្នុងឃុំកំពង់គោ បានកំណត់ ស្ទឹងសែន ស្ទឹងតូច បឹងអាងស្តុក ស្រះទឹក ជាប្រភពធនធានទាំងនេះ តែទៅថ្ងៃអនាគតក៏ត្រូវខិតខំយកចិត្តទុកដាក់ នៅក្នុងការចិញ្ចឹមត្រីថែមទៀត ដើម្បីបានផលគ្រប់គ្រាន់អាចផ្តល់ជាប្រភពប្រូតេអ៊ីនសាច់ដ៏សំខាន់ សម្រាប់ប្រជាពលរដ្ឋនៅក្នុងឃុំ។ ចំពោះស្ថានភាពសមស្របនៅក្នុងឃុំគួរចិញ្ចឹមត្រីតាមបែបចិញ្ចឹមក្នុងស្រះខ្នាតតូច ស្រះចិញ្ចឹមត្រីតាមគ្រួសារ និងកសិដ្ឋានចិញ្ចឹមត្រីក្នុងស្រែ ដែលជាទម្រង់មួយនៃការបង្កើនបរិមាណត្រី ដោយអាចបង្កើនផលិតភាពជលផលតាមប្រពលវប្បកម្ម (តាមវាលស្រែ) ហើយមានប្រយោជន៍ក្នុងការប្រើត្រីសម្រាប់ទប់ទល់សត្វល្អិត និងដង្កូវហ្វូងក្នុងស្រែ ដែលបំផ្លាញផលដំណាំផងដែរ។ ដូច្នេះដើម្បីធានាឱ្យមានការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាពតទៅអនាគត អាជ្ញាធរមានសមត្ថកិច្ច ជាពិសេសក្រុមប្រឹក្សាឃុំត្រូវមានវិធានទប់ស្កាត់ការបំផ្លាញធនធានជលផលនេះដូចខាងក្រោម៖

- ត្រូវគ្រប់គ្រង និងអភិរក្សធនធានជលផលឱ្យបានល្អ
- លុបបំបាត់ការធ្វើនេសាទលើសកម្រិត

- ថែរក្សា ការពារព្រៃលិចទឹកជាជម្រកត្រីពង
- ជំរុញការធ្វើវារីវប្បកម្មតាមគ្រប់រូបភាព
- ទប់ស្កាត់ការប្រើឧបករណ៍ឆក់ និងសារធាតុពុលគ្រប់ប្រភេទទៅលើធនធានជលផលគ្រប់ប្រភេទ

ចំណែកធនធានសំខាន់ៗ ក្រៅពីការរៀបរាប់ខាងលើនេះ នៅក្នុងឃុំពុំមានឃើញធនធានអ្វីផ្សេង ដែលគួរឱ្យកត់សម្គាល់ឡើយ។

### ៣.៤.២.គម្រោងគាំទ្រចាំបាច់ សម្រាប់គាំទ្រនិរន្តរភាព

ដើម្បីមានមធ្យោបាយគ្រប់គ្រាន់ធ្វើឱ្យសម្រេចបាននូវការគ្រប់គ្រងប្រព័ន្ធកសិកម្ម និងធនធានសំខាន់ៗសម្រាប់ការគាំទ្រដល់និរន្តរភាពនៃការអភិវឌ្ឍ និងអភិរក្សដីធ្លីនិងធនធានធម្មជាតិនៅក្នុងឃុំកំពង់គោចាំបាច់ត្រូវបង្កើតឱ្យមានគម្រោងគាំទ្រជាអាទិភាពមួយចំនួនដូចខាងក្រោមៈ

- កែលម្អផ្លូវដីសទៅផ្លូវគ្រួសក្រហម
- ពីផ្លូវគ្រួសក្រហមទៅផ្លូវបេតុងឬផ្លូវកៅស៊ូ
- សាងសង់ផ្លូវបេតុងឬផ្លូវកៅស៊ូ
- សាងសង់លូកាត់ផ្លូវ
- សាងសង់ស្ពានឆ្លងស្ទឹងសែន
- សាងសង់ស្ពាន(បេតុង បេឡេ)
- ស្តារប្រឡាយអមសងខាងផ្លូវ
- ស្តារប្រឡាយចាស់ឡើងវិញ
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម
- បណ្តុះបណ្តាលផលិតជីកំប៉ុស្ត
- បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី
- បណ្តុះបណ្តាលពីការដាំដំណាំស្រូវ
- តបណ្តាញទឹកស្អាតឱ្យដល់គ្រប់ភូមិ
- តបណ្តាញអគ្គិសនីឱ្យដល់គ្រប់ភូមិ
- បង្កើតសហគមន៍កសិករ ដើម្បីជំរុញការអនុវត្តន៍ភូមិ១ ផលិតផល១
- ដោះស្រាយដីសម្បទានសង្គមកិច្ច
- ជំរុញធ្វើប័ណ្ណក្រីក្រឱ្យដល់ស្ត្រីគ្រប់រូប
- ផ្តល់អាហាររូបត្ថម្ភដល់ស្ត្រី និងកុមារ
- ផ្សព្វផ្សាយពីការចាក់វ៉ាក់សាំងការពារជម្ងឺដល់ស្ត្រីមានផ្ទៃពោះ និងកុមារ
- ពង្រឹងសេវាថែទាំសុខភាព និងព្យាបាលជម្ងឺជូនដល់ប្រជាពលរដ្ឋឱ្យបានល្អប្រសើរឡើង
- ផ្សព្វផ្សាយពីច្បាប់ភូមិបាល ច្បាប់ជលផលជូនដល់ប្រជាពលរដ្ឋ

## ៣.៥.សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់២០៣២)

ផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់គោ នៅឆ្នាំ២០១៧ បានឱ្យដឹងថា ឃុំកំពង់គោ ជាឃុំមួយក្នុងចំណោមឃុំ១១ របស់ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ មានភូមិចំនួន ៥ និងមានទំហំផ្ទៃដីសរុបចំនួន ២៨ ១៩១,៤៤ ហិកតា។ នៅក្នុងឆ្នាំ២០១៧ ឃុំកំពង់គោ មានប្រជាពលរដ្ឋ

រស់នៅ ១ ៥៤៣ គ្រួសារ និងប្រជាជនសរុប ៧ ៦៥៦ នាក់ ក្នុងនោះស្ត្រី ៣ ៩២១ នាក់ មានដង់ស៊ីតេប្រជាជនមធ្យម ២៦,៦ នាក់/គ.ម²។ ឃុំកំពង់គោ មានសណ្ឋានភាពដីខ្សាច់ល្បាយ (ពណ៌ប្រផេះ) ដីល្បាប់ ដីកណ្តេងខ្លាញ់ក្តាម (ពណ៌ក្រហម) ពពាយកណ្តុរ (ពណ៌ខ្មៅ) និងដីមមោក ត្រូវបានប្រើប្រាស់សម្រាប់ដីស្រែប្រាំង ដែលបានផ្តល់នូវមុខរបរសំខាន់ដល់ប្រជាពលរដ្ឋភាគច្រើនរហូតដល់ប្រមាណ ៩៧,៦ ភាគរយ សេវាកម្ម ២,៤ ភាគរយ និងសិប្បកម្មមិនមាននោះទេ។ ទន្ទឹមនេះឃុំកំពង់គោ មានប្រភពទឹកស្រោចស្រព និងប្រើប្រាស់ក្នុងជីវភាពរស់នៅពីស្ទឹងសែននិងបឹងធម្មជាតិ ដែលអាចនាំទឹកមកប្រើប្រាស់តាមរយៈប្រឡាយរងចំនួន ២ខ្សែ និងប្រឡាយជើងក្អែបចំនួន១៦ខ្សែ។ បន្ថែមពីលើនេះ ឃុំកំពង់គោស្ថិតនៅជិតទីរួមខេត្តកំពង់ធំ ដែលជាការផ្តល់ឱកាសឱ្យឃុំកំពង់គោអាចទាញយកប្រយោជន៍ពីតំបន់នេះបាន ហើយឃុំនៅមានផ្លូវផ្សេងៗទៀត គ្រប់គ្រាន់អាចភ្ជាប់ទំនាក់ទនងពីភូមិមួយទៅភូមិមួយក្នុងឃុំ និងអាចភ្ជាប់ទំនាក់ទំនងទៅឃុំ និងស្រុកផ្សេង រួមទាំងទីរួមខេត្តកំពង់ធំបានដោយងាយស្រួល។ ចំពោះកំណើនប្រជាជនវិញបានរកឃើញថា ក្នុងរយៈពេល១៥ឆ្នាំទៅមុខរហូតដល់ឆ្នាំ២០៣២ នឹងមានប្រជាជនកើនឡើងរហូតដល់ ៩ ០៥១នាក់ ដែលត្រូវយកចិត្តទុកដាក់គិតគូររកដំណោះស្រាយពីការប្រើប្រាស់ដីដើម្បីឆ្លើយតបបានទៅនឹងតម្រូវការរបស់ប្រជាជន។ ទន្ទឹមនឹងនេះ ក៏បានរកឃើញអំពីបញ្ហាប្រឈមមួយចំនួនទៅលើសកម្មភាពនៃការអភិវឌ្ឍឃុំកំពង់គោបច្ចុប្បន្នផងដែរ ដូចជា ការធ្វើស្រែដែលមានសក្តានុពលក្នុងការអភិវឌ្ឍឃុំមិនទាន់ទទួលបានផលស្រូវសមស្របអស់លទ្ធភាពនៅឡើយ ដោយសារតែដីស្រែទាំងអស់នេះកាន់តែខ្សត់ជីជាតិ ខ្វះទឹកក្នុងការស្រោចស្រពសម្រាប់ផ្គត់ផ្គង់ដល់ការធ្វើស្រែបង្កើនរដូវ ខ្វះចំណេះដឹងពីបច្ចេកទេសនៃការដាំដុះ ខ្វះចំណេះដឹងពីបច្ចេកទេសក្នុងការប្រើប្រាស់ជីគីមី និងថ្នាំពុលកសិកម្ម ប្រព័ន្ធប្រឡាយដែលមានស្រាប់បានរាក់ ខ្វះកម្លាំងពលកម្ម ដោយសារចំណាកស្រុកច្រើន គឺបាត់កម្លាំងពលកម្មជិតពាក់កណ្តាលនៃកម្លាំងពលកម្មដែលមាន និងតម្លៃកសិផលមិនមានស្ថេរភាព ដោយឈ្មួញជាអ្នកកំណត់តម្លៃ។ ទន្ទឹមការរកឃើញបញ្ហាមួយចំនួនលើសកម្មភាពអភិវឌ្ឍឃុំ ក៏បានរកឃើញថា ជាទូទៅការប្រើប្រាស់ដីនៅក្នុងឃុំបច្ចុប្បន្ន បានចំទិសដៅ និងមានភាពសមស្របដូចជា ការប្រើប្រាស់ដីសម្រាប់លំនៅឋាន កសិកម្ម ប្រព័ន្ធផ្លូវគមនាគមន៍ ប្រព័ន្ធធារាសាស្រ្តជាដើម ដែលទៅថ្ងៃអនាគ ក៏នៅតែរក្សាមុខងារប្រើប្រាស់ដីទាំងនោះឱ្យនៅដដែល ។ បន្ថែមពីលើនេះទៀត ក៏បានរកឃើញវិធីដោះស្រាយបញ្ហាផ្សេងៗទៀតផងដែរ សម្រាប់អនាគត ដូចជាត្រូវសាងសង់បន្ទប់រៀនបន្ថែម ពង្រឹងការផ្តល់សេវាសុខាភិបាលឱ្យបានប្រសើរឡើង ជំរុញឱ្យប្រជាពលរដ្ឋហូបទឹកស្អាត និងប្រើប្រាស់បង្គន់អនាម័យ ជួសជុលផ្លូវ ស្តារប្រឡាយដាំដើមឈើតាមទីសាធារណៈ ជំរុញការចិញ្ចឹមត្រីតាមស្រែ។ ជាពិសេសការដោះស្រាយដី សម្រាប់លំនៅឋានក្នុងភូមិ ដែលមានស្រាប់ដែលបច្ចុប្បន្ននៅទូលាយអាចផ្គត់ផ្គង់ការសាងសង់លំនៅឋានបាន។ ដើម្បីដោះស្រាយទៅនឹងកំណើនប្រជាជន ត្រូវពង្រឹងការធ្វើស្រែឱ្យបាន២ដងក្នុងមួយឆ្នាំ និងធ្វើស្រែតាមបែបប្រពលវប្បកម្ម ដើម្បីបង្កើនទិន្នផលស្រូវឱ្យបានខ្ពស់អស់សក្តានុពល សម្រាប់ផ្គត់ផ្គង់ការហូបចុក និងអាចមានលទ្ធភាពនាំស្រូវចេញបានចំនួន ១៤៥ ៩៥៤,៦២ តោន/ឆ្នាំ ដើម្បីជួយផ្គត់ផ្គង់ដល់ជីវភាពរបស់ប្រជាពលរដ្ឋក្នុងឃុំឱ្យបានកាន់តែប្រសើរឡើង ស្របទៅនឹងកំណើនប្រជាពលរដ្ឋ ព្រមទាំងជួយជំរុញកំណើនសេដ្ឋកិច្ចក្នុងឃុំ។ ការរកឃើញភាពសមស្រប និងជម្រើសនៃការប្រើប្រាស់ដីនៅក្នុងឃុំកំពង់គោនាពេលអនាគត បានមកពីការវាយតម្លៃដ៏ត្រឹមត្រូវដោយផ្អែកលើធនធានដី រយៈកម្ពស់ដី ទីជំរាល ធនធានទឹក ការកាន់កាប់ដី និងសក្តានុពលនៃការប្រើប្រាស់ដីនៅក្នុងឃុំនេះ ដើម្បីធានាថាការប្រើប្រាស់ដីក្នុងឃុំកំពង់គោទៅអនាគតប្រកបដោយចីរភាពនិងសមធម៌។

ដូច្នេះ ដើម្បីសម្រេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីនៅក្នុងឃុំកំពង់គោ ស្របតាមស្ថានភាពដីជាក់ស្តែង និងសក្តានុពលនៃធម្មជាតិ សម្រាប់ការគាំទ្រកិច្ចអភិវឌ្ឍសេដ្ឋកិច្ចសង្គម ប្រកបទៅដោយចីរភាព និងសមធម៌ រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ

នាពេលអនាគត ដូចបានរកឃើញមានចែងលម្អិតនៅក្នុងរបាយការណ៍បច្ចេកទេសនេះ រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ជាពិសេសក្រុមប្រឹក្សាឃុំ ដែលជាតំណាងប្រជាពលរដ្ឋនៅក្នុងឃុំកំពង់គោ ហើយមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅក្នុងឃុំ ត្រូវខិតខំអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់គោនេះ ដែលបានអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការរួច ដោយបញ្ជៀបទៅនិងផែនការអភិវឌ្ឍឃុំ ឱ្យបានប្រកបដោយប្រសិទ្ធិភាពខ្ពស់បំផុត ដើម្បីធានាភាពជោគជ័យនៃផែនការនេះ។


លេខ៖ ២៥២/២០២០

បានពិនិត្យ និង សូមគោរពជូន

លោកអភិបាលនៃគណៈអភិបាលស្រុក និង ជាប្រធានគណៈកម្មាធិការ
រៀបចំដែនដី និងនគរូបនីយកម្មស្រុកកំពង់ស្វាយ មេត្តាពិនិត្យ និង សម្រេច។

ថ្ងៃ ពុធ ៥កើត ខែកត្តិក ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

កំពង់គោ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០២០

មេឃុំកំពង់គោ


លេខ៖ ២៧៣ / ២០២០

បានពិនិត្យ និង សូមគោរពជូន

ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និង ជាប្រធានគណៈកម្មាធិការ
រៀបចំដែនដី និង នគរូបនីយកម្មខេត្តកំពង់ធំ មេត្តាពិនិត្យ និង សម្រេចដ៏ខ្ពង់ខ្ពស់ ។

ថ្ងៃ សុក្រ ៦រោច ខែ កត្តិក ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

កំពង់ស្វាយ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០២០

អភិបាលនៃគណៈអភិបាលស្រុក និង ជាប្រធាន
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកកំពង់ស្វាយ

លេខ៖ [illegible]/២០២១

បានឃើញ និងឯកភាពសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ

ថ្ងៃ [illegible] ខែ ភទ្របទ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

កំពង់ធំ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០២១

**អភិបាលនៃគណៈអភិបាលខេត្ត និងជា**

**ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ**

សុខ លូ

# ឯកសារឧបសម្ព័ន្ធ

# ផែនទីហេដ្ឋារចនាសម្ព័ន្ធ ឃុំកំពង់គោ



# ផែនទីប្រព័ន្ធធារាសាស្ត្រ ឃុំកំពង់គោ




ផែនទីប្រើប្រាស់ដីសាមញ្ញ ឃុំកំពង់គោ
456000mE
460000
464000
468000
472000
476000
480000mE
1408000mN
1404000
1400000
1396000
1392000
1388000mN
ជ
ក
ត
ល
ឃុំត្បែង
ឃុំត្រពាំងឫស្សី
ឃុំសាន់គ
ឃុំចំណាក្រោម
ឃុំក្បីដូង
កោះក្របបាយ
បូពីង
កំពង់គោលើ
កំពង់គោក្រោម
ខ្សាច់ជីរស់
សង្កាត់អូរគន្ធ
ឃុំផាត់សណ្ដាយ
សង្កាត់ស្រយ៉ូវ
ឃុំផ្លូវទូក
ឃុំច្រណូក
សញ្ញាសម្គាល់
ព្រំប្រទល់ និងទីតាំងរដ្ឋបាល
សាលាឃុំ
ភូមិ
ព្រំប្រទល់រដ្ឋបាលឃុំ
ហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ន
មន្ទីរពេទ្យ មណ្ឌលសុខភាព
វត្ត
សាលារៀន
ស្ពាន
ទ្វារទឹក
ផ្លូវគ្រួសក្រហម ឬក្រាលថ្ម
ផ្លូវដីស ឬផ្លូវរទេះ
ប្រឡាយរង
ប្រឡាយតូច
ប្រភេទប្រើប្រាស់ដីបច្ចុប្បន្ន
ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ
ដីកសិកម្ម
ដីព្រៃ/គម្របព្រៃ
ផ្ទៃទឹក និងខ្សែទឹក
ប្រព័ន្ធកូអរដោនេ
ចំណោលផែនទី : UTM
តំបន់ទី : 48N
ទិន្នន័យយោង : WGS 1984
អេលីបសូអ៊ីត : WGS 1984
ប្រភពទិន្នន័យ
-ទីតាំងវិនិយោគ ប្រភពពីផែនការអភិវឌ្ឍឃុំរយៈពេល៥ឆ្នាំនិងអាជ្ញាធរមូលដ្ឋាន
-ទិន្នន័យទីតាំង និងព្រំប្រទល់រដ្ឋបាលប្រភពពីនាយកដ្ឋានភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (២០១៩)
-ទិន្នន័យសំខាន់ៗផ្សេងទៀត ប្រភពពីមន្ទីរ/ស្ថាប័នពាក់ព័ន្ធជុំវិញខេត្ត
បញ្ជាក់
-ព័ត៌មានដែលបង្ហាញនៅលើផែនទីនេះ គឺផ្អែកលើទិន្នន័យដែលបានបង្កើតឡើងដោយថ្នាក់ជាតិនិងត្រូវបានកែសម្រួលដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន
-ព្រំប្រទល់រដ្ឋបាលទាំងនោះ មិនអាចចាត់ទុកជាផ្លូវការ និងខ្សែបន្ទាត់ព្រំដែននៃផែនទីនេះ ពុំមានតម្លៃជាផ្លូវការអន្តរជាតិឡើយ
-ផែនទីនេះត្រូវបានបោះពុម្ពនៅ ខែ.................................. ឆ្នាំ២០.......
មាត្រដ្ឋាន ១:១០០ ០០០
០ ២ ៤
គីឡូម៉ែត្រ
គាំទ្រដោយ
ADB
GAFSP
global agriculture & food security program
អនុវត្តដោយ
MINISTRY OF ECONOMY AND FINANCE

# ផែនទីគម្រោងវិនិយោគ ឃុំកំពង់គោ




**សញ្ញាសម្គាល់**

ព្រំប្រទល់ និងទីតាំងរដ្ឋបាល

- សាលាឃុំ
- ភូមិ
- ព្រំប្រទល់រដ្ឋបាលឃុំ

ហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ន

- មន្ទីរពេទ្យ មណ្ឌលសុខភាព
- វត្ត
- សាលារៀន
- ស្ពាន
- ទ្វារទឹក
- ផ្លូវគ្រួសក្រហម ឬក្រាលថ្ម
- ផ្លូវដីស ឬផ្លូវរទេះ
- ប្រឡាយរង
- ប្រឡាយតូច

ប្រភេទប្រើប្រាស់ដីបច្ចុប្បន្ន

- ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ
- ដីកសិកម្ម
- ដីព្រៃ/គម្របព្រៃ
- ផ្ទៃទឹក និងខ្សែទឹក

គម្រោងវិនិយោគ

- សាងសង់ស្ពានបេតុង
- សាងសង់លូកាត់ផ្លូវលូ
- ជួសជុលផ្លូវដីស
- ស្តារប្រឡាយរង
- ស្តារប្រឡាយតូច
- ជីកប្រឡាយតូច
- សាងសង់ផ្លូវចាក់កៅស៊ូ

**ប្រព័ន្ធភូមិសាស្ត្រ**

ចំណោលផែនទី : UTM
តំបន់ទី : 48N
ទិន្នន័យយោង : WGS 1984
អេលីបស្វូអីត : WGS 1984

**ប្រភពទិន្នន័យ**

-ទីតាំងវិនិយោគ ប្រភពពីផែនការអភិវឌ្ឍឃុំរយៈពេល៥ឆ្នាំនិងអាជ្ញាធរមូលដ្ឋាន
-ទិន្នន័យទីតាំង និងព្រំប្រទល់រដ្ឋបាលប្រភពពីនាយកដ្ឋានភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (២០១៩)
-ទិន្នន័យសំខាន់ៗផ្សេងទៀត ប្រភពពីមន្ទីរ/ស្ថាប័នពាក់ព័ន្ធជុំវិញខេត្ត

**បញ្ជាក់**

-ព័ត៌មានដែលបង្ហាញនៅលើផែនទីនេះ គឺផ្អែកលើទិន្នន័យដែលបានបង្កើតឡើងដោយថ្នាក់ជាតិនិងត្រូវបានកែសម្រួលដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន
-ព្រំប្រទល់រដ្ឋបាលទាំងនោះ មិនអាចចាត់ទុកជាផ្លូវការ និងខ្សែបន្ទាត់ព្រំដែននៃផែនទីនេះ ពុំមានតម្លៃជាផ្លូវការអន្តរជាតិឡើយ
-ផែនទីនេះត្រូវបានបោះពុម្ពនៅ ខែ.................................. ឆ្នាំ២០.......

 

សកម្មភាពក្រុមការងារចូលរួមប្រជុំទទួលការណែនាំពីនីតិវិធីរៀបចំផែនការប្រើប្រាស់ដីថ្នាក់ឃុំ
ពីប្រធានគ្រប់គ្រងគម្រោងរបស់ក្រុមហ៊ុន

 

សកម្មភាពប្រមូលទិន្នន័យនៅតាមមន្ទីរជុំវិញខេត្តរបស់ក្រុមការងារក្រុមហ៊ុន SBK

 

កិច្ចប្រជុំពិភាក្សាអំពីផែនទីប្រើប្រាស់ដីបច្ចុប្បន្នឃុំកំពង់គោ




សកម្មភាពក្រុមការងារចុះទីវាលស្រង់ទិន្នន័យបំពេញបន្ថែមលើ
ផែនទីប្រើប្រាស់ដីបច្ចុប្បន្នដែលមានស្រាប់ឃុំកំពង់គោ




សកម្មភាពចូលរួមត្រួតពិនិត្យ ណែនាំ
ការអនុវត្តគម្រោងរបស់អង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ(NIO)




កិច្ចប្រជុំក្រុមប្រឹក្សាឃុំកំពង់គោ ដើម្បីពិនិត្យ និងឯកភាពទៅលើ
សេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់គោ





កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកកំពង់ស្វាយ ដើម្បីពិនិត្យ និងឯកភាពទៅលើ សេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់គោ







ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



សកម្មភាពផ្សព្វផ្សាយជាសាធារណៈសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅឃុំកំពង់គោ




កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ
ដើម្បីពិនិត្យ និងឯកភាពទៅលើ សេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំកំពង់គោ

# ឯកសារយោង

# ឯកសារយោង

១. ឯកសារព័ត៌មានស្ថានភាពឃុំកំពង់គោស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៣ របស់មន្ទីរផែនការខេត្ត
២. ឯកសារព័ត៌មានស្ថានភាពឃុំកំពង់គោស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៤ របស់មន្ទីរផែនការខេត្ត
៣. ឯកសារព័ត៌មានស្ថានភាពឃុំកំពង់គោស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៥ របស់មន្ទីរផែនការខេត្ត
៤. ឯកសារព័ត៌មានស្ថានភាពឃុំកំពង់គោស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៦របស់មន្ទីរផែនការខេត្ត
៥. ឯកសារព័ត៌មានស្ថានភាពឃុំកំពង់គោស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៧ របស់មន្ទីរផែនការខេត្ត
៦. ផែនការអភិវឌ្ឍឃុំរយៈពេលប្រាំឆ្នាំ(២០១៨-២០២២)របស់ឃុំកំពង់គោ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ
៧. កម្មវិធីវិនិយោគឃុំកំពង់គោ ឆ្នាំ២០១៧ របស់ឃុំកំពង់គោ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ
៨.របាយការណ៍ស្តីពីការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថាន ឃុំកំពង់គោ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ឆ្នាំ២០១៧